# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៩ លេខ ២ ខែកុម្ភៈ ព.ស. ២៤៩៩ គ.ស. ១៩៥៧

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា* បញ្ជីរឿង *ទំព័រ*

— ជាបកថារឿងពុទ្ធសាសនានៅប្រទេសកម្ពុជា ..... លោកសម-ញាណ ... ១០៣
— គិលានុបដ្ឋានកថា .. (តចប់) ........ ព្រះភិក្ខុ ប៉ាង-ខាត់ ... ១០៩
— ប្រស្នាលទ្ធិកប់អានខ្មោចបិសាច (តចប់) ..... ឃុនបណ្ណានុរក្ស ប៊ូ-ប៊ូ .. ១១៦

*ផ្នែកអក្សរសាស្ត្រ*

— ភាសិតខ្មែរ ..................... លោកទៀង-តៃឈុន .. ១២២
— សាវតារនាងហ្ស៊ីទជាកិ . (តចប់) ........ លោក អ៊ុំ-ហ៊ី ប្រែ .. ១២៩
— រឿងទេវទូតរបស់លោកអម្រឹតក្សត្រ៊ីអ៊ុក ....... លោកញ៉ុក-ថែម ពិនិត្យ . ១៤៤
— សុភាសិតប្រដៅជនប្រុសស្រី (តមក) .... ព្រះឃោសធម្ម ម៉ុង-សែស . ១៥២
— ពេជ្រព្រះភជា (តមក) ........... លោក ស៊ុន-ហ៊ាន ប្រែ .. ១៦៣
— រឿងសាមកុក (តមក) ........... ឧកញ៉ា ទូ-កន ប្រែ .. ១៦៩

*កំណត់ប្រវត្តិការណ៍*

— ពិធីបុណ្យកតញ្ញូកតវេទីតាំងពោះសម្ដេចព្រះធម្មលិខិត
ឧត្តមប្រឹក្សា ល្វី-ឯម របស់សមណៈនិស្សិត លោកឯន-ប៊ង់ . ១៧៨
— ដំណើរទៅកាន់ប្រទេសឥណ្ឌានៃលោក ភ៉យ-ប៊ុក ..... លោកភ៉យ-ប៊ុក ១៨៨
— វចនានុក្រមសំស្ក្រឹតខ្មែរ . (តមក) .... វីរិយបណ្ឌិតោ ភិក្ខុ ប៉ាង-ខាត់ . ១៩៦

មួយឆ្នាំមាន ១២សៀវភៅ—ដំឡៃជាវ ២៣០រ៉ៀល

# KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

## TABLE DES MATIÈRES

### PARTIE RELIGIEUSE:

-Causerie sur le bouddhisme au Camboge . . . par *M. SAM-NHEAN*. 103
-Gilanupatthanakatha (suite et fin) . . . . . . par vén. *PANG-KHAT*.109
-Les diables (suite et fin) . . . . . . . . . . . par *M. . . . BOU-PO*...116

### PARTIE LITTERAIRE:

-Recueils de proverbes Khmers ... par *M. TIANG-TAY-CHHUN*..122
-Histoire de Jeanne d'Arc (en vers) suite et fin ... par *M. OUM-HY* ...129
-Histoire de Devanda de *M. MOK*,
revue et corrigée . . . . . . . . . . . . . . . par *M. NHOC-THEM*.144
-Bons Conseils . . . . . . . . . . . . . . . . . par vén. *MŒUNG-SES* .152
-Conte "*LE DIAMANT DE RAJA*" (suite) traduit par *M. SIN-HEAN* 163
-Histoire de samkok (suite) . . . . . . traduit par *M. NOU-KAN* ..169

### NOTES ET CHRONIQUES:

-Fête de reconnaissance des disciples en l'honneur
de Samdach Dhammalikhita *LOUIS-EM* . . . par *M. EN-PANG*. 178
-Voyage en Inde de *M. RAY-BUC* . . . . . par *M. RAY-BUC* . 188
-Dictionnaire Sanskrit - Khmer (suite) ... par vén. *PANG-KHAT* ... 196

Prix d'abonnement annuel (comprenant 12 numéros): 230$00

# ផ្នែកសាសនា

## បាឋកថាជាវៀនពុទ្ធសាសនានៅប្រទេសកម្ពុជា

## លោក សម.ញាណ ដែលបានទៅជាអ្នកសង្កេតការណ៍ឯកជន

ក្នុងពិធីបុណ្យរម្លោកពុទ្ធសករាជ ២៥០០ នៅប្រទេសឥណ្ឌា
បានថ្លែងបាឋកថានេះនៅថ្ងៃទី ១៨ វិច្ឆិកា ១៩៥៦ ក្នុងវិទ្យាល័យគិតៈនារីមល
ក្នុងចំណោមមហាវិទ្យាល័យនាក្រុងញូដេលី មានសេចក្ដីដូចតទៅនេះ :-

*លោកចាងហ្វាង ! អស់លោកជាសិស្សានុសិស្សទាំងឡាយ !*

*ពេលនេះ ខ្ញុំមានកិត្តិយសណាស់ ដោយបានទទួលសេចក្ដីសុំពីអស់លោកឲ្យខ្ញុំមកថ្លែងបាឋកថានៅវិទ្យាល័យនេះ ។*

*ខ្ញុំមានអំណរយ៉ាងក្រៃលែងចំពោះលោកចាងហ្វាងនិងអស់លោកជាសិស្សានុសិស្ស ដែលបានអញ្ជើញមកជួបជុំជាកិត្តិយស ដើម្បីស្ដាប់នូវបាឋកថារបស់ខ្ញុំនេះ ។*

*មុននឹងថ្លែង ខ្ញុំសូមប្រកាសជំរាបអំពីប្រវត្តិខ្លួនខ្ញុំសិន ខ្ញុំនេះឋានៈជាប្រធានពុទ្ធិកសមាគមកម្ពុជាផង ហើយជាអនុប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រនៃប្រទេសកម្ពុជាផង ប៉ុន្តែដែលខ្ញុំធ្វើដំណើរមកកាន់មហាប្រទេសឥណ្ឌានេះក្ដី មកថ្លែងបាឋកថានេះក្ដី ឥតមានតាំងនាមឋានៈណាមួយខាងលើនេះទេ គឺមកក្នុងឋានៈជាឯកជន ។*

*ខ្លួនខ្ញុំនិងព្រះមហាថេរៈ ព្រមទាំងអស់លោកដែលនិមន្តអញ្ជើញមកជាមួយនេះ គឺជាតិខ្មែរៗ ជនជាតិខ្មែរនិងជនជាតិឥណ្ឌា បានទាក់ទងគ្នាតាំង*

ពីបូរាណមកហើយ ។ តាមពង្សាវតារថាមានក្សត្រអង្គមួយព្រះនាម កោណ្ឌញ្ញៈ ទ្រង់យាងចេញពីមហាប្រទេសឥណ្ឌានេះទៅកាន់ជ្រោយ សុវណ្ណភូមិ . . . គ្រានោះព្រះអង្គមានជ័យជំនះបានសោយរាជសម្បត្តិជា បឋមវង្សខ្មែរ ទ្រង់ព្រះនាម ព្រះបាទកុមេរុ ខ្លះហៅ ព្រះថោង ព្រះអង្គនោះហើយជាមហាក្សត្រទី ១ នៃប្រទេសកម្ពុជា ។

ប្រជាជនខ្មែរទុកជនជាតិឥណ្ឌាជាមេរៀមច្បង ដោយព្រះមហាក្សត្រ ទី១របស់ខ្មែរ ទ្រង់យាងចេញពីមហាប្រទេសនេះទៅ ហើយមហាប្រទេស នេះជាដើមកំណើតនៃពុទ្ធសាសនា ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់បានឧបត្តិ ឡើងក្នុងមហាប្រទេសនេះ ។

ហេតុដែលនាំឲ្យឃ្លាតការប្រាស្រ័យទាក់ទងគ្នាជាយូរអង្វែងឆ្នាំ ព្រោះមានមហាអំណាចមកសង្កត់សង្កិនប្រទេសយើងទាំងពីរ ។ ឥឡូវនេះ ជាសម័យសករាជថ្មីនៃប្រទេសយើងបានឯករាជ្យ រដ្ឋាភិបាលយើងទាំងពីរ បានទាក់ទងគ្នាជាថ្មីឡើងវិញ រវាងវប្បធម៌, សេដ្ឋកិច្ច និង ពុទ្ធសាសនា ទាំងនៅជាអព្យាក្រឹត កាន់វិន័យបញ្ចសីលាដូចគ្នា ទាំងនេះជាលទ្ធផល យ៉ាងប្រសើរក្រៃលែង ចំពោះប្រទេសយើងទាំងពីរ ។

ខ្ញុំមានវាសនាល្អបានមកគោរពបុណ្យពុទ្ធជយន្តិក្នុងមហាប្រទេសនេះ, បុណ្យនេះប្រទេសខ្មែរ ក៏ប្រុងធ្វើនៅឆ្នាំក្រោយដែរ ព្រោះប្រជាជនខ្មែរ និយមរាប់អានពុទ្ធសាសនាណាស់ ។

ប្រទេសខ្មែរមានប្រជាជនតែប្រាំមួយលាននាក់ទេ ប៉ុន្តែមានវត្តអារាម

២.៧០០ វត្ត មានលោកសង្ឃជាង ៧ ម៉ឺនអង្គ, វត្តទាំងឡាយនោះគេទុកដូចជាសាលារៀន ហើយលោកសង្ឃធ្វើជាគ្រូបង្រៀនអក្សរសាស្ត្រផងៗ

មានលោកអង្គខ្លះស្វះស្វែងរៀនបំណេះវិជ្ជាខាងពុទ្ធសាសនា មានតួយ៉ាងដូច

– លោកភិក្ខុ គួប-គិ.ទៀង ចិតបញ្ញោ មកនៅរៀនក្នុងវិទ្យាល័យគិនោរមល់នេះ;

– លោកអង្គខ្លះនៅរៀនឯនាលន្ទា, អង្គខ្លះនៅរៀនឯសន្តិនិកេតន៍សព្វថ្ងៃនេះស្រាប់ ៗ

មានជនខ្លះដែរ គេឆ្ងល់ថាការគោរពកាន់ពុទ្ធសាសនាដូច្នេះតើមានប្រយោជន៍អ្វី ?

ខ្ញុំអាចឆ្លើយបានថា បើប្រតិបត្តិតាមទុកទពុទ្ធសាសនា ដែលមិនតឹងពេក មិនធូរពេក ទើបមានប្រយោជន៍នៅនាលោកយនេះផង ទៅបរលោកនាយផង ព្រោះទុកទពុទ្ធសាសនាតែងទូន្មានបុរសស្ត្រីទាំងឡាយ ឲ្យលះបង់នូវសេចក្ដីខ្ជិលច្រអូសចេញ ហើយខំព្យាយាមប្រកបកិច្ចការទៀង ព្រោះសេចក្ដីខ្ជិលជាមេអាក្រក់នាំឲ្យមនុស្សយើងទន់អន់ថោកទាបយ៉ាំងពិបំផុត ដូចមានន័យថា:

– កាលបើខ្ជិលហើយ តើនឹងមានបំណេះ (បិញ្ញ:) ពីណា?

– កាលបើគ្មានបំណេះ (សិប្ប:) ហើយ តើនឹងរកទ្រព្យសម្បត្តិឯណាបាន ?

– កាលបើខ្វះក្រ គ្មានទ្រព្យសម្បត្តិហើយ ម្ដេចឡើយនឹងវិនាសញាតិ

មិត្តឯណាមកកាប់សាទខ្លួន ?

កាលបើគ្មានញាតិមិត្តហើយ តើសេចក្តីសុខនឹងមានពីណាមកដល់ខ្លួន ? ។ល។

ការខូចប្រយោជន៍ទាំងនេះព្រោះអ្វី? ព្រោះតែខ្ជិលៈនេះឯង ហេតុនេះហើយ ទើបព្រះពុទ្ធសាសនាទូន្មានឲ្យលះបង់នូវសេចក្តីខ្ជិលចេញ ហើយឲ្យតាំងចិត្តខំប្រាហ៍រៀនចំណេះផ្សេងៗ (សិល្បៈ) ។ល។ ទើបមានប្រយោជន៍នៅនាលោកក៏យនេះ ។

ម្យ៉ាងទៀត ព្រះពុទ្ធសាសនាទូន្មានឲ្យបានប្រយោជន៍ទៅខាងបរលោកនាយផង ទៅនាលោកក៏យៈនេះផង សឹងមានន័យយ៉ាងខ្លី ៣គឺថា

១– កុំធ្វើអំពើអាក្រក់ (បាប) ,

២– ឲ្យធ្វើតែអំពើល្អ (បុណ្យ) ,

៣– ធ្វើចិត្តឲ្យស្អាតស្អុះស្អំ ។

# អធិប្បាយសារុប

មនុស្សយើង ត្រូវញ៉ាំងកាយវាចាចិត្ត ឲ្យប្រកបតាមសីលធម៌ ឲ្យមានមេត្តាករុណាដល់មនុស្សនឹងសត្វផងទៅ ទើបសមនឹងឋានៈខ្លួនជាមនុស្សជាតិ ។ កាលបើយើងចង់បានសុខ ត្រូវយើងកុំបៀតបៀនគេប៉ុណ្ណេះជាដើម ។ ព្រះពុទ្ធសាសនាយ៉ាងខ្លីនេះ បើប្រៀបផ្ទឹមនឹងវិន័យបញ្ញត្តិ ដែលមហាប្រទេសនេះនឹងប្រទេសនានាបានប្រកាសនៅក្រុងបានដូចនោះ មានន័យស្របគ្នា; កាលបើប្រតិបត្តិតាមហើយ សេក្តីសុខ

សន្តិភាពសីឥមានដល់សត្វលោក នៅនាលោកិយនេះផង នៅបរលោកនាយផងដោយពិត ។

ថ្វីបើទីពុទ្ធសាសនាខាងលើនេះមានដំណើរកន្លងទៅ២.៥០០ ឆ្នាំហើយ ក៏នៅតែមានរសជាតិយ៉ាងប្រសើរ ជាហេតុនាំឲ្យប្រជាជនច្រើនប្រទេសនឹករលឹកចំពោះព្រះមហាករុណាទិគុណ នៃព្រះសម្មាព្រះសម្ពុទ្ធបាននាំគ្នាមកគោរពបុណ្យពុទ្ធជយន្តិ ដែលរដ្ឋាភិបាលមហាប្រទេសនេះផ្តើមធ្វើយ៉ាងទទូលាកែ ។

លោកបាងហ្វាង! លោកគង់បានជ្រាបហើយថា ពិភពលោកសព្វថ្ងៃនេះ នៅតែជុំកូនរំសោវ នៅតែព្យួរកាំភ្លើងបៀតបៀនគ្នា, អំពើនេះកើតឡើងដោយអំណាចចិត្តមានលោភៈ ទោសៈ មោហៈ, អ្នកដែលចូលចិត្តធ្វើអំពើនេះ ប្រហែលមកពីមិនយល់ទីពុទ្ធសាសនា ឬក៏យល់ដែរប៉ុន្តែមិនព្រមប្រតិបត្តិតាម ។

កុងនាមផ្ទាល់ខ្លួនខ្ញុំ សូមគោរព សូមពរ អំពីលោកជាសាស្ត្រាចារ្យនាវិទ្យាល័យនេះ ព្រមទាំងអស់លោកជាសាស្ត្រាចារ្យនៅវិទ្យាល័យនានាផ្សេងទៀត, ខ្ញុំសូមឲ្យលោកលៃលកគេងគ្រោងក្បួនបង្ហាត់បង្រៀនទូវសិស្សានុសិស្ស ទាំងឡាយឲ្យបេះធ្វើចិត្តឲ្យស្អាតស្អំបរិសុទ្ធតាមទីពុទ្ធសាសនាផង ។ បើបានតាមសុំនេះ សង្ឃឹមថាយុវជនយុវតីជាសិស្សានុសិស្សទាំងឡាយ កាលបើចេញពីសាលារៀនទៅទីណាំនាំប្រជាជាតិមិនឲ្យបៀតបៀនគ្នា កាលបើធ្វើបានដូច្នេះ សេចក្តីសុខ, សន្តិភាព ក្នុងពិភពលោកនឹងកើតមានដោយពិត ។

មុននឹងបញ្ចប់ខ្ញុំសូមបួងសួងចំពោះគុណព្រះរតនត្រ័យ:

-សូមឲ្យសត្វលោករស់នៅជាសុខសាន្ត!

-សូមឲ្យផ្ទៃភពាលនៃមហាប្រទេសឥណ្ឌា ព្រមទាំងប្រជាជនជាតិឥណ្ឌា បានប្រកបដោយនូវសេចក្ដីសុខសេចក្ដីចំរើន!

-សូមឲ្យអស់លោកជាសាស្ត្រាចារ្យ ហើយនឹងសិស្សានុសិស្សទាំងឡាយ បានប្រកបដោយអាយុ: វណ្ណ: សុខ: ពល: គឺរៀងទៅកុំបីឃ្លៀងឃ្លាតឡើយ !

× ×

×

បន្ទាប់ពីថ្លែងសុន្ទរកថាជាភាសាខ្មែរនេះចប់ហើយ, ព្រះមហា គួច-គី-ឡេង ជាតបណ្ឌិត ជាសមណ:និស្សិតខ្មែរដែលនៅសិក្សាក្នុងវិទ្យាល័យតិនោះនោះ បានប្រែពីភាសាខ្មែរទៅជាភាសាអង់គ្លេស នាំឲ្យអស់លោកជាសាស្ត្រាចារ្យ ព្រមទាំងសិស្សានុសិស្សទាំងឡាយទះដៃអបអរជាច្រើនលើក ។

# និងសង្គមបច្ចុប្បន្ន

វីរិយបណ្ឌិតោ (ប៉ាង-ខាត់)

គ—ចប់

បើឥតពីព្រះសង្ឃហើយ ព្រះធម៌គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលនាំឲ្យយើងស្គាល់ខុសត្រូវ ល្អអាក្រក់ ស្គាល់គុណទោស ស្គាល់ផ្លូវទៅរកសិវិដ្ឋានក៏សាបសូន្យទៅដែរ យើងមានតែភ្លើងលោភៈ ទោសៈ មោហៈ មកដឹកនាំចិត្តយើង យើងមានតែកិលេសគ្រប់គ្រងចិត្ត កើតទៅជាកិលេសគ្រប់គ្រងលោក កាលបើកិលេសគ្រប់គ្រងលោកហើយ លោកនេះនឹងទៅជាភ្លើងប្រល័យកល្បឆេះមិនខាន ព្រោះយើងមិនមានព្រះធម៌ គឺព្រះធម៌ដែលដឹកនាំចិត្តយើង ឬមិនមានព្រះធម៌ដែលគ្រប់គ្រងលោក ទុកដូចជាគ្មានទឹកអម្រឹតជួយរំលត់ភ្លើងនោះ ។

ហេតុនេះការទំនុកបម្រុងបច្ច័យ៤ចំពោះព្រះសង្ឃដើម្បីឲ្យព្រះសង្ឃរស់នៅបាន ជាកិច្ចមួយប្រសើរណាស់ ឈ្មោះថា យើងជួយមនុស្សលោកទាំងឲ្យលោករស់នៅក្នុងសន្តិភាព ដោយទ្រព្យបត្តិបត្តិរបស់យើង ។ ទ្រព្យក្នុងទីនេះមាន២ប្រការ គឺទ្រព្យខាងក្រៅ១ ទ្រព្យខាងក្នុង១ ។

ទ្រព្យខាងក្រៅ ចែកជា២ប្រការ គឺទ្រព្យចំពោះ១ ទ្រព្យមិនចំពោះ១, ឯទ្រព្យខាងក្នុងក៏ចែកជា ២ ប្រការដែរ គឺ អត្តសមទ្រព្យ១ អនុគាមិកទ្រព្យ១ ។

ទ្រព្យបំពោះ៖– ទ្រព្យណាសម្រាប់លៀងជីវិតឲ្យប្រព្រឹត្តទៅ ដូចគ្រឿងស្លៀកពាក់អាហារ ទីដេកនៅ ថ្នាំកែរោគ ទ្រព្យនោះឈ្មោះថា ទ្រព្យបំពោះ ជាទ្រព្យចាំបាច់ខ្វះខានពុំបាន ។

ទ្រព្យមិនបំពោះ៖– ទ្រព្យណាដែលគ្រាន់តែជាគ្រឿងឧបករណ៍តែលោកនិយមថាជាទ្រព្យមានតម្លៃវិសេសវិសាលបំផុត ដូចមាស ប្រាក់ពេជ្រ និលរ័ត្ន ទ្រព្យនេះលោកឲ្យឈ្មោះថាជា ទ្រព្យមិនបំពោះ ព្រោះទ្រព្យទាំងអស់នេះ មិនអាចបំបាត់ទុក្ខវេទនាដែលកើតពីស្រេកឃ្លានបានទេ យើងវៀរលែងខានក៏បានដែរ មិនមែនជាគ្រឿងចាំបាច់លៀងជីវិត មានក៏មិនធាត់អត់ក៏មិនស្គមដែរ ។

ទ្រព្យដោយបំពោះនិងទ្រព្យមិនបំពោះទាំងពីរប្រការនេះ លោកឲ្យឈ្មោះថាជា ទ្រព្យខាងក្រៅ ព្រោះនៅខាងក្រៅពីខ្លួនយើង និងកើតមានបានដោយការស្វែងរកពីខាងក្រៅ មានបានមកប៉ុន្មាន ក៏ត្រូវអស់ទៅវិញដោយការចាយវាយខ្លះ ដោយអន្តរាយខ្លះ ដោយបាក់បែកខ្លះ ដោយហេតុផ្សេងៗខ្លះ បើទុកជារកបានមកច្រើនប៉ុន្មានក៏បានប្រើតែមួយជីវិត កាលណាយើងស្លាប់ទៅវិញទ្រព្យទាំងនោះក៏ធ្លាក់ទៅជារបស់អ្នកដទៃ ។ ទ្រព្យខាងក្រៅនេះ បើយើងចេះប្រើ ទើបទៅជាគុណ បើយើងមិនចេះប្រើ គឺប្រើក្នុងផ្លូវខុស ក៏ទៅជាទោសបំផ្លិចបំផ្លាញអ្នកម្ចាស់ទ្រព្យខ្លួនឯងវិញ ដូចចាយលេងប្រើស្រា បៀ ប៉ោ អាភៀន កញ្ឆា

ជាដើម ឬជួនកាលក៏អាចនាំអន្តរាយមកឲ្យខ្លួនវិញដូចចោរប្លន់កាប់សម្លាប់អ្នកម្ចាស់ទ្រព្យជាដើម ។

៦ ទ្រព្យខាងក្នុង បានដល់សេចក្ដីល្អ ហៅតាមវោហារពុទ្ធសាសនាថាអរិយទ្រព្យ ។ អរិយទ្រព្យនេះចែកជា២ប្រការគឺ អង្គសមទ្រព្យ ១ អនុគាមិកទ្រព្យ១ ។

អង្គសមទ្រព្យ.— ទ្រព្យដែលជាចំណែកមួយស្មើដោយរាងកាយ បានដល់ការចេះដឹងចំណេះវិជ្ជា សមត្ថភាពអធ្យាស្រ័យល្អ, សេចក្ដីល្អទាំងនេះ កាលបើយើងបានកសាងឲ្យកើតមានក្នុងខ្លួនយើងហើយ តែងជាប់នៅជាមួយនឹងខ្លួនយើងរហូតដល់ស្លាប់បាត់បង់ទៅវិញ អ្នកណាមកដណ្ដើមយកមិនបានកាត់ថ្លៃមិនបានមិនចេះរេចរិលអស់ទៅវិញ ប្រើប្រាស់ច្រើនឡើងក៏រឹងរឹតតែចំរើនច្រើនឡើង កាលរូបកាយបែកធ្លាយទៅវិញក៏រលត់ទៅមួយអន្លើដោយជីវិតដូចអវយវៈរាងកាយផ្សេងៗ របស់យើងដែរ ទ្រព្យនេះ ហៅថា អង្គសមទ្រព្យ ។

អនុគាមិកទ្រព្យ.— ទ្រព្យដែលជូនយើងទៅ គឺទ្រព្យណាមួយដែលយើងបានធ្វើឲ្យកើតមានក្នុងខ្លួនយើងហើយ ឲ្យផលមកដល់យើងក្នុងជាតិនេះនឹងជាតិតទៅមុខបើទុកជាយើងរលត់ខ្លួនទៅវិញ ក៏នៅតែជាប់តាមខ្លួនយើងទៅជួយឧបត្ថម្ភយើងឲ្យកើតក្នុងភពខាងមុខ បរិបូណ៌ដោយសេចក្ដីសុខចំរើនទៀតរឿយៗទៅ បានដល់គុណធម៌ប្រពៃដូចសទ្ធា សីល បញ្ញា នឹងកុសលកម្មផ្សេងៗទៀតជាដើម លោកហៅថា អនុគាមិកទ្រព្យ ។

អរិយទ្រព្យនេះ ជាទ្រព្យសម្បត្តិយើងពិតប្រាកដព្រោះជាប់ទៅជាមួយអ្នកធ្វើ ហើយនាំផលមកឲ្យអ្នកធ្វើនោះរឿយ ៗ ទៅមិនចេះវិនាសអន្តរាយបាត់បង់ទៅវិញទេ ចោរលួចយកមិនបាន មិនទៅជាប្រយោជន៍ជនដទៃ អ្នកណាដណ្តើមយកមិនបាន ហើយមានអំណាចជូនយើងទៅឲ្យកើតក្នុងភពតូចភពធំ បានសុខចំរើនថែមទៀត ។

មន្ទីរពេទ្យព្រះសង្ឃនេះទ្រទ្រង់នៅបាន ក៏ដោយការអាស្រ័យទ្រព្យទាំង ២ ប្រការ ដូចពោលមកហើយរបស់ពុទ្ធសាសនិកជនទាំងឡាយទាំងបព្វជិតទាំងគ្រហស្ថ ។ លោកសប្បុរសទាំងឡាយដែលបានបរិច្ចាគធនធានទំនុកបម្រុងមន្ទីរពេទ្យព្យាបាលព្រះសង្ឃនេះ ក៏ហាក់ដូចជាបានបំរើព្រះសម្មាសម្ពុទ្ធ សូមដូចពុទ្ធភាសិតថា:

យោ ភិក្ខវេ ឧបដ្ឋហេយ្យ, សោ គិលានំ ឧបដ្ឋហេយ្យ ប្រែថា "ម្នាលភិក្ខុទាំងឡាយ! អ្នកណាមួយគប្បីបំរើតថាគតយ៉ាងណា អ្នកនោះក៏គប្បីបំរើភិក្ខុឈឺយ៉ាងនោះដែរ" ។

ពុទ្ធភាសិតនេះ បានសេចក្តីថា បំរើភិក្ខុសាមណេរដែលមានរោគាពាធដោយការទំនុកបំរុងបច្ច័យទាំង ៤ ប្រការគឺ ចីវរបច្ច័យ បិណ្ឌបាតបច្ច័យ សេនាសនបច្ច័យ និងគិលានភេសជ្ជបច្ច័យ នឹងបានអានិសង្សប្រាកដដូចបំរើព្រះសម្មាសម្ពុទ្ធយ៉ាងនោះដែរ ។ ការបំពេញកុសលក្នុងថ្ងៃនេះ មានបំណងតែមួយគឺជួយឧបត្ថម្ភមន្ទីរពេទ្យព្យាបាលព្រះសង្ឃនេះឲ្យប្រព្រឹត្តទៅដោយប្រពៃ ដោយការអាស្រ័យទឹកចិត្តប្រកបដោយសទ្ធា មេត្តា ករុណា របស់លោកសប្បុរសទាំងឡាយ លោកសប្បុរសទាំង

ឡាយដែលបានបំពេញកុសលដ៏ប្រពៃ គឺបានលះបង់កម្លាំងកាយកម្លាំងចិត្ត កម្លាំងទ្រព្យ កសាងមន្ទីរពេទ្យព្រះសង្ឃនេះក្តី បរិច្ចាគធនធានទំនុកបំរុងបច្ច័យរៀងរាល់ថ្ងៃ រាល់ខែ រាល់ឆ្នាំក្តី ដល់មន្ទីរពេទ្យព្រះសង្ឃនេះក្តី ឈ្មោះថារួមសាមគ្គីធម៌បំពេញកុសលមួយដ៏ធំពិសេសពិសាល ជួយធ្វើការជាប្រយោជន៍បំបាត់ទុក្ខវេទនាព្រះសង្ឃដែលកើតពីរោគាពាធ ឈ្មោះថាឲ្យអាយុជីវិត ឲ្យអនាម័យគឺមិនមានរោគ ឲ្យពណ៌សម្បុរ ឲ្យកម្លាំង ឲ្យសេចក្តីសុខ ឲ្យសេចក្តីចំរើន ឲ្យព្រះនិព្វានដល់ភិក្ខុសាមណេរទាំងឡាយក្នុងពុទ្ធសាសនា ។ ភិក្ខុសាមណេរទាំងឡាយដែលបានទទួលសេចក្តីអនុគ្រោះពីលោកសប្បុរសទាំងឡាយ ហើយមិនមានទុក្ខវេទនា មិនមានរោគ សុខសប្បាយ មានរាងកាយមាំមួនមានកម្លាំង មានសុខភាពបរិបូណ៌ ជាឱកាសប្រពៃនឹងបំពេញព្រហ្មចរិយធម៌ រៀនសូត្រព្រះពុទ្ធវចនៈ ជាអ្នកចេះដឹងព្រះពុទ្ធវចនៈច្រើន យល់ច្បាស់នូវធម៌ព្រះសម្មាសម្ពុទ្ធ នឹងប្រតិបត្តិធម្មវិន័យឲ្យពេញបរិបូណ៌ដូចស័ង្ខដែលបុគ្គលខាត់ហើយ ដោយប្រពៃដូច្នោះឯង ហើយនឹងសាចព្រួសពូជសម្មាទិដ្ឋិឲ្យផ្សាយទូទៅដល់សត្វលោកទាំងមូល ឲ្យស្គាល់ខុសត្រូវ ស្គាល់ល្អអាក្រក់ ស្គាល់គុណទោស ស្គាល់ផ្លូវទៅកាន់ឋានសួគ៌ ឋាននិព្វាន កើតសេចក្តីសុខ ចំរើន កើតសន្តិភាពពេញសកលលោកដែលសត្វលោកប្រាថ្នាគ្រប់គ្នា ហេតុនេះហើយបានជាព្រះសម្មាសម្ពុទ្ធត្រាស់ទេសនាទុកថា អរោគ្យា បរមា លាភា "ការមិនមានរោគ ជាបរមលាភ" ។ អ្នកដែលបានឲ្យជីវិត ឲ្យអនាម័យ ឲ្យសេចក្តីសុខសេចក្តីចំរើនដល់ជនដទៃ ឈ្មោះថាបានឲ្យ

របស់ប្រសើរដ៏លើស ដែលជាកំពូលសេចក្ដីប្រាថ្នាតាំងតួនដល់ជនដទៃ ហើយនឹងត្រូវបានរបស់ប្រសើរលើសមកវិញ សមដូចពុទ្ធភាសិតថា

អគ្គទាយី វរទាយី សេដ្ឋទាយី ច យោ នរោ
ទីឃាយុ យសវា ហោតិ យត្ថ យត្ថុបបជ្ជតិ

"នរជនណាដែលឲ្យរបស់ដ៏លើស ឲ្យរបស់ដែលគួរប្រាថ្នា ឲ្យរបស់ដែលប្រសើរ នឹងត្រូវបានរបស់ប្រសើរវិញ គឺមានអាយុវែង មានយសបរិវារក្នុងភពដែលខ្លួនកើតហើយ" ។

អគ្គតោ វេ បសន្នានំ អគ្គំ ធម្មំ វិជានតំ
អគ្គេ ពុទ្ធេ បសន្នានំ ទក្ខិណេយ្យេ អនុត្តរេ
អគ្គេ ធម្មេ បសន្នានំ វិរាគូបសមេ សុខេ
អគ្គេ សង្ឃេ បសន្នានំ បុញ្ញក្ខេត្តេ អនុត្តរេ

"អ្នកចេះដឹងធម៌ដ៏ប្រសើរ តែងជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរពោលគឺជ្រះថ្លាក្នុងព្រះពុទ្ធជាបុគ្គលប្រសើរលើសលប់ ជាទក្ខិណេយ្យបុគ្គលមិនមានបុគ្គលណាប្រៀបបាន, ជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ជាធម៌រម្ងាប់បង់នូវរាគាទិកិលេស ជាធម៌ឲ្យសេចក្ដីសុខ, ជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាស្រែបុណ្យរកស្រែបុណ្យឯទៀតក្រៃលែងជាងគ្មាន" ។ អ្នកដែលបានឲ្យទានដ៏ប្រសើរដល់បុគ្គលប្រសើរប្រាកដដូច្នេះ តែងចំរើនដោយបុណ្យដ៏ប្រសើរផង ដោយអាយុដ៏ប្រសើរផង ដោយសម្បុរកាយដ៏ប្រសើរផង ដោយកេរ្តិ៍ឈ្មោះដ៏ប្រសើរផង ដោយសេចក្ដីសុខដ៏ប្រសើរផង ដោយកម្លាំងកាយដ៏ប្រសើរផង ។ អ្នកដែលមានប្រាជ្ញា បានដម្កល់ខ្លួនក្នុង

ធម៌ប្រសើរហើយតែងឲ្យបានដល់បុគ្គលប្រសើរយ៉ាងនេះឯង ទោះទៅកើតជាតិណាៗ ជាមនុស្ស ឬជាទេវតា តែងបានទៅជាបុគ្គលប្រសើរហើយរីករាយសប្បាយក្នុងលោកខាងមុខឥតសង្ស័យឡើយ ។

អាត្មាភាពសំដែងធម៌ទេសនាអំពីគិលានុបដ្ឋានកថា ចែកជូនលោកសប្បុរសទាំងឡាយ ក៏ល្មមដល់កាលវេលា សន្មតថាចប់ដោយប្រការប៉ុណ្ណោះ ឯវំ ។

ឯតេន សច្ចវជ្ជេន សុវត្ថិ ហោតុ សព្វទា

អរោគិយ សុខញ្ចេវ កុសលញ្ច អនាមយំ

ដោយសច្ចវាចានេះ សូមសេចក្តីសួស្តី សេចក្តីសុខដែលកើតពីការមិនមានរោគ និងអនាម័យគឺការប្រាសចាករោគាពាធ សូមមានដល់លោកសប្បុរសទាំងឡាយឲ្យបានគ្រប់កាលទៅហោង ។

# ប្រស្នាលទ្ធិរាប់អានខ្មោចបិសាច

## ឃុនបណ្ឌុរក្ស ប៊ូ-ប៊ូ រៀបរៀង

(តចប់)

ជនជាតិចិន – លោក ឡៅ-ស៊ឺ ជាអ្នកប្រាជ្ញជាតិចិន កើតមុនលោកអ្នកប្រាជ្ញ ខុង-ជឺ ៥៣ ឆ្នាំ គឺមុន ព.ស. ៦១ ឆ្នាំ ។ លោកឡៅ-ស៊ឺ បានបង្កើតលទ្ធិ តៅ អ៊ីស្ម៍ ។ លទ្ធិនេះជឿប្រកាន់ថា "មានព្រះជាធំបំផុតនៅឯស្ថានសួគ៌ មនុស្សត្រូវតែធ្វើពិធីបន់ស្រន់បួងសួងអង្វរករទើបព្រះជាម្ចាស់ទ្រង់ប្រោសប្រាណ" ។ បំណោតមក លទ្ធិតៅ-អ៊ីស្ម៍នេះក្លាយទៅជាលទ្ធិរាប់អានខ្មោចបិសាចទេវតាអ្នកតា ដែលពួកចិនជាប់រាប់អានតរហូតមកដល់សព្វថ្ងៃនេះ ។

មានអ្នកប្រាជ្ញសំខាន់របស់ជាតិចិនម្នាក់ទៀតឈ្មោះ ខុង-ជឺ កើតក្រោយលោក ឡៅ-ស៊ឺ ៥៣ ឆ្នាំ គឺមុន ព.ស. ៨ ឆ្នាំ ។ លោក ខុង-ជឺ ជាមេលទ្ធិមួយហៅថា លទ្ធិខុង-ជឺ ។ នេះ ទូន្មានប្រជាជនចិនថា "ចូរអ្នករាល់គ្នា គោរពរាប់អានខ្មោចបិសាច ប៉ុន្តែត្រូវនៅឲ្យឆ្ងាយពីខ្មោច" ។ ឱវាទរបស់លោក ខុង-ជឺ នេះ មានតទៅទៀតថា "ខ្មោចអាចសំដែងឫទ្ធិបាដិហារ្យដែលមាននៅក្នុងខ្លួនបានជាច្រើនប្រការពិតមែន ប៉ុន្តែ យើងមើលខ្លួនខ្មោចមិនឃើញ ស្ដាប់សំឡេងខ្មោចមិនឮ, សូម្បីយើងមើលខ្មោចមិនឃើញ ស្ដាប់សំឡេងខ្មោចមិនឮដូច្នេះ ខ្មោចក៏ចេះតែចូលជ្រៀតជ្រែកនៅក្នុងវត្ថុគ្រប់យ៉ាង របស់ដែលប្រាសចាកខ្មោចនោះគ្មានសោះ, ខ្មោចជាហេតុនាំឲ្យប្រជាជនក្នុងអាណាចក្រត្រូវកាន់សីល

ទីធ្លាធំជម្រះមន្ទិលសៅហ្មង ប្រជាជនត្រូវស្លៀកពាក់សំពត់អាវយ៉ាងល្អដើម្បីធ្វើកិច្ចគោរពបូជា, ហេតុនោះ ខ្មោចប្រៀបដូចក្រសែទឹកហូរ ហាក់ដូចជាមានខ្មោចនៅតាំងខាងលើផ្ទៃអាកាស នៅខាងត្បូងខាងស្តាំរបស់អ្នកធ្វើកិច្ចគោរពបូជា សូម្បីនៅបាតស្ទឹងទន្លេសមុទ្រក៏មានខ្មោចដែរ" ។ ប្រជាជនជាតិចិនជាប់ពាក់អានខ្មោចបិសាចតាមលទ្ធិ ខុង-ជឺនេះរៀងមក ។

ជនជាតិជប៉ុន— ជាតិជប៉ុនសម័យបុរាណកាន់លទ្ធិសាសនាជិនតោ ។ លទ្ធិសាសនានេះជាដើមកំណើតរបស់ជនជាតិជប៉ុន តាំងកកើតឡើងក្នុងប្រទេសជប៉ុនតែម្តង ។ លោកសាស្តាជិនតោបានប្រៀនប្រដៅប្រជាជនជប៉ុនថា " មនុស្សយើងកាលស្លាប់ទៅហើយ ទុកដូចជាផ្លាស់រូបកាយថ្មី ឬទុកដូចជាផ្លាស់គ្រឿងសំលៀកបំពាក់ជាថ្មីប៉ុណ្ណោះ, ឯវិញ្ញាណមិនមែនសាបសូន្យបាត់ទៅតាមទេ តែងគង់នៅចាំថែរក្សាគ្រួសារជាប់ជានិច្ច ព្រោះវិញ្ញាណជារបស់មិនចេះសាបសូន្យបាត់ទៅណា" ។ ក្រៅពីនេះ លោកសាស្តាជិនតោបានប្រៀនប្រដៅប្រជាជនជប៉ុនឲ្យគោរពពាក់អានបូជាបុព្វបុរសរបស់ខ្លួន ។

លទ្ធិពាក់អានខ្មោចបិសាចរបស់មនុស្សបុរាណដូចបានរាប់ឈ្មោះមកហើយដោយសង្ខេបនេះ ដើម្បីនឹងបង្ហាញឲ្យឃើញថា ការពាក់អានខ្មោចបិសាចនោះ មិនមែនទើបកើតមានក្នុងសម័យថ្មី ៗ នេះទេ គឺធ្លាប់កើតមានជាប់តៗគ្នាតាំងពីបុរាណកាលរហូតជាងពាន់ឆ្នាំមកហើយ ។ ចំណែកមនុស្សជាតិដទៃទៀតដែលមិនបានបញ្ចេញឈ្មោះ ឬមិនបានដំណាល

លទ្ធិរបស់គេគន់ទីនេះផង គឺមានលទ្ធិកប់សានខ្មោចបិសាចដូចជាមនុស្សបុរាណដែលបានបញ្ចេញឈ្មោះមកហើយនោះដែរ ប្លែកតែត្រង់តិចច្រើនឬផ្សេងគ្នាប៉ុណ្ណោះ ។

ស.- អ្វីហៅថា សព?

ច. រូបមនុស្សស្លាប់ថ្មីៗ ហៅថា "សព" ត្រូវអានថា "សប់" ព្រោះពាក្យនេះជាភាសាបាលី-សំស្រ្កឹត ប្រែថា "ខ្មោចស្រស់, រូបបុគ្គលស្លាប់, សាកខ្មោច ឬ សាកសព" ត្រូវនឹងពាក្យខ្មែរសាមញ្ញថា "ខ្មោច" ប្រើជាពាក្យខ្ពស់ថា "សព" ប្រើជាកដសព្ទថា "ព្រះសព" ឬ ព្រះបរមសព" ។

ស.- ចុះមនុស្សគ្រប់ជាតិ មានវិធីធ្វើបុណ្យសពដូចគ្នាតែម្យ៉ាងឬ ឬក៏ធ្វើប្លែកគ្នាដែរ ?

ច. មានវិធីធ្វើបុណ្យសពប្លែកៗគ្នាជាច្រើនយ៉ាងណាស់ ធ្វើទៅតាមលទ្ធិទំនៀមទម្លាប់របស់ខ្លួន ទីនរៀបរាប់ឲ្យសព្វគ្រប់មិនបានទេ ប៉ុន្តែ បើសំដៅយកគោលធំបំផុតគន់វិធីចាត់ការសពនោះ មានគោលតែត្រឹមៗ យ៉ាងគឺ វិធីកប់សព១, ដុតសព១, មិនកប់មិនដុតសព១ ។

## ការកប់សព

ស.- ចុះមនុស្សជាតិណាខ្លះ ធ្វើវិធីកប់សព ?

ច.-មានមនុស្សច្រើនជាតិច្រើនភាសា ប្រាប់ឈ្មោះមិនគ្រប់ទេ សូមប្រាប់តែអំពីជនជាតិអេស៊ីប្តិមួយ, ខ្ញុំបានដឹងដោយសារសង្កេតមើលប្បវត្តិសាស្រ្តសាកល ឃើញថា ជនជាតិអេស៊ីប្តិធ្វើវិធីកប់សពតាមលទ្ធិជឿ

ប្រកាន់របស់ខ្លួនថា វិញ្ញាណមិនចេះស្លាប់ ៗ ទីសម្រាប់ដម្កល់សព គេធ្វើជា
អនុស្សាវរីយ៍យ៉ាងខ្ជាប់ខ្ជួនណាស់ ហើយប្រុងប្រយ័ត្នមិនឲ្យពួកចោរឬ
មានការមើលងាយដល់សពឬដល់ទីកន្លែងទុកសពផង ៗ នៅទីដម្កល់
សពនោះ គេធ្វើបន្ទប់ងងឹត ៗ សម្រាប់ជាលំនៅរបស់វិញ្ញាណ ទីងជាទី
ទុកសពផង ៗ ក្នុងបន្ទប់នេះ គេបានចាត់ដាក់លំគ្រឿងប្រដាប់ផ្ទះទីង
អាហារហើយបានសាងរូបរបស់សពទុកនៅក្បែរខាងផង ៗ ទីកន្លែង
កប់សព គេធ្វើឆ្ងាយពីទន្លេនិល មិនឲ្យមានទឹកជោរជន់លិចទៅដល់
ជាទីហែងស្ងួតមិនសើម ដើម្បីទុកសពឲ្យបានយូរអង្វែងឆ្នាំ ៗ

នៅក្នុងស្រុកអេស៊ីបទីមួយ ៗ មានអ្នកចិញ្ចឹមជីវិតដោយវិធីអប់សព
ដោយគ្រឿងក្រអូបសម្រាប់ទុកឲ្យបានយូរ កាលញាតិរបស់សពទៅ
និយាយជួលឲ្យគេធ្វើ ហើយប្រគល់សពឲ្យទៅគេហើយ គេក៏ចាប់យក
ឈើលាបថ្នាំចេញមកឲ្យមើល ហើយគេសួរថា អ្នកត្រូវការបែបណា? រូប
ឈើនេះមាន ៣ យ៉ាង តម្លៃផ្សេងៗគ្នា ដែលមានតម្លៃច្រើនជាងគេនោះ
គេធ្វើជារូបដំណាងព្រះអូស៊ីរីស ៗ កាលញាតិរបស់សពនិយាយថ្លៃ
ស្រេចហើយ ក៏ត្រឡប់មកផ្ទះវិញ ៗ ឯពួកអ្នកអប់សពក៏ធ្វើការនៅផ្ទះ
របស់ខ្លួន ៗ សម្រាប់វិធីអប់សពយ៉ាងល្អលេខមួយនោះ មុនដំបូងគេ
ខ្ទះយកខួរក្បាលចេញដោយសឹកដែកទំពក់ទៅតាមរន្ធច្រមុះ ហើយលាង
ដោយបាញ់ទឹកបញ្ចូលទៅក្នុងក្បាល ហើយចោះផ្ទៃជំនីតាញយកពោះ
វៀនចេញមកលាងដោយស្រាត្នោត ប្រលប់ដោយគ្រឿងក្រអូប ដែល
កិនខ្ទេចជាផង់ ទើបគេញាត់ចូលទៅវិញជាមួយនឹងថ្នាំដែលធ្វើពីជ័រ

ឈើក្រអូបទឹងគ្រឿងក្រអូបឯទៀតៗ ហើយដេរភ្ជិតទៅវិញ ទើបគេយកស្បូកមកដាក់សពត្រាំក្នុងថ្នាំអំបិលម្យ៉ាងចំនួន ៦០ ថ្ងៃ ។

កាលគ្រប់កំណត់ ៦០ ថ្ងៃហើយ រាងកាយនោះក៏ស្ងួតក្រៀមទៅ នៅសល់តែស្បែកដណ្តប់ឆ្អឹង ទើបគេយកសំពត់តូចៗជ្រលក់ជ័រ ហើយរុំដោយសំពត់ដទៃទៀតជា ៣ ជាន់ ទើបយកសំពត់ជាតិរុំ ១ ជាន់ទៀត ។ កាលគេរៀបចំស្រេចហើយ គេយកសពនោះដាក់ក្នុងមឈូសដែលធ្វើដោយឈើជាពីរជាន់ ហើយមានលក្ខណៈប្រហែលនឹងរូបមនុស្ស នៅចំណែកខាងក្បាលនោះ គេឆ្លាក់ជារូបមុខរបស់សពនោះឯង ។ ការធ្វើវិធីបែបនេះ ជាហេតុរក្សាសពទុកឲ្យបានយូរអង្វែងជាវេលាច្រើនពាន់ឆ្នាំ ក្នុងវេលានេះមានសពសល់នៅជាចំនួនច្រើន ។

## ការដុតសព

មានជនជាតិជាច្រើនជាតិធ្វើពិធីដុតសព ។ ក្នុងគតិនេះ ស្រុកខ្មែរចំពោះតែពួកជាតិ ហៀមួយប៉ុណ្ណោះ [illegible] មិនកប់សព ។ គេធ្វើបុណ្យដុតសពវិញ ព្រោះគេប្រកាន់ជឿថា ការដុតសពនឹងធ្វើឲ្យវិញ្ញាណរបស់អ្នកស្លាប់នោះឲ្យស្អាតហ្មតចត់ ហើយវិញ្ញាណនឹងអណ្តែតតាមអណ្តាតភ្លើងឡើងទៅឯស្ថានសួគ៌ ។ សម្បូគ្រឿងសំណែនរបស់វិញ្ញាណនោះ លុះធ្វើពិធីស្រេចហើយ គេក៏ចាត់ការដុតភ្លើងដូចគ្នានៅវេលានោះដែរ ព្រោះគេជឿប្រកាន់ថា ភ្លើងជាទូតរបស់ស្ថានសួគ៌ដែលមានប្រចាំនៅនាស្ថានមនុស្ស ។ ចំណែកឆ្អឹងរបស់អ្នកស្លាប់នោះ គេរើសយកមកបញ្ចុះទុកក្នុងទីដ៏សមគួរ ( ចេតីយ ) ។

# ការមិនកប់មិនដុតសព

ជនជាតិប៉ឺរ្ស៍ ជាពួកអរិយ៉េន មិនកប់មិនដុតសពទេ ព្រោះគេជឿប្រកាន់ថា សពរបស់មនុស្សមិនត្រូវដុតភ្លើង ឬកប់ក្នុងដី ឬបណ្តែតចោលក្នុងទឹកស្ទឹងទន្លេសមុទ្រទេ ព្រោះជាការធ្វើទឹកដីនឹងភ្លើងឲ្យសៅហ្មងស្មោគគ្រោក ដែលចាត់ជាជាបាបយ៉ាងធំក្រៃលែង ទើបគេធ្វើវិធីមួយឲ្យផុតពីបាប គឺគេនាំយកសពទៅទុកចោលក្នុងព្រៃឲ្យត្មាតស៊ី ។ វិធីនេះសាយភាយចូលមកប្រទេសឥណ្ឌៀខ្លះដែរ នៅមានធ្វើជាប់តមករហូតដល់សព្វថ្ងៃនេះ ដូចជានៅប្រទេសបុមបៃ ។

រឿងសពនេះ រួមសេចក្តីថា ជាតិមនុស្សផ្សេងៗ ក្នុងលោកមានវិធីធ្វើសព៣យ៉ាងគឺ កប់សព១, ដុតសព១, មិនកប់មិនដុតសពទេ គេយកសពទៅចោលក្នុងព្រៃឲ្យសត្វស៊ី១ ។ ឯរបៀបចាត់ការធ្វើបុណ្យសពនោះ មានវិធីប្លែកៗពីគ្នាជាច្រើនប្រការទៅទៀត តាមលទ្ធិទំនៀមទម្លាប់របស់ជាតិជននោះៗ នឹងរៀបរាប់ឲ្យសព្វគ្រប់ក្នុងទីនេះមិនបានទេ ។

រឿងលទ្ធិកប់អានខ្មោចបិសាចសង្ខេបប៉ុណ្ណោះ ។

# ផ្នែកអក្សរសាស្ត្រ

## ភាសិតខ្មែរ

លោក ទៀង_តៃឈុន ក្រុមការដើមខ្សែលេខ១

ប្រមូលរៀបរៀង

---

១- ការែកគេស៊ីក្រោមក្អែក ការែកមិនដឹងខ្លួន ។

២- កុំទុកចិត្តមេឃ, កុំទុកចិត្តផ្កាយ, កុំទុកចិត្តកូនថាគ្មានសហាយ, កុំទុកចិត្តម្ដាយថាគ្មានបំណុល ។

៣ ស៊ូវស្លាប់ប៉ា កុំឲ្យតែស្លាប់មេ, ស៊ូវលិចទូកកណ្ដាលទន្លេ កុំឲ្យតែភ្លើងឆេះផ្ទះ ។

៤- គោកាវស៊ីកៃមាត់ត្រដោក ខ្អែគងពោះក្របី ។

៥- ផគជំពោះហៅជម្ងឺ, ជំចុះមិនឈឺយកឈើចាក់ ។

៦- គយដេក ជាស់គយឲ្យអង្ករ ។

៧ រទេះបាក់មិនគិត ទៅគឹតតែគោលុបដាំង (លិង្គ) ។

៨- សាច់មិនបានស៊ី យកឆ្អឹងព្យួរក ។

៩- ម្នោៗ ទៅយកដីរក្អាត្បៀតឈ្មៀក ។

១០- ម្នោៗ យកស្ករទៅផ្ញើស្រមោច ។

១១- ផគមិនផគយកកលអន្ទាក់ ។

១២- កំប្រុកស៊ីផ្លែល្វា ចំពាក់ភតា ទៅផ្សូរឯក្តិតឈ្លួស ។

១៣- ផ្កែព្រុសមិនដែលខាំ, ផ្គរលាន់រអាំ មិនដែលភ្លៀង ។

១៤- ឆ្កែខាំឲ្យគេម្ចាស់, គោល្កើសឲ្យគេនាយ ។

១៥- បង្ហាញឲ្យគេអន្ទក់, ចង់ស្រណុកឲ្យនឿយពី(ក្មេង) ។

១៦- ចំណីច្រើនមុខច្រើនពិសា, កូនច្រើនបាច្រើនល្អ ។

១៧- គោលឿនសឹកក, ស្រីល្អសឹកគូថ ។

១៨ ប្រាជ្ញកាន់ប្រស្នា, មោសកាន់បន្ទា, កាន់ព្រៃ, ដំរីកាន់

រនាម, ត្រីកាន់ទឹក, តាហ៊ានកាន់សឹក, ប្រមឹកកាន់តែន ។

១៩- ចាស់កាន់ស្ទាប់, ពាលកាន់កាប់, ក្មេងកាន់យំ ។

២០- ទឹកហូរតាមប្រឡាយ, ទន្សាយបោលតាមប្រឡោះ ។

២១- មានប្រឡាយទើបទឹកហូរ ។

២២- ទំពក់ទៅទើបក្លៅជ្រុះ ។

២៣- ភ្លើងឆេះតែពីសំកម ។

២៤- ស្លឹកឈើជ្រុះមិនដែលឆ្ងាយពីគល់ ។

២៥- អ្នកយើងគន់គ្រោះតាមកសិ, ចៅក្រមកាត់ក្តីតាមពាក្យ ។

២៦- កើតជាជន្លេនទៅខ្លាចអីដី, ធ្វើជាមន្ត្រីទៅខ្លាចអីប្រាក់, ធ្វើ

ជាជាងថ្នាក់ទៅខ្លាចអីឈើ ។

២៧- ធ្វើជាគ្រូពេទ្យមិនលែងអកគ្រួសគ្រំ , ធ្វើជាចៅក្រមមិនលែង

និយាយហួស, ធ្វើជាអ្នកបួសមិនលែងត្រូវអាបត្តិ ។

២៨ កើតជាអ្នកចំបាំងមិនត្រូវភសឹក, កើតជាអ្នកប្រមឹកមិនត្រូវ

ភតែន ។

២៩- គោគេមិនឃ្លួត ឃ្លួតតែគោឯង ។

៣០- ចិញ្ចឹមមនុស្សឲ្យមើលចិត្ត, ចិញ្ចឹមសត្វឲ្យពិនិត្យមើលចង្កូម ។

៣១- និយាយក្តីឲ្យមើលមាត្រា, និយាយការឲ្យមើលទំនង ។

៣២- មនុស្សខ្លាំងទុកជារបង, មនុស្សកាចទុកជាខ្នង, មនុស្សកោង ទុកជាសម្រាស់, មនុស្សស្លូតណាស់ទុកជារបាំង ។

៣៣- បើម៉្យនឹងកាច ឲ្យគេកោត, បើម៉្យនឹងឆោត ឲ្យគេអាណិត ។

៣៤- ដឹងធ្វើយព្រោះដង កូនឆ្គងព្រោះមេបា ។

៣៥- ផ្លែក្រឡាបគង់មានបណ្តូល, មនុស្សរាំងមូលគង់មានចិត្ត ។

៣៦- អឹមជាងអៀម ស្ងៀមជាងស្រដី ។

៣៧- និយាយយប់ស្ងប់ព្រៃ និយាយថ្ងៃព្រៃមានត្រចៀក ។

៣៨- ពើសដៃ ផ្ទៃឆ្អែត ។

៣៩- ឃ្លានកុំអាលស៊ី ។

៤០- ដេកយប់កុំនិយាយនឹងស្រី ។

៤១- បង់ព្រះទៅសំពះឯបាយ៉ាប, បង់បញ្ចមហាប្រាសាទទៅនៅព្រៃស្មសាន, បង់ពាក្យសមណៈជីព្រាហ្មណ៍ទៅយកឯពាក្យពាល ។

៤២- បំណាច់នឹងបាបឲ្យឆ្អាបមាត់ ។

៤៣- លូកប្រហុកឲ្យកប់ក្លៀក ។

៤៤- ផល់កំពង់លង់ទូក ។

៤៥- ពងមាន់កុំផល់នឹងថ្ម ។

៤៦- កុំពាំមុខដីន កុំទទឹងមុខសឹក ។

៤៧- ស្តូឲ្យសាប, អត្តុយឲ្យតាប ប្រាជ្ញាឲ្យវៃ សំដីឲ្យទន់ ។

៤៨- កាប់បំពង់រង់ទឹកភ្លៀង ។

៤៩- ឮតែផ្គរ កុំអាលចាក់ទឹកបំពង់ចោល ។

៥០- ធ្វើស្រែឲ្យមើលស្មៅ, ទុកដាក់កូនចៅឲ្យមើលផៅសន្ដាន ។

៥១- ក្ដៅកេរែក ត្រជាក់ពេកល្ហូកទនដៃ ។

៥២- ពូជសិស្សគ្រូបី, ពូជស្រីប្ដីលែង, ពូជគោជ្រវលែង, ពូជឆ្កែបង់ម្ចាស់ ។

៥៣- ក្របីស្នែងកែក មនុស្សភ្នែកឯក(១) ក្រពើកំបុតកន្ទុយ ។

៥៤- ចូលស្ទឹងតាមបត់ ចូលទូកតាមកំពង់ ចូលស្រុកតាមប្រទេស ។

៥៥- ទូកបែកជាទូកតត់, ទូកកំបុតជាទូកង ។

៥៦- អំបែងបែក រកអំបែងណាដូច ។

៥៧- សាបមួយដៃ, ប្រៃមួយចប ។

៥៨- រួចបាត់ជាត្រីកស់, បានទាំងអស់ជារនូត ។

៥៩- ឃើញឈើពុក កុំអាលទម្លាក់ត្រពោកអង្គុយ ។

៦០- ហ៊ានស្បែកដាច់, ខ្លាចស្បែកស្វិត ។

៦១- អក់ៗពេញបំពង់, ផុងៗកន្ទះបែក ។

៦២- រនាបបាក់គ្រាន់ទីនជួស តែមាត់ហួសកំពប់ប្រាក់ ។

៦៣- ជំពប់ជើងគង់ពត់ កំពប់មាត់បង់ប្រាក់ ។

៦៤- ដីឥដ្ឋានៅក្រាក្រ សម្បុរល្អនៅខែកត្តិក ។

៦៥- មីសៗកិះឆ្នាំងបាយឆ្អុះ ។

---

១ ន័យថា មនុស្សស្រលៀងភ្នែក ។

៦៦- ហើសតែមាត់ ត្រគាកស្លាប់ស្ងួក ។

៦៧- មនុស្សកុំមើលងាយមនុស្ស ។

៦៨- ប្រហែសបាត់ ប្រយ័ត្នគង់ ។

៦៩- ច្រើនចេះរបេះក្បាច់ ។

៧០- អ្នកមានកុំអរ អ្នកក្រកុំថប់ ។

៧១- មានមិនដែលបីត, ក្រមិនដែលបីជាន់ ។

៧២- ឃ្លោកលិច អំបែងអណ្តែត ។

៧៣- ប្រាសពីដង្រែក ទៅប្អែកលើពូក ។

៧៤- ងើយស្កក ទុនដាក់គ្រាប់ ។

៧៥- ប្រាជ្ញចុះរណ្តៅ, ខ្លៅឡើងសួគ៌ ។

៧៦- ចង់ចេះឲ្យសម្លាប់អាចារ្យ, ចង់បានផ្លែផ្កាឲ្យយកកើនជុំគល ។

៧៧- សំដីសជាតិ, មារយាទសពូជ ។

៧៨- កក្តាញស្លាប់ព្រោះមាត់, ខ្វែកស្លាប់ព្រោះអាចម៍ ។

៧៩- ប្រើអន្ទង់ឲ្យបំហុងកក់ ។

៨០- ខឹងឲ្យអត់, ខ្សត់ឲ្យរក, ឲ្យច្រើនកុំយក, ខ្លាចឲ្យចូលជិត ។

៨១- គេខុសកុំអាលអរ, គេសាទរកុំអាលអួត ។

៨២- ធ្វើស្រែទាន់ក្តៅដី, ចង់ស្រីទាន់ក្តៅចិត្ត ។

៨៣- លេងក្មេងអាប់យស, លេងតស់ក៏ខាំដៃ, លេងចាស់ក៏ចង្រៃ ។

៨៤- ស្វាមិនបង់ចៀម, សៀមមិនបង់ក្បួន, យួនមិនបង់ពុក,
ខ្មែរស៊ីតម្រុត មិនបង់ចៃបូ ។

៨៥- អណ្តាតជាអាទិ៍កខ្លួន បង់ទ្រព្យធនផងពីព្រោះអណ្តាត ។

៨៦- សត្វដង្កែស្លាប់ដោយសារប្រើស ។

៨៧- ទៅហើយមានបុណ្យខ្លួនមានស័ក្តិ ទៅហើយអប្បល័ក្ខណ៍ ខ្លួនធ្លាក់អណ្តូង ។

៨៨- កាលឈឺចង់រស់ថាថ្វាយគោ ជារស់ជ្រើសយកពងមាន់មួយទៅថ្វាយ ។

៨៩-កាលឈឺធ្ងន់យកដីទៅបន់ដល់ជម្ងឺស្រន់យកពងមាន់ទៅថ្វាយ ។

៩០- កុំអរនឹងយស កុំជាខ្ទុកជៀតផ្ទះ ។

៩១- និពសកុំម្ទេញ, ខ្ទុកពេញកុំដង, ទឹកកុំទន្ទេញ, មិត្តកុំបណ្តេញ ស្អប់កុំព្យាបាទ ។

៩២- លួចគេធ្លាប់ដៃ ដេកថ្ងៃធ្លាប់ភ្នែក ។

៩៣- អ្នកចេះដប់មិនស្មើអ្នកប្រសប់មួយ ។

៩៤- ខ្លួនទាបកុំគោង, ដៃខ្លីកុំឈោង ប្រហ៊ុបុកភ្នំ ។

៩៥- កុំបោះសន្ទូចរំលងភ្នំ ។

៩៦- ដំរីសារស្លាប់ទៅយកចង្អេរបាំង ។

៩៧- អូសទូកកុំឲ្យឃើញដាន(១) ចាប់ត្រីបានកុំឲ្យល្អក់ទឹក ។

៩៨- ដំរីផុងព្រៃយុងដើមឈើ ។

៩៩- រទេះបាក់ត្រង់ណា ល្អិតស្មៅត្រង់ណោះ ។

-១០០ បញ្ជាប់ទឹកលោកសង្ឃ កុំខ្លាចកាន់ព្រះកេស ។

---

១ ន័យខ្លះថា អូសទូកកុំឲ្យល្អាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក ។

១០១– ដេកផ្ងារស្ដោះលើទ្រូងឯង ។

១០២– ធ្វើស្រែនឹងទឹក, ធ្វើសឹកនឹងបាយ ។

១០៣– ដឹងរន្ដោះបោះដឹងបណ្ដោយ ។

១០៤– ដឹងចាំងតាមសាប់ ប្រាប់កាត់តាមពាក្យ ។

១០៥– ប្រើទៅជាត្បូងចិញ្ចៀន ក្រវិចក្រវៀនជាមៀនកាំបិត ។

១០៦– គោស្គមថ្នមប្រើ ។

១០៧– បង្អៀតចិត្តនៅមិនបាន, បង្អៀតផ្ទះនៅបាន ។

១០៨– កុំក្ដិចសង្អារប្រជល់គ្នា ។

១០៩– ជាងទងស៊ីរងកំបែក, ជាងដែកហែកនឹងមាត់ ។

១១០– ភូតនៅហោរ, ហោរនៅជាង ។

១១១– ធ្វើស្រែមិនបាច់ភ្ជួរ រក្សាតែមួរស្រូវស៊ីមិនអស់ ។

១១២– មាន់ពងលើជង្រុកស្រូវ ។

១១៣– ទឹកបាក់ទៅទាប, ដីខ្ពស់កណ្ដៀរពូន ។

១១៤– គោមួយក៏យប់, គោដប់ក៏យប់ ។

១១៥– បង់បាយមិនមើលប្រាណ, ដាំចង្ក្រានមិនប្រមាណថ្នាំង ។

១១៦– បាយសង្ក្រាដទៅប្រមាទកន្ទួងធំ ។

១១៧– ត្នោតបាទប្រមាទត្នោតលៃ ។

១១៨– ប្រមាត់ដីអ្នកបង់ឡើងទ្រេង ។

១១៩– មានគំនិតឥតកំណើត ។

(មានត)

## សាវតារឆាផហ្វ៊ងជាតិ

# លោកអ៊ុំ.ប៉ី តែងជាកាព្យពាក្យ៧

(តចប់)

ទៅដេញអង់គ្លេសឲ្យស្ងប់ស្ងាត់ លើកពលកំចាត់ឲ្យវេទនា
ផ្ដល់ផ្ដាច់ដីវៀតកុំគិតរា ចាប់ចងយកជាឈ្លើយចំពាំង ៗ
ព្រះបាទសាវល័ទក្រាំពីរនោះ ព្រះពាក្យដូចផ្ទោះពីពេះខ្លាំង
តែពុំសូវជឿថាបេះប្រាំង ព្រោះគ្មានកម្លាំងដោយក្នុងកាយ ៗ
ស្ដេចទ្រង់បង្គាប់ជំនុំសង្ឃ សាកសួរនោមយ័ក្នុងៗបាយ
ពីសោធហោទនាងឲ្យដោះស្រាយ នូវគ្រប់បរិយាយផងនានា ៗ
តែនាងឆ្លើយឥតមានទាល់សោះ ឆ្លើយដោះប្រស្នាអាចគ្រប់ឃ្លា
ច្រើនលើកច្រើនផងជាច្រើនគ្រា ទើបព្រះពជាទ្រង់ជឿផង ៗ
ជឿជាក់ថានាងកាន់សាស្នា មែនមានប្រាជ្ញាថ្លាកន្ទង
ទើបប្រគល់ទ័ពឲ្យនួនល្អង ចំនួនមួយកងរពេចខ្ចី ៗ
ឲ្យនាងនាំទៅយកអាសា ក្រុងអ៊ីឡេអង់ណាតាមសេចក្ដី-
ប៉ុនប៉ងរបស់ត្នស្ត្រី ក្នុងគ្រានោះរៃកុំបីចាំ ៗ
កាលណោះអាយុនាងទើបបាន ប្រមាណជាដប់ប្រាំពីរឆ្នាំ
ប្រាជ្ញារៀនរៃស្រីគ្មានគម្ម ចិត្តចាំចងជាប់នឹងផែនដី ៗ
អស្ចារ្យក្នុងផ្លូវយុទ្ធសាស្ត្រ នាងគ្នាសប្រសប់សព្វសេចក្ដី
ឥតមានតក់ស្លុតខ្នុតភ័យ ប្រុងប្រៀបស្នាតើស្រីពុក ៗ

នៅថ្ងៃមួយនឹងប្រាំបួន ការវិលដែលខួបលើកទ័ពក្សា
កញ្ជ្រៀវហៀវហ៊ោសូរខ្ទរខ្ទារ កក្រើកពសុធាគ្រានោះឯង
ដោយព្រៃព្រឹក្សបក្សាស្ងាត់ ពលច្រើនប្រាក់កាត់កន្ទេង
កន្ទងចងផ្លូវតម្រូវស្ទង ពុំមានកោតក្រែងនាងថ្លៃនរិន្ទ្រ
មិនយូរប៉ុន្មានក៏បានដល់ ទីស្ថានមណ្ឌលក្រុងក្រពិត
ដែលពួកអង់គ្លេសគេមានរិទ្ធ ពន្ធដិតពីមុខអ្នកស្រុកព្រួយ
កាសឹកបន្ទាយកាយពលជាប់ ចំនួនជាងដប់ទ័ពជំនួយ
បំណូលចូលថ្នល់វិចិត្តមួយ ហ្វ្រ័នជាក៏មិនព្រួយប្រុងអាត្មា
ទើបនាងឆ័កក្មេកស្រែកប្រាប់ពល ឲ្យប្រុងទប់ទល់តបេស្ដា
កុំខ្លាចអំណាចសមោហា ដែលមានរិទ្ធិក្លាមិនប៉ុន្មាន
យើងមកយកជ័យឲ្យល្បីឈ្មោះ ចិត្តមូលចំពោះបូរីស្ថាន
អម្ចាស់ជីវិតជាដើមដាន ត្រូវយើងប្រឹងប្រាណឲ្យបានសុខ
ជីវិតត្រូវគិតរួមជាមួយ ស្លាប់រស់ត្រូវជួយគ្នាកុំធុក
កុំរញុញព្រាប់កាសន្ទុក្ខ ពេលនេះយើងលុកកុំទុកនៅ
គោលក្លាំងនាងលើកដៃយកជ័យ បំផ្លាយកាផនេយ្យបំបោលទៅ
កន្លងពេលវេលាគ្រាឥឡូវ បញ្ជ្រាបសត្រូវឲ្យខ្លាចម្ដង
បង្គាប់ឲ្យទ័ពវាយបន្ទាយ ឲ្យខ្ទេចរលាយយកមួយម្ដង
ឲ្យបានដូចចិត្តគំនិតប៉ង កុំឲ្យសៅហ្មងក្នុងចិន្ដា
ពលរេហ៍មានរិទ្ធិចិត្តអនេក វាយបែកបន្ទាយឆ្ងាយសីមា
ចាក់កាប់ចាប់ជាន់ផ្ដន់ដីវ៉ា តាមដោយប្រាជ្ញាហ្វ្រ័នជាតិថ្លៃ

អង់គ្លេសភ័យញ័ររត់ប្រសាច ចុះចាញ់អំណាចខ្លាចចបរណៃ
ខ្លះដុតទឹកក្តៅស្រែកអាឡ័យ អាណិតខ្លួនក្ស័យអាឡ័យខ្លាំង ៗ
លុះដេញទៅដល់បន្ទាយធំ អង់គ្លេសចូលផ្តុំប្រជុំប្រាំង
តយុទ្ធមកវិញពេញកម្លាំង ឯពលបារាំងចង់រួញក ៗ
ព្រោះបន្ទាយនោះខ្ពស់ហើយមាំ ពីបាក់ទៅទ្រាំទ្រវេទនា
ចូលពុំរួចសោះអស់វិជ្ជា នឿយណាយកល់គ្នាចង់ក្រោយ ៗ
ប៉ុន្តែនាងស្រែកខ្លាំងអនេក កុំឲ្យពលខ្មែរបែកបណ្តោយ
ទើបនាងប្រញាប់ប្រាប់អ្នកក្រោយ ហុចជណ្តើរឲ្យនាងយ៉ាងឆាប់ ៗ
រួចនាងលើកផ្អែកទៅជញ្ជាំង ឲ្យពលឡើងតាំងតំណាប់
លុកលុយប្រជុយចូលទៅកាប់ វាយចាក់សម្លាប់ឲ្យហិនហោច ៗ
ប៉ុន្តែអង់គ្លេសមិនមែនសៅ វាយកទឹកក្តៅមកចាក់ស្រោច
រលាករលាត់រលាយខ្លោច ស្លាប់ដូចស្រមោចស្រោចទឹកក្តៅ ៗ
នាងចំទៀនពលកុំឲ្យខ្លាច លុះដោយអំណាចគាប់ចិត្តនៅ
សង្រ្កសង្គុញព្រុញពីក្រៅ ឲ្យច្បាស់សះខ្ចាត់មុននេះណា ៗ
មិនយូរប៉ុន្មានក៏បានឆ្ងាយ ជញ្ជាំងបន្ទាយដោយចេស្តា
បារមីវីទ្ធដែលខ្លៀវក្លា ផ្តល់ផ្តាច់ដ៏កុំទុកនៅ ៗ
ខ្លះបាញ់ខ្លះបុកសំរុកទ្វារ ចូលជិតពិតគ្នាពាសពេញផ្លូវ
ខ្លះស្លាប់ខ្លះរស់ចំរុះនៅ បាក់ដៃជើងក្លៅត្រូវគ្រប់គ្នា ៗ
បណ្តាលលានព្រនឹ្ខរ វិស័យដូចផ្គរក្សេះសង្រ្គាព
កក្រើករំពើកកង្រ្កក ញាប់ញ័រពសុធាជាខ្លាំងក្រៃ ៗ

អង់គ្លេសឃើញនាងកងស្រឡះ    រួតរះផ្កាសព្រួញរំពេចខ្ចី
ដាក់ស្នាលើកត្រង់ដំរង់ស្រី    រួចស្រេចហើយខ្ចីកសកៃភ្លាម ៗ
ព្រួញក្តែតត្រូវផ្ងាប់មុតជាប់ស្នា    កញ្ញាឈឺអួលដួលចេញឈាម
អូយ! យ៉ាយ! ក្រហាយចាប់ចុកភ្លាម    រឹងថ្គាមនាងថ្ងូរហូរទឹកភ្នែក ៗ
ពួកទ័ពត្រឡប់មកមើលនាង    ជួយលើកជួយលាងហើយយំស្រែក
ថ្នាក់ថ្នមបមបីភ័យចំឡែក    ពាល់ភ្នាពរែកបែកចិត្តពីរ ៗ
ដោយគិតថានាងគ្មានបារមី    គ្មានវិជ្ជាអ្វីក្នុងឥន្ទ្រីយ
ចុះនេះជាត្រូវព្រួញមុតដល់ទី    ផ្តល់ផ្តាច់ជីវជាមិនខាន ៗ
ចំណែកប៉ែកខាងពួកអង់គ្លេស    លុះឃើញមាសមេត្រូវព្រួញប្រាណ
ត្រង់ស្នាដូច្នោះខុសលំអាន    គិតស្មានថានាងរំលាងខណ្ឌ ៗ
នាំគ្នាស្រែកហៅសូរអនេក    លាន់ឮស្មើរបែកសំរ៉ែកលាន់
បណ្ដាលឲ្យពួកបាំងក័ន្ត    កាំងភ័យស្មោស្ងន់គិតរួញព ៗ
បង់ថយត្រឡប់ទៅវិញខ្ចី    ឲ្យតែស្ត្រីម្នាក់អង្គា
ទៅច្បាំងពឹងផលទល់ទ័ពពាក់    តាមដោយវេទជន្មាស្រី ៗ
ដែលអ្នកថាមានឫទ្ធិចំហុក    ពូកែជើងឆុតផុតលោកិយ
ស្រាប់តែមកដួលដេកនៅដី    ភាំងក្អួចស្មារតីពុំដឹងខ្លួន ៗ

នាងឮសំរែកអង់គ្លេសច្បាប់    ខឹងណាស់ក្រោកឈរពេញសំខ្លួន
ហើយស្រែកដេញទ័ពសន្ធាប់ផ្ទួន    លាន់ឮក្រអួនរំពងព្រៃ ៗ
ឈាមដោរហូរចេញពេញសស្រាក់    ហៀកក្នាក់ដោតអាវនាងគ្មានភ័យ
គ្មានស្តុករន្ធត់ផុតស្មារតី    ដែលឡើងអាជានេយ្យស្រីប៉ូលច្បាំង ៗ

បង្គាប់ឲ្យទ័ពត្រឡប់ទៅ កុំខ្លាចសត្រូវនៅពពាំង
ចូលតប្រយុទ្ធឲ្យមុតខ្លាំង ឲ្យខ្លាចបាកំងប្រាំងនឹងចិត្ត ៗ
ពលចូលគគុកសំរុកក្លាម បាញ់ស្លាប់កាប់ឈាមពាសពេញពិត
ខ្លះបាក់ខ្លះជ្រេងរងកាំបិត ប្រកៀកប្រកិតប្រគងគ្នា ៗ
បាក់កាប់ត្រូវក្បាលកណ្ដាលខ្លួន ស្ទុះរត់ចូលផ្ទួនឲ្យមរណា
ពុំទាន់គេជាន់ជាប់ក្រពា ទាញផ្កាវមុកផ្ទើយបាក់ដើមទ្រូង ៗ
បាក់ជើងបាក់ដៃបែកឈាមប្រឡាល បាញ់សាច់ដាច់ក្បាលដួលសន្ធ្រាន
សួផ្ទផ្ទព្រួញអន្ទ្រញមោង បាញ់ផ្លូងឈាងបាប់ខែលមកឃាំងៗ
អូយ! អាយ! យ៉ូយ! យ៉ាយ! ស្រែប្រកាប់ លេចនោមលេចអាចម៍ទាំង
ដោយខ្លាំង
សេះទាត់ក្បាត់ស្នៀតធាក់ប្រវម៉ុំង ប៉ាសត្រូវជញ្ជាំងក័យស្ទាំងខ្លួន ៗ
មិនយូរប៉ុន្មានទ័ពបារាំងដាក់ ក៏យទ័ពបច្ចាមិត្តសំនួន
ចុះផ្តាំយបន្ទាយតាំងដប់ប្អូន អង់គ្រស់ជយខ្លួនរត់ចូលព្រៃ ៗ
បាប់តាំងពីពេលនោះរៀងទៅ ល្បីឈ្មោះនោមឆ្ងៅពេញបូរ
ប្រទេសបាកំងទាំងប្រុសស្រី សូប់ស្ងែងបារមីឥតម៉្ងឺស្នើ ៗ
ខ្លបខ្លាចអំណាចរ៉ឺខេបស្ដា ទើបជឿដាក់ជាទេវតាប្រើ
ហើយនាំគ្នាស្គាល់ថាគ្រាន់បើ ខ្លះទៀតសរសើរថាបងប្អូន ៗ
ខ្លះថាពួកមិត្តមកពីដើម ចិត្តល្មើមល្អណាស់ហៅគ្នាអូន
យាយមួយថាភេញហៅតែប្អូន តាថាក្មួយស្មូគ្យព្រោះយូរយារ ៗ

លុះយកក្រុងនោះបានស្រេចហោង ចិន្តានាងប៉ងនាំពល

ទៅអភិសេកគ្រងភព ក្រុងកុងដែលជាប្ដីថ្លៃ ៗ
ប៉ុន្តែស្ដេចពុំទាន់ជឿជាក់ ព្រះទ័យនៅស្អាក់ហាក់សង្ស័យ
ថាមានទេវតារក្សាថ្លៃ មានបុណ្យពេកក្រៃទិស្សយខ្ពស់ ៗ
លុះគ្រាតែនាងមានជំនះ ម្ដងទៀតឃើញឈ្នះច្បាស់ចំពោះ
ទៅលើនាយពលអង់គ្លេស់នោះ នាមឈ្មោះគាល់បូរស្វូរស្វប់ស្វែន ៗ
ទើបស្ដេចព្រមគ្រាប់តាមស្ត្រី ទៅក្រុងកុងដ៏យឥតបីក្រែង
គ្រងរាជសម្បត្តិក្សត្រតម្កើង បានសុខអន្លើងស្ដេចនិវត្ត ៗ
ដល់ថ្ងៃឆ្នាំបីខែសេចកម្មប្រើ នាងលើកទ័ពឈមដោយគីរ
រាយយកបន្ទាយមុខប៉ារីស៍, ហ៊ានហោចខ្ទេចខ្ទីទាំងពីរផង ៗ
កាលនោះនាងត្រូវរបួសខ្លាំង ចិន្តានាងកាំងក៏យកខ្ទង់
ដឹងច្បាស់ថាក៏ត្រូវសំណាងផង អស់ត្រឹមនេះហោងឥតសង្កា ៗ
សំឡេងដែលធ្លាប់បង្គាប់ឲ្យ ធ្វើអ្វីក៏ដោយថ្កុកមុខណា
ពួកពលសកលរាល់អាត្មា ឈប់ស្ដាប់រហារកញ្ញាស្រី ៗ
មានខ្លះក្រឡេះនិន្ទាថា កញ្ញាទ្រើសឃ្នងមិនគប្បី
មានចិត្តគិតក្បត់ស្ដេចផែនដី ដោយនៅសេចក្ដីអ្វីមួយ ៗ
ពួកទ័ពត្រឡប់ទៅក្រោយអស់ មិនជឿនាងសោះដែលឲ្យជួយ
គតាំងបញ្ជាំងទៀតកុំគិតព្រួយ ដល់ខ្លួននាងមួយដែលពិការ ៗ
សល់រានពុំបានយកប៉ារីស៍ នាងស្ដាយពេញទីស្រក់នេត្រា
យំសោកបោកខ្លួនខ្លួនខ្លោចផ្សា នឹកដល់រាស្ត្រាព្រេងអតីត ៗ

លុះចូលមកដល់ដើមឆ្នាំក្រោយ មួយពាន់បួនរយសាមសិបពិត
ព្ធដំណាំងជាពួកខ្មាំងគិត លើកគ្នាមកជិតចោមកន្ទ្វង ។
ព័ទ្ធលុកកុកពានបំពានក្រុង វាយយកខាងក្នុងក្រុងកំបែន
ឲ្យខូចល្អិតល្អោចខ្ទាចជាផ្សែង គ្រប់ទីកន្លែងមិនលែងដៃ ។
នាំលើកទ័ពមកយកកសា ក្រុងនោះទៀតណាទាំងយប់ថ្ងៃ
គ្មានទៀយគ្មានណាយប្តុស្តាយក្ស័យ ឲ្យគេក្រុងក្រៃប្រួបរកទុក្ខ ។
សេះនាងពៀនលន់ពន់អនេក តក់ស្រែកហែកផ្លូវទៅតែមុខ
ពលផងត្រសងតាមតគុក ដោយគៀនក្រឡុកក្រលៀតកំភ្ន ។
ក្រឡេះបញ្ចាប់ក្អកក្រឡេកទៅ បានឃើញពាលពៅកាលចោមជុំ
ពេមរតជិតខ្លួនទួនក្រុំ ហាក់ដូចសត្វឃ្មុំប្រជុំផ្កា ។
ពលតាមចូលតាំងច្បាំងសន្ទឹក ក្រាសក្រៃពន្លឹកក្នុងបព្វតា
ចាញ់ដៃថយពលចោលអាសា ដណ្តើមបារ៉ូនដាក់កុំបានទេ ។
គឺជាអកុសលអស់សំណាង សំណូមនាងសាងពីបុព្វ
បានជាបណ្តោយឲ្យមាសមេ ឆ្ងាយពីពលរេហ៍ដូច្នេះនៃ ។
ទន់ខ្លួនទន់ប្រាណរន្ធត់រល័ក្ខណ៍ របេះពៃធ្លាក់ពីអាជនេយ្យ
បណ្តោយឲ្យគេចាប់ចងស្រី តាមដោយសេចក្តីគេបំណាង ។
គេនាំទៅលក់ឲ្យអង់គ្លេស បានដំឡៃទ្វេពេកកន្ទ្វង
មួយម៉ឺនកាក់មាសសុទ្ធតែម្តង គ្មានប្រកែកផងនាងល្បងព្រេង ។
តាមផលទិស្ស័យពីអតីត នាងមិនភ័យភិតតក់វង្វេង
គ្មានវល់គំនិតគ្មានចំបែង នៅស្ងៀមមិនលេងលសំដី ៕

លាន់ឮដំណឹងដឹងសុះសាយ ល្បីឈ្មោះហួសឆ្ងាយក្នុងបុរី
ប្រទេសបារាំងតាំងប្រុសស្រី កើតមានសេចក្តីភ័យរន្ធត់ ។
ញ័រញាប់ចំប្រប់ត្រឡប់ថ្លើម ភាសូរស្រីឆ្មើមដង្ហើមផុត
ស្តាយកាយស្តាយខ្លួនទួនបរិសុទ្ធ ស្តាយពេកដេកស្តុកស្លាប់ភាសា ។
នាំគ្នាយំយែកស្រែកបន់ស្រន់ ដល់ព្រះអរហន្តបន់ទេវតា
សូមឲ្យនាងរួចរស់ជីវ៉ា វិលមកសីមាក្រុងក្សត្រ ។
ឈប់ស្តុះហើយថ្លែងពីអង់គ្លេស ទិញបានមាសមេនាំចេញផ្លាត់
ទៅក្រុងអ៊ីឡេអង់តម្រង់ស្កាត់ ពលអមចាំស្កាត់ខ្វាចបាត់ស្រី ។
ដាក់គៀបឃ្នាបខ្នោះមិនអស់ចិត្ត ប្រាក់ករុំតែតតប្រណី
ប្រានមុខប្រានក្រោយដោយសេចក្តី- ព្យាបាទស្តីឲ្យវេទនា ។
បង្អាប់បន្ទុះបញ្ឈោះផង បញ្ចៀនខ្លួនល្អងឲ្យគ្រាំគ្រា
ពេបជ្រាយលែបខាយលេងគ្រប់គ្នា ដោយដងមាគ៌ាត្រកាល័យ ។
រៀងរាប់ដរាបសំដៅត្រង់ ដល់ក្រុងអ៊ីឡេអង់ដែលយកស្រី
ទៅឃាំងឃាត់ឃុំជំនុំក្តី ថ្ងៃដប់ប្រាំបីខែដេសមប្រ៊ ។
មួយពាន់បួនរយសាមសិបដាក់ អង់គ្លេសចាប់ថ្នាក់ដាក់មិនថ្នម
ឃើញច្បាស់ខ្មៅសល្អក្រហាម លើកពលមកអមហើយចោទថា ។
កែងក្ងាយកាយខ្លួនខ្លួនជាស្រី មានបុណ្យបារមីល្បីអស្ចារ្យ
លើសលុបក្នុងភពគ្រប់សីមា ដោយមានទេវតារក្សានៅ ។
អំនួតអួតខុសខ្ពស់អំណាច ព្រោះមានបីសាចកាចកាស្រូវ
ខ្មោចព្រៃប៉ុលស៊ើស៊ីអ៊ះទៅ មិនត្រូវតាមផ្លូវពិតសត្យ ។

អង់គ្រស់ប្រាជ្ញប្រាយផ្សាយសេចក្ដី យ៉ាងផ្ដើមដើម្បីតែបំភ្លាត់
អ្នកស្រុកកុម្ភករបរវដ្ដ ឲ្យជឿប្រាកដសន្មតបាន ៗ
បន្ទោកបន្ទយបន្អាប់កេរ្តិ៍ រាល់គ្នាឯងគេក្នុងភូមិស្ថាន
កុំឲ្យគោរពគ្រប់រូបប្រាណ ជឿថាកល្យាណស្រីខ្មោចព្រៃ ៗ
បិសាចអារក្សអ្នកតាប្រើ បណ្ដាយឲ្យដើររកកូតស្ដី
ដូច្នេះមនុស្សម្នាទាំងប្រុសស្រី ត្រាកចិត្តទីទៃពីស្រីសួន ៗ
ពិនិត្យអង្កេតរកអង្គហេតុ ឥតមានអណ្ដាតឲ្យមាំមួន
លេបទោសកុំហុសខុសលើខ្លួន នឹមនួនចំនួនបួនខែផ្កាយ ៗ
ពុំដឹងជាប់ចោទជាបទណា បើករកមាត្រាមកអធិប្បាយ
ទៅយកទោសធ្ងន់ទម្ងន់កាយ ក្នុងបទក្ដីក្លាយកាន់សាស្នា ៗ
ពុំត្រឹមពុំត្រូវផ្លូវសុចរិត តាមដោយក្រមក្រិត្យគ្រូអាចារ្យ
មួយទៀតឆ្កៀតចោទថាកញ្ញា តែងតួអាត្មាជាបុរស ៗ
ខុសភេទជាស្រីពិន័យធ្ងន់ ផ្ដន្ទាឲ្យជនផងទាំងអស់
ឃើញស្មៀនក្រែងស្ទាបអំណាចស្រស់ ឥតមានសប្បុរសក្នុងដួងថៃ ៗ
នាងស្រក់នេត្រាទុក្ខក្ដួល ព្រមឆ្លើយទទួលទាំងអួលផ្ទៃ:
ខ្ញុំខុសហើយសូមលោកអភ័យ កុំចាប់ប្រល័យនៃជីវ៍ ៗ
ខ្ញុំព្រមទទួលប្រតិបត្តិ គោរពបញ្ញត្តិបទមាត្រា
ហើយសូមល័ក្ខខ័ណ្ឌខសព្យា ឈប់តែងអាត្មាជាប្រុសទៀត ៗ
គេយកនាងទៅបង្ខាំងទុក ឲ្យនៅក្នុងគុកតូចចង្អៀត
ដាក់សោក្រៅក្នុងបំរុងស្ងៀត ខ្លាចនាងសឹកសៀតទ្រៀតចេញបាន ៗ

បង្អត់ចំណីឲ្យជីសាប    តែងហៅធ្វើបាបផ្ចាញ់ផ្ចាលប្រាណ
ដាក់ខ្នោះមិនដោះឲ្យដើរបាន    អកុសលកល្យាណប្រាណវេទនា ។
កើតទុក្ខមុខក្រៀមស្ងៀមអនេក    ស្រក់តែទឹកភ្នែកផ្ទែកគ្មានគ្នា
អាសូរខ្លួនស្គមទ្រមពេក    តែម្នាក់អង្គាក់ព្រាត់ភ្លាត់ ។
ដល់យប់យូរបណ្ដាពន់ប្រមាណ    យាមមួយព្រួយប្រាណព្រោះវិបត្តិ
នាងដេកលង់លក់ស្រមុកស្ងាត់    ដូចកល់រូបសត្វបាត់ស្មារតី ។
ពេលនោះមានទាំងទេវ៣នាក់    លួចស្លៀកបំពាក់វល័ក្ខណ៍ស្រី
ជាប្រុសខុសគេទេហេតុជាថ្មី    ឲ្យឃើញសេចក្ដីស្រីក្នុងខ្លួន ។
គ្រាន់ជាសំអាងទៅក្រាបទូល    ស្ដេចជាកំពូលបណ្ដូលក្បួន
ឲ្យជាប់សេចក្ដីជាស្រីសួន    នៅតែតែងខ្លួនជាបុរស ។
ក្រោយមកយកនាងទៅជំនុំ    នៅចំណោមជំប្រជុំអស់
នាម៉ឺនកង្វៀមទ្រឹពស់    ដោយនៅជំពោះកន្ត្រកក្រោ ។
ជំនុំជំរះច្បាស់មួយថ្ងៃ    ពុំជាប់សង្ស័យក្រែងបទណា
ទើបប្រែយកព្រោះមួយអស្ចារ្យ    ហៅថាក្បត់សាស្នាចំហុក ។
គ្រវ៉ៃយកនាងទៅបង់បូជា    ឲ្យក្ស័យជន្មាទាំងរស់សុទ្ធ
ចងខ្សែហែហាមជួនទៅដុត    ទើបពេញបរិសុទ្ធក្នុងផ្លូវច្បាប់ ។
អនិច្ចា កញ្ញាហ្មុនដាក់    រងទុក្ខលំបាកយាកយុំយ៉ាប់
ដួលខ្លួនខ្ទួនក្រោកមកប្រញាប់    ដោយស្ដាយក្រែងស្លាប់ក្នុងអគ្គី ។
ហើយខំផ្ចង់ចិត្តគំនិតវង    ធ្វើយតបទៅវិងថានារី
សុខចិត្តទទួលទោសទាំងពីរ    ពុំស្ដាយជីវិតក្ស័យ ។

តាមផលនៃកម្មប្រចាំជាតិ សន្ដតត្រូវឃ្លាតតាមនិស្ស័យ
ព្រេងបុណ្យសំណាងកសាងថ្ងៃ គង់បានបច្ច័យទៅថ្ងៃមុខ ។
រូបនាងសំយុងក្បាលឈ្លោកជ័ ទឹកគុណកោសីប្រើមានទុក្ខ
ទោរទន់ជូនខ្លួនទួនមិនសុខ ចិន្ដាវិតក្កកក្កលខ្វាំង ។
នៅស្ងៀមក្រៀមក្រំក្នុងនុក៏ ឥតមានស្ដីថាឲ្យពួកខ្មាំង
ទំដូងវិញ្ញាណគ្មានកន្ទកាំង គ្មានភ័យភិតភាំងបាត់ស្មារតី ។
ពេលនោះពពួកនាយឃុំ នាំគ្នាចូលជុំចាប់ស្ដ្រី
ដាក់ខ្នោះដាក់ឃ្នាងនាំនាងខ្ចី ទៅគុកទុកស្រីដូចសព្វផង ។
រង់ចាំតែដល់ថ្ងៃធ្វើគត់ ទឹងនាំទៅជុតជុតជាម្ដង
ពិបាកកាក្យពេកកន្ទង ដោយខ្វាចទួនល្អងគេបួចព្រួយ ។
នៅថ្ងៃសាមសិបខែម៉ាក្រោយ មួយពាន់បួនរយសាមសិបមួយ
ជាថ្ងៃហ្វ្យ័ទជាកិផុតមនុស្សជួយ ស្រីស្រស់ជំទួយរលួយសុន ។
ពាហានកាន់គ្រឿសធ្វើពាទល្វាយ ព័ទ្ធទ្រោមទោមដាយចេញពីគុក
ឆ្នាំត្រដៀងថៃថែកកុង ឈមមុខទៅស្លុងក្រុងរូអង់ ។
ដែលពួកអាន់គ្លេសសង់ប៉ាឆា មួយនៅក្នុងផ្សារព្រាប៉ាបង់
បូជានារីតែងឯងអគ្គិ ទាំងរសនៅត្រង់កណ្ដាលផ្សា ។
មានរៀបគំនរគរអុសបាច់ បំរុងរូបស្រីបទុកនៅនា
មានតូបមានធំបង់រគា ទុកទឹងបូជាពុំងារស្រី ។
លុះបានដល់ទៅទីប៉ាឆា រូបស្រីបកាលណា នាងមិនភ័យ
ប្រុងចិត្តឥតស្លុតមានស្មារតី ខឹកគុណកោសីនៃទេវតា ។

តាមពាក្យសង្ឃរាជយេស៊ូម្នាក់ ហែដឹកវរល័ក្ខណ៍បញ្ជាក់ថា:

ឲ្យនាងប្រុងប្រៀបរៀបអាត្មា កុំគិតទៅណាការនាធម៌ ៗ

ឲ្យនាងផ្ទៀងស្តាប់ចាប់អារម្មណ៍ ព្រះធម៌ឧត្តមប្រណម្យល្អ

ឲ្យល្អិតចិត្តក្តួចផ្តួចរកធម៌ ទៅឯព្ធដព្រះយេស៊ូ ៗ

ថ្ងៃនពីអ្នកស្រុកភូមិជិតឆ្ងាយ ក្មេងចាស់តាំងឡាយមកស្កាត់ឈូ

សព្វប្រកល្ហកផ្លូវមិនទៅយូរ តាមមើលយេស៊ូឲ្យធម៌ស្រី ៗ

ខ្លះកើតសង្វេគទឹកភ្នែកហូរ អាណិតអាសូរក្នុងហឫទ័យ

ទំអត់សង្កត់មិនចេញស្តី ខ្លាចគេដឹងក្តីពិន័យខ្លួន ៗ

ខ្លះម្នាមោះម្នេញពេញអក័ព្វ នាំគ្នាត្រឡប់ទៅតាំងជួន

បើកភ្នែកក្រឡេកឃើញតែខ្លួន ពោះបីដើរពួនក៏ពុំបាត់ ៗ

ការនាធម៌ចប់សព្វគ្រប់ហើយ ទើបបានគ្រាណាត្រើយក្រោកប្រយ័ត្ន

បើកភ្នែកក្រឡេកឃើញប្រក័ត មនុស្សច្រើនពេកក្តាត់ពាសពេញផ្សារ ៗ

ងើយងើបមើលលើស្មើរដាច់ខ្យល់ សំឡឹងប្តឹងដល់ទៅទេវតា

ដាក់ភ្នែកក្រឡេកមកអាត្មា ហួសទៅបាធាឃើញអុសគរ ៗ

សំឡក់ភ្នែកធំពុំចេញស្តី ស្មើរថ្លាយផ្ទះដីហួសគំនរ

ទើបមានទឹកភ្នែកបែកហៀរមក ញាប់ញ័រខ្ទូរខ្ទូរជីវិន ៗ

នាងលើកដៃប្រណងទៅទេវតា ហើយថ្លែងវាចាដោយទាន់ហាន់:

ស្តាយស្រុកស្តាយភូមិដែលប្រែកន្ត ស្តាយពុំបានទាន់ជួយអាសា ៗ

រូគង់! រូគង់! មើលមុខខ្ញុំ ថ្ងៃក្រោយអ្នកកុំកើតទុក្ខា

ឲ្យប្រាស់ទាន់ខ្ញុំនៅជីក៏ បន្តិចអាត្មានឹងសូន្យហើយ ៗ

រូបនាងបណ្ដោយខ្សែគេចង ច្រើនជាន់ចំណងចងកៀកកើយ
កៀកគិតតែខ្លួនខ្លួនគ្រាណាត្រើយ រួចស្រេចបាច់ហើយលើកយកទៅ ៗ
ដោតចំកណ្ដាលគំនរអុស ក្រឡេកឃើញខ្ពស់ច្បាស់សន្ធៅ
សង្សារពជយេស៊ូបហូលទៅ បង្ហាញពាលពៅរូបព្រះអង្គ ៗ
ឲ្យនាងសំឡឹងពិចារណា កុំភ្លេចអាត្មាចិត្តាត្រង់
ទឹកគុណយេស៊ូគ្រូស្រោចស្រង់ នាងក៏ប្រុងផ្ចង់តម្រង់ខ្លួន ៗ
ការនាជានិច្ចមិនភ្លេចសោះ ទឹកគុណទាំងអស់ពេញសំនួន
សូត្រធម៌បរិសុទ្ធមិនស្ដុតខ្លួន តាមដោយនៅក្បួនដំបូនព្រះ ៗ
ភ្លើងកាន់តែឆេះៗ ខ្ពស់ឡើង អណ្ដាតផ្កាតប៉ុនហួសស្រឡះ
ដោយប្រេងទីងខ្យល់ផាត់ធាប់ណាស់ បំហាយទៅប៉ះដើងម្ដងៗ ៗ
បណ្ដាលស្រៀវប្រួញរួញកាយា ឈើផ្សាអួលណែនសែនសៅហ្មង
នាងរើមិនរួចព្រោះចំណង ទំទាំមាត់ផ្សេងតាមក់ស្មា ៗ
ផ្សែងដិតល្វិតមេឃក្រឡេកទៅ ពពកខ្មួលខ្មៅក្ដៅអស្ចារ្យ
ឃើញទេពបុត្រសុទ្ធទេវតា ឯអាកាសាមមាប្រថពី ៗ
មីស្សែល! មីស្សែល! នាងហៅឈ្មោះ សូមជួយសង្គ្រោះដល់អញ្ជលី
មីស្សែល! មីស្សែល! ជួយនារី ឲ្យចេញអំពីទីនេះទៅ ៗ
ចំណែកឯភ្លើងឆេះឡើងខ្លាំង ពេញនៅកម្លាំងភ្លើងសន្ធៅ
ខ្យល់បក់បោកអុសឆេះខ្ពស់ទៅ ដល់ខ្លួនជោមខ្មៅត្រូវចំហាយ ៗ
ក្ដៅពេកនាងស្រែកថ្ងូរល្ហើយៗ ថាឱលោកអើយភ្លើងដល់កាយ

ឆាបឆេះល្បះល្បាចខ្មោចក្រហាយ ហ៊ូយ! យ៉ាយ! យ៉ាយ! យ៉ាយ!
ក្តៅណាស់តើ ៗ
ក្រោយមកឮមាត់នាងប្អូនស្ងួន គុណបុណ្យទាំងពួងល្អប្រសើរ
ផល់ទៅទេវតាដែលបានប្រើ ឲ្យនាងមកស្មើធ្វើចំបាំង ៗ
នឹកគុណយេស៊ូគ្រូសាស្តា ជាប់នៅទុកមិនភ្លេចភ្លាំង
ដកបដាបផល់ខ្យល់កម្លាំង កួចខ្លាំងបាំងចាប់ស្លាប់ទៅហោង ៗ
ធ្វើគត់រំលត់ដុតហ្សុនជាតិ បំជាអស្ចារ្យកាចចំបង
ឃើញស្លាបខ្លាចស្មែរក្រែងកន្ទង ដុតទាំងរសផងដោយចង់ស្រី ៗ
អង់គ្លេសលុះឮនាងស្រែកហៅ ទេវតាក្នុងក្រៅផ្លូវហោះនៃ
ជឿពិតអាណិតអាសូរស្រី កើតមានសេចក្ដីភ័យអន្តរាយ ៗ
យំសោកបោកខ្លួនទាំងអស់គ្នា នាមុនប្រជារាស្ត្រជិតឆ្ងាយ
ពួកពលសកលផងទាំងឡាយ សោកស្តាយកាយស្រីហើយភ័យខ្លួនៗ
ថាយើងធ្វើទោសនោះពេញខុស ដុតស្រីទាំងរស់មិនសមសួន
ជាស្រីមានធម៌ល្អក្នុងខ្លួន ព្រហ្មវិហារទាំងបួនទួនកាន់ខ្ជាប់ ៗ
ដឹងខ្លួនថាខុសហួសទៅហើយ អង់គ្លេសមិនស្បើយដើរត្រឡប់
ទៅវិញពេញទុក្ខមុខអក់ឮ ដង្ហើមធុញថប់ចំប្រប់អើយ ៗ
ចប់ដោយសង្ខេបតែប៉ុណ្ណោះ

×

× ×

## ផលនៃការអានរឿងស្វ៊ែនជាក

សាវតារនៃកញ្ញា ហ្វ៊ែនជាក

បើលោកអ្នកបានអានៈ ហើយកើតខ្លោចផ្សា

ស្តាយនារីដែលជាទីពេញចិត្ត

យកកា សាជួយផែនដីនៃបាពិន ។

រួចពីស្តាយនាំឲ្យក្លាយចិត្តក្លាហាន

ហ៊ានលះប្រាណចូលតយុទ្ធនឹងពួកខ្មាំង

ដែលបង់មកយករដ្ឋយើងជាតា សាំង

ហ៊ានតតាំងស៊ូតែស្លាប់ដូចហ្វ៊ែនជាក ។

យកកា សានៃរដ្ឋា ហើយស្លាប់ខ្លួន

តាមក្នុងក្បួនសុភាសិតពិតជៀនជាក់ :

"រស់កុំគាប់ ងាប់កុំគួរ គួរគ្រប់លក្ខណ៍."

ជាតិទុកដាក់ផ្នែក "មហាបុរសរត្ន"

ជាតិធ្វើបុណ្យរំលឹកគុណខួបរាល់ឆ្នាំ

ជាប្រចាំដូចបារាំងធ្វើប្រាកដ

"បុណ្យហ្វ៊ែនជាក" ជាទំនៀមទៀមជាផ្ដត់

យើងគួរកត់យកតម្រាប់តាមទៅអើយ!

យូរ·អ៊ុន

រឿងទេវន្ត

ពាក្យកាព្យ

# លោកអម្ចាត់ក្សត្រ ម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម

# លោក ញ៉ុក ថែម ពិនិត្យ

## អារម្ភកថា

រឿងទេវន្តនេះ ជារឿងជាតកមួយ ក្នុងគម្ពីរបញ្ញាសជាតក ដែលអ្នកប្រាជ្ញបានរៀបរៀងទុកមកជាភាសាបាលី ក្នុងដែនសុវណ្ណភូមិ គឺជ្រោយទ្វីបអាស៊ី ដែលលយចេញពីតួទ្វីបទៅទិសខាងត្បូង ដែលជាទីតាំងប្រទេសទឹងប្រជាជាតិផ្សេង ៗ ជាច្រើន គឺយួន, ខ្មែរ, លាវ, ថៃ, ភូមា, ម៉ាឡាយូ តែគេមិនទាន់ដឹងប្រាកដថា គម្ពីរបញ្ញាសជាតកនេះ អ្នកប្រាជ្ញជាតិអ្វីបានតែងទុកមក ? ហើយបានតែងទុកមកក្នុងប្រទេសណា ជាដំបូង ? ក្នុងព្រះពុទ្ធសករាជប៉ុន្មាន ? ។

ប៉ុន្តែតាមយោបល់យល់ស្មានរបស់យើង ថាបណ្ដាគម្ពីរជាភាសាបាលី ដែលគេបានតែងឡើងជាន់ក្រោយ ៗ មក ច្រើនតែតែងនៅប្រទេសលាវ ថៃ និងភូមា; ចំពោះគម្ពីរបញ្ញាសជាតកបាលី ប្រហែលជាអ្នកប្រាជ្ញជាតិលាវ ស្រុកឆៀងហ្មៃ ដែលនៅក្នុងអាណាចក្រថៃសព្វថ្ងៃនេះ ដោយបានប្រមូលរឿងរ៉ាវចាស់ ៗ ក្នុងស្រុកឬពីប្រទេសក្រៅ; រៀបរៀងជាភាសាបាលីឡើងរវាងសតវត្សរ៍ទី ២០ នៃពុទ្ធសករាជ ហើយគម្ពីរនេះមានសាយភាយទៅពាសពេញក្នុងដែនសុវណ្ណភូមិ ដែលកាន់ព្រះពុទ្ធសាសនាលទ្ធិ

ហិនយាន, ក្រៅពីសុវណ្ណកូម៉ ហាក់ដូចជាមិនមានគេដឹងឮពីឈ្មោះគម្ពីរនេះឡើយ ។

ឯរឿងក៏ក្នុងគម្ពីរបញ្ញាសជាតក ដែលអ្នកប្រាជ្ញឬចិន្តកវីជាតិខ្មែរបានប្រែនិងរៀបរៀងជាភាសាខ្មែរនោះ មានច្រើនរឿង ជាពាក្យកាព្យក៏មាន ជាពាក្យរាយក៏មាន ដូចជា សមុទ្ទឃោសជាតក, សុធនជាតក, សុធនុជាតក, រតនបជ្ជោតជាតក និង សិរីវិបុលកិត្តិជាតក ជាដើម, ទាំង៥ ជាតកនេះ ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយហើយ សុទ្ធសឹងជាពាក្យរាយទាំងអស់, ឯជាពាក្យកាព្យនោះក៏មានច្រើនរឿង ដូចជារឿងព្រះសុធន, សព្វសិទ្ធិ, សុភមិត្រ, វនាវន, សុវណ្ណសង្ខ, វរវង្ស, សូរវង្ស, បុញ្ញសារៈសិរសា ជាដើម ។

ចំពោះរឿងទេវន្ទ ពាក្យកាព្យ ដែលរៀបរៀងជាភាសាខ្មែរនេះ ជាស្នាដៃរបស់លោក អម្រឹតក្សត្រី នាមដើម ម៉ុក កាលធ្វើជាមន្ត្រីក្នុងសម្តេចព្រះវររាជជននី នៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមព្រះសុ-វណ្ណកោដ្ឋ លោកបានប្រែរៀបរៀងជាពាក្យកាព្យកាលពីក្នុងពុទ្ធសករាជ ២៤០២ ដូចមានពាក្យប្តូមរបស់លោកនៅខាងដើមរឿងនេះស្រាប់ ។

ប្រហែលលោកម៉ុកនេះហើយ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញថា ជាកវីឯកមួយ ក្នុងរជ្ជព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម តែតាមពាក្យសាមញ្ញច្រើនហៅថា លោកសុន្ទរម៉ុក ប្រហែលជាក្រោយមកទៀត ទើបបានមកធ្វើជាចាងហ្វាងកិច្ចព្រះអាលក្ខ នៅក្នុងព្រះបរមរាជ-

ពីធ ក្រុងភ្នំពេញ ទើបបានទទួលព្រះរាជតាំងងារជាឧកញ៉ាសុន្ទរ
វោហារ ។

លោកម៉ុកនេះ មានសេចក្ដីដំណាលថាជាមនុស្សពិការដៃទាំងពីរផង គឺក្រញែនដៃសងខាង ទើបមានពាក្យដន្ទដន្ទេញលេង ដែលបាស់ៗ ចាំតៗ មកថា ម៉ែងក្រញ៉ុក ម៉ុកក្រញែង ប្រហែលជាប៉ុនត្រឹកកំផ្លែនផង ។ មានសេចក្ដីដំណាលថា ព្រះករុណាជាម្ចាស់ជីវិតទ្រង់ប្រោសប្រាណណាស់ តែងតាមហែហមទៅកាន់ទីជិតឆ្ងាយ, កាលណាទ្រង់ចង់ព្រះបណ្ដាប់ពាក្យកាព្យតែងទ្រង់មានព្រះបន្ទូល ឲ្យលោកសុន្ទរម៉ុកថ្លែងថ្វាយភ្លាម ៗ ឯពាក្យកាព្យរបស់លោកនោះ មិនបាច់គិតគូរកពាក្យប្ដូនយូរទេ គ្រាន់តែហាឡើង ក៏ចេញពាក្យកាព្យហូរទៅតែម្ដង ៗ មួយទៀត ព្រះករុណាជាម្ចាស់ជីវិតទ្រង់ស្និទ្ធស្នាលរាប់អានលោកជាច្រើន ទើបទ្រង់ត្រាស់ហៅថា ម៉ុក ៗ ម៉ែងក្រញ៉ុក ម៉ុកក្រញែង ដូច្នេះជារឿយៗ ។ ឯលោកសុន្ទរម៉ុក ក៏មានបដិភាណពន់ពេកល់ដល់ព្រះរាជគព្យាស្រ័យ ចេះផ្គាប់ឲ្យត្រូវតាមព្រះរាជបំណងគ្រប់គ្រា វេលាដែលទ្រង់ក្រសាលជាមួយទីន្ទូន ៗ ពាក្យកាព្យផ្សេងៗ ដែលព្រះករុណាត្រាស់ឲ្យលោកសុន្ទរ ម៉ុក ថ្លែងថ្វាយភ្លាម ៗ នោះ មានច្រើនរឿងច្រើនអន្លើ មានកន្លែងខ្លះមានគេចាំទុកតៗ មកដល់ឥឡូវនេះក៏មាន ដូចគ្រាមួយអស់អ្នកអស់នាងកំពុងចុះងូតទឹកក្នុងកំពង់ នៅឱកាសបុណ្យចុះដៃ ស្រាប់តែកំពត១ខាំក្ដៅអ្នកមេនាងម្នាក់ អ្នកមេនាងនោះស្រែកស្ទុះឡើងពីទឹកមក, ព្រះករុណាទ្រង់ជ្រាបរឿងនោះ ក៏មានព្រះបន្ទូលឲ្យសុន្ទរ ម៉ុក ថ្លែងពាក្យកាព្យថ្វាយឲ្យទ្រង់ព្រះសណ្ដាប់

មួយពេល ៗ លោកសន្ធរពេហារក៏ថ្លែងពាក្យកាព្យថ្វាយក្សាមថា :

– កំពតកំពង់ប៉ោះ ខាំបន្ទោះកន្ទៀតក្តៅ

នាងនាងស្រែកលោ្លៗ យកអំពៅព្រៃមកបិទ ៗ

គ្រាមួយ លោកអាត់ម៉កល . . . . មេទ័ពជើងទឹក បានរើសយក

បានចាត់ឲ្យបំរើនាំសត្វកែះពីរ ១ ឈ្មោល ១ ញី មកថ្វាយព្រះករុណាជា

ម្ចាស់ជីវិត ក្នុងព្រះបរមរាជវាំង ក្រុងភ្នំពេញ, ក្នុងខណៈនោះទ្រង់ទត-

ភ្លេកបង់ទ្រង់ព្រះសណ្តាប់ពាក្យកាព្យស្រស់របស់លោកសុន្ធរ ម៉ុក ទើប

ទ្រង់បង្គាប់ឲ្យលោក ម៉ុក មើលសត្វទាំងពីរនោះ លោកម៉ុក ទូលជា

ពាក្យកាព្យក្សាមក្នុងខណៈនោះថា:

– សត្វកែះទាំងពីរ មួយឈ្មោលមួយញីសុំបុស្រស់

ក្បាលតូចមុខស្របក្របកលាស់ របស់អាត់ម៉កលយកមកថ្វាយ ៗ

ក្នុងសម័យជាមួយនឹងលោកសុន្ធរ ម៉ុក នោះ មានកវីឯកម្នាក់ទៀត

មានងារស័ក្តិជាទី ឧកញ៉ាវង្សាធិបតី, កវីឯកទាំងពីរធ្លាប់បានប៉ះសំដីប៉ូ

មាត់គ្នាជាច្រើនដង តែគ្រង់ដែលមានគេចាំតៗគ្នាមកខ្លះនោះ គឺត្រង់ដែល

លោកសុន្ធរម៉ុកពោលបន្ទាប់លោកវង្សាធិបតីថា:

– សុន្ធរប្រាជ្ញព្រោក ប្រាជ្ញជាជាងលោក វង្សាធិបតី ៗ

លោកវង្សាធិបតីឆ្លើយបន្ទាប់វិញថា:

– សុន្ធរប្រាជ្ញព្រោក ប្រាជ្ញព្រើលជាងលោក វង្សាធិបតី សរសើរ

ខ្លួនឯង គ្រវែងដៃទូ បញ្ចេញសំដី ឲ្យស្រីកោតឯង ៗ

រឿងរ៉ាវកាព្យឃ្លោងរបស់លោកសុន្ធរ ម៉ុក នៅមានច្រើនតទៅទៀត

តែដោយហេតុមិនបានកត់ត្រាទុកមកជាបែបផែន បានជាមិនមានសេសសល់ដល់មកឥឡូវនេះប៉ុន្មានឡើយ រឿងធំៗដូចជារឿងទុំទាវនេះ យើងមិនដែលបានប្រទះទេ ធ្លាប់ឃើញតែពាក្យកាព្យខ្លីៗស្នាដៃរបស់លោក គេបានយកទៅបោះផ្សាយក្នុងកាសែត ១ ឈ្មោះ ស្រុកខ្មែរ កាលពីជាង ១០ ឆ្នាំមុននេះ ។

តាមដែលយើងបានមើលពាក្យកាព្យផ្សេងៗ ដែលពួកចិន្តកវីបានតែងឡើង ក្នុងជួសម័យព្រះករុណាព្រះបរមកោដ្ឋ ព្រះករុណាព្រះសុវណ្ណកោដ្ឋ នោះសេចក្ដីបរិនទាំងរបៀបកាព្យឃ្លោងខ្មែរ មានចំនួនគួរឱ្យសរសើរជាច្រើន ទាំងលំនាំសេចក្ដី ទាំងសម្ផស្សពាក្យចួន តែពាក្យកាព្យអស់នេះ បែរជាពាស់គ្រឿងរបស់ជនសម័យនេះខ្វះ ចំពោះត្រង់ដែលប្រើស័ព្ទបាលីច្រើនពេកប៉ុណ្ណោះ ប៉ុន្តែយើងមិនត្រូវបន្ទោស ពីព្រោះសម័យនោះភាសាបាលីជាឃ្លាំងចំណេះវិជ្ជា ជាភាសាមានដំឡៃថ្លៃបំផុត ជាមូលភាសានៃអក្សរសាស្ត្រខ្មែរ និងភាសាខ្មែរទាំងមូល បណ្ដាប្រជាជនទូទៅទាំងជាន់ខ្ពស់ជាន់ទាប សឹងនាំគ្នាលើកដំកើងអ្នកចេះបាលីព្រះត្រៃបិដកទាំងអស់ ទើបជាហេតុឱ្យអ្នកចេះបាលីមានសេចក្ដីចំរើន ទាំងកេរ្តិ៍ឈ្មោះទាំងយសសក្តិ មានចំនួនដូចសម័យសព្វថ្ងៃនេះ ដែលកដការលើកដំកើងអ្នកដែលប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សា ឬឧត្តមសិក្សាខាងវិជ្ជាបាកំងសែស ដូច្នោះដែរ ។

បើពោលចំពោះពាក្យកាព្យរបស់លោកអម្រឹតសត្រ មុក ដែលបានតែងរឿងទុំទាវនេះ ឃើញមានរបៀបតែងប្លែកផ្សេងពីរបៀបរបស់ចិន្តកវី

ផ្សេងៗក្នុងសម័យជាន់ដើម ឬក្នុងជំនាន់របស់លោក គឺលោកនិយមប្រើពាក្យកាព្យតែមួយបទ រហូតដល់ចប់ចុងចប់ដើម មិនប្រើច្រើនបទ ដូចជាចិន្តកវីឯទៀតៗឡើយ ដូចជារឿងទេវន្តនេះ ជារឿងវែងលន្ទង់លន្ទោច គួរប្រើពាក្យកាព្យច្រើនបទ ទើបសមនឹងផ្លូវរឿងដែលវែង តែលោកប្រើតែបទកាកគតិមួយ តាំងពីខាងដើមដល់ចប់រឿង ។

ក្នុងទីបំផុតនេះ យើងមានសង្ឃឹមថា រឿងទេវន្តពាក្យកាព្យរបស់លោកអម្រឹតក្សត្រី ម៉ុក នេះ ល្មមជាគ្រឿងប្រដាប់សតិបញ្ញារបស់ជនានុជនក្នុងសម័យសព្វថ្ងៃនេះបានខ្លះមិនខាន ដោយហោចទៅយើងនឹកសង្ឃឹមថាល្មមជាគ្រឿងបង្ហាញឲ្យយើងឃើញ ឲ្យយើងស្គាល់របៀបកាព្យឃ្លោងនឹងសំនួនវោហាររបស់ចិន្តកវីខ្មែរយើង កាលពីមួយសតវត្សកន្លងមកនេះជាប្រាកដ ដែលល្មមចាប់យកជាមេគំនិតដឹកនាំឲ្យយើងគិតបង់តែងកាព្យឃ្លោងឡើងខ្លះ នៅឱកាសដែលប្រទេសជាតិកំពុងត្រូវការកសាងអក្សរសាស្ត្រខ្មែរ ឲ្យបានចំរើនលូតលាស់ឡើងវិញនេះ ។

ហ្លួងនិពន្ធមន្ត្រី ញ៉ុក . ថែម

\+

× +

## រឿងទេវន្ត

### បទកាកគតិ

អហំវន្ទា អញ្ជលិយា បគ្គយ្ហា សិរសបណោ ពុទ្ធំ វរញ្ញា-
ណំ ញាណសេដ្ឋោ ។ អហំនមា នមស្សិត្វា ធម្មគុណោ
គុណសង្ឃំ អហំនមោ នមស្សមានោ រត្តិន្ទិវា ។

អញខ្ញុំបង្គំ ក្រញក្រាបប្រណម្យ ក្រោមព្រះបាទា ព្រពុទ្ធសម្តេច សារពេជ្ញសាស្តា ព្រះអង្គជាតិជា មកុដកែវកែវត្រៃ ៗ អហំអញខ្ញុំ ក្រាបថ្វាយបង្គំ ព្រះធម៌ថ្លាថ្លៃ ប្រាំបីហ្មឺនបួនពាន់ ធម្មខន្ធវិស័យ វិសេសក្រាសក្រៃ ជ្រៅជ្រះពិស្តារ ៗ អហំអញខ្ញុំ ក្រាបថ្វាយបង្គំ គាំងពីបឋម(១) សាវ័កសាវេក បច្ចេកពុទ្ធា ពោធិសត្វា ឥសីសង្ឃ(២)សព្វ ៗ បង្គំគុណគ្រូ វិញ្ញាណវិញ្ញូ តែងប្រដៅគ្រប់ អាចិអក្ខបាលី គម្ពីរបេះបប់ អញខ្ញុំគោរព មាតាបិតា ៗ នៅទេពទិសទស ទូទាំងសោឡស(៣) នូវមហាព្រហ្ម អញខ្ញុំប្រតិស្ឋ នមស្សការ ចាតុភជា(៤)នៅនាៈលោកិយ ៗ មានព្រះធត-រដ្ឋ(៥) ធិពដមហាក្សត្រ ជាអធិបតី សូមវុឌ្ឍិពរ បវរសិរី សុខសាន្តសួស្តី ដូចក្តីបំណង ៗ សូមឈ្នះលោភោ ទោសោមោហោ ទបត្រូញភ័យផង សូមសុខពាល់បាន និព្វានដូចប៉ង កុំបីមានហ្មង មារមកបំណ្ហា(៦) ៗ

សិរីសុភៈ មស្តុរៈ(៧) វរមង្គលា(៨) ពុទ្ធសាសនំ វិរិយា(៩) វរកាព្យា(១០) សារសព្វសេបក្តី ៗ ទ្វេសហស្សា(១១) ចតុស-តា(១២) ទ្វេសំវច្ឆរី(១៣) ឯឡក(១៤)អ- ស្សុជ្ជិមាសី(១៥) ព្រះហស្បតី តេតិត្ថិយា(១៦) ៗ

---

១– បឋមឬបឋមគឺបឋមសាវ័ក-បឋមសាវិកា ។ ២– ពួកឥសី ។ ៣–ទូទាំងឋានសួគ៌ ១៦ជាន់ ។ ៤– ស្តេចចាតុលោកបាល ដែលស្ថិតនៅប្រចាំទិសទាំងបួន ។ ៥– ជាឈ្មោះស្តេចចតុលោកបាលមួយអង្គក្នុងចំនួន៤អង្គ ។ ៦– ប្រែថា បៀតបៀន ។ ៧– សូមសិរីដ៏ប្រសើរល្អឲ្យមាន ។ ៨–មង្គលដ៏ប្រសើរ ។ ៩– ដ៏ប្រសើរវិសេស ។ ១០– កាព្យដ៏ប្រសើរ ។ ១១– ពីរពាន់ ។ ១២– បួនរយ ។ ១៣– នឹងពីរឆ្នាំ ។ ១៤–ឆ្នាំមមែ ។ ១៥–ខែអស្សុជ ។ ១៦–បីកើត ។

សក្រាជគ្រប់គ្រាន់ បួនរយពីរពាន់ នឹងពីរសប្ត គន់គិតគ្មេគ្មាន បច្ចុប្បន្នសាសនា មមែឯឡា អស្សុជមាស ៗ សុកប្បក្ខ[១] តេតិត្ថយេ គរុវារ៍[២] បីកើតគត់ច្បាស់ ព្រហស្បតិ៍ ករកាលអគ្គិ·សួរសមសគ្គា ៗ ប្រកបព្រះកើ្ត ប្រាកដបិតថេរ ជាកដមាតា ល្បីឮទៅឆ្ងាយ ប្រុះប្រាយ ប្រាជ្ញ នីរទេៈអ្នកណា[៣] ខ្ទៃស្មើបារមី ៗ ទ្រង់ព្រះនាមករ សម្តេច ព្រះវរ រាជជននី វរៈខត្តិយា វង្សសិរី សេដ្ឋាវរី វរោត្តម ៗ បរមគុល សកលមង្គល ឧត្តមបរម ប្រសើរប្រសិទ្ធ បពិត្រជាអំ-ម្ចាស់ប្រសើរសម បិតលើសិរសើ[៤] ៗ ស្តេចទ្រង់សីល ខន្តីសង្វំ អាចអត់ទេត្រ៍ តោសទុក្ខ សត្វសត្វ ទុគ្គតក្រក្រី ប្រោសប្រាណប្រណី ដោះដោយតោសទុក្ខ ៗ ទ្រង់ទូរទេសពិធ រាជធម៌ក្រមក្រិត្យ[៥] រីកស្តេសោតសុខ ធ្វើនបុណ្យ វិវឌ្ឍន៍ បំបាត់ភ័យផុក ប្រេមប្រោសតោសទុក្ខ ជួតបារមីតា ៗ ធម៌ព្រះកម្មដ្ឋាន សោតទ្រង់រៀនបាន ប្រសើរថ្លៃថ្លា គិតគុណរត្នត្រៃ តាំងបីទត្តិណា[៦] តែងទ្រង់មេត្តា ជីវិតសព្វសត្វ ៗ ស្តែងស្តេចមកគង់ នៅភ្នំហើយទ្រង់ សាងអដ្ឋសេរត្ន[៧] រូបគួរស្ញប់ស្ញែង គោតក្រែងបុណ្យ ក្តាត់ ហើយទ្រង់បែងចាត់ ព្រះរាជទ្រព្យធ្វើ ៗ

(មានត)

---

១–ខាងកើត ។ ២–ថ្ងៃព្រហស្បតិ៍ ។ ៣–គឺព្រះអ្នកឯណាមួយ ។ ៤–តាំងពីពាក្យថា សម្តេចព្រះវររាជជននី....បិតលើសិរសើ ជាព្រះនាមព្រះរាជមាតារបស់ព្រះករុណាព្រះនរោត្តម ។

៥–ទសពិធរាជធម៌គឺធម៌សម្រាប់ស្តេច១០ប្រការមានទាននឹងបរិច្ចាគជាដើម ។ ៦–ទក្ខិណៈ ឧត្តម, ខ្ពង់ខ្ពស់ ។ ៧–អដ្ឋារសៈ១៨គឺកសាងព្រះពុទ្ធរូបកំពស់១៨ហត្ថ ដែលហៅ ព្រះអដ្ឋារស នៅភ្នំព្រះរាជទ្រព្យស្រុកខ្ពង់សព្វថ្ងៃនេះ ។

សុភាសិតប្រដៅជនប្រុសស្រី

# ព្រះឃោសធម្ម ម៉ុង_សែស

ចៅអធិការវត្តមហាមន្ត្រី សង្កាត់លេខ ៥ ក្រុង

រៀបរៀង

( តមក )

៣២.–ណាភឹ ទស្សេតិ សុន្ទរី បង្ហាញនូវនាភីផ្ចិតអាត្មា
ឲ្យប្រុសឃើញគួបគាប់ដោយស្នេហា ដោយយកឫកលមាយាមាតុគ្រាម ។

៣៣.–អក្ខឹ និខនតិ កន្តា នារីក្រេកក មា ចំព្យាយាម
យកដៃកៀសភ្នែកកំពេចភ្នាម ប៉ងឲ្យគេបែរតាមមើលខ្លួនជាក់ ។

៣៤.–ភមុកំ ឧក្ខិបតិ បី ធម្មជាតិជាស្រីតែងមានញាក់
នូវចិញ្ចើមនៃខ្លួនដោយចិត្តស្ម័គ្រ ស្នេហាប្រមូលកក់ពេញចិន្តា ។

៣៥.–ឱដ្ឋំ បលិខតិ ឥត្ថី ជនបានជាតិជាស្រីកបតណ្ហា
យកធ្មេញប៉ែកខាងក្រោមនៃអាត្មា ច្បួតបបូរមាត់ថាប៉ែកខាងលើ ។

៣៦–.ជីវ្ហំ និល្លាលេតិ នារី ស្រីកើតនាលោកយធ្វើអំពើ
លៀនអណ្ដាតចេញក្រែមធ្វើងើ ឲ្យប្រុសចិត្តសើរើមើលខ្លួនលេង ។

៣៧.–ទុស្សំ មុញ្ចតិ រមណី ស្រាយសំពត់ចេញពីចង្កេះឯង
រលាស់រលាមមើល ទៅស្ដាំឆ្វេង នាំឲ្យប្រុសផ្សេងៗកើតមេត្រី ។

៣៨. ទុស្សំ ពន្ធតិ ទយិតា ចងសំពត់អាត្មាវិលវិញថ្មី
ដោយដឹកទាញចិត្តប្រុសឲ្យរេតី មាយារបស់ស្រីបែបនេះមាន ។

៣៩.- សិរសី មុញ្ចតិកគ្គ ស្រាយក្តួនសក់អាត្មាដោយគិតច្បាន

ឲ្យគេមើលចំហើយគ្រេកចង់បាន តាមច្បាប់ពីបុរាណមិនខុសគ្នា ។

៤០.- សិរសី ពន្ធតិ នារី ផនបានជាតិជាស្រីកបមាយា

ស្រាយក្តួនសក់ខ្លួនជាធម្មតា ត្រឡប់ចងវិញជាប្រក្រតី ។
ដែលបានថាថ្លែងថៃឥកយរៀបកប់ ជាច្បាប់មាយានៃជនជាស្រី
ចំនួនសែសិបគត់តាមបាលី កុណាលជាតកស្តីថ្លែងថៃងចប់ ។
ហៃនាងនារីល្អកបកល្យាណ គបដោយបញ្ញាញាណឈ្លាសវៃគ្រប់
ចូរមើលចូរស្តាប់ច្បាប់ឲ្យបានសព្វ ចូរវៀបត្រឡប់យកត្រង់ល្អ ។
ធម្មតារូបនៃស្រីដែលកើតស្អាត មិនបំពៅតាមខ្នាតជាខ្មៅស
មិនសំពៅយកមានឬជាគ្រ សំពៅឯកត្រង់ល្អសព្វាពង្គកាយ ។
ល្អគ្រប់ទាំងកំពស់ទីងទំហំ ក្បាលដៃជើងសក្តិសមត្រូគាកសាយ
ដំណើរលំនាំមន្ទល្អកើតឆាយ មិនបាច់ប្រើងកែក្រោយគឺល្អឯង ។
មួយទៀតនារីល្អមានប្រាំយ៉ាង: ល្អបក់, សាច់ជាសំគាល់ឃើញជាក់ស្តែង,
ល្អធ្មេញទន្សាស្រស់បស់ទៃង, ល្អវ័យបានអាថ៌ធ្វើយូរឆ្នាយ ។
សក់ប្រៀបដូចកន្ទុយនៃបក្ខាក្ងោក ស្រាកខ្ទំលាក់យារស្តោកទាំង ក្រោយកាយ
សំយុងដល់ធ្លាក់ក្បែនចុងកត់សាយ ងងឿងបបព្រមក្រោយល្អគួរគាប់ ។
រីមចបូមាត់នៃនារីណា ក្រហមទុំដូចជាផ្លែទន្ទាប់
ត្រឹមស្មើគ្នាជិតស្និទ្ធបប្រមជាប់ នារីនោះមានគ័ព្ទហៅល្អសាច់ ។
ល្អធ្មេញគឺធ្មេញនៃនារីណា សម្បុរស្រស់ស្មើគ្នាជិតមិនដាច់
ដូចយកពេជ្រមកដាំជាជួរក្បាច់ នារីនោះបានស្រួចហៅល្អធ្មេញ ។

សម្បុរស្បែកនៃនាងនារីខ្មៅ   មិនបាច់លាបដោយម្សៅជាទីពឹង
ផ្គូរផង់ក្ដីបំព្រងល្អស្អាតក្ដឹង   គួរប្រៀបធៀបនឹងចបល្បាខៀវ ៗ
សម្បុរស្បែកនៃនាងនារីស   ផ្គូរផង់ហ្នត់ល្អក្ដីស្រស់ស្រៀវ
ប្រុសឃើញស្រឡាញ់ស្ទើរលិទ្ធក្រលៀវ   ប្រុសផ្អើលមើលខ្វល់ខ្វៀវតែគ្រប់គ្នា ៗ

នេះហៅស្រីល្អសម្បុរស្បែក   តម្រាប្រីល្អឯកតាមវាសនា
ជាផលបុណ្យតានសីលភាវនា   អប់រំសាងល្អជាពីព្រេងនាយ ៗ
ស្រីណាមានរូបល្អវ័យជំបូង   សម្រាលកូនប្រាងប្រូងច្រើនរៀងកាយ
វ័យនៅតែល្អនឹងមិនប្រែក្លាយ   ស្រីនោះសោភបរិយាយហៅល្អវ័យ ៗ
រូបស្រីល្អជាទុយបញ្ឆោតពាល   ឲ្យកើតគ្រេកគ្រអាលទាំងយប់ថ្ងៃ
ឲ្យវង្វេងភន្តកាំងបាត់ព្រះត្រៃ   លក្ខណ៍ដោយឥតសង្ស័យក្នុងចិត្តា ៗ
គឺភ្លេចត្រង់ធម៌ជាអនិច្ចំ   ភ្លេចទាំងទុក្ខំនឹងអនត្តា
ស្រវឹងវង្វេងដូចផឹកសុរា   កើតទាំងលោភតណ្ហាច្រើនពេញទី ៗ
បើងបានថ្វាថ្លែងថែងចរចា   ចងជាពាក្យកាព្យប្រះដាស្រី
ឲ្យស្គាល់ការខុសត្រូវកិច្ចការអ្វី   បានឹងចប់សេចក្ដីតែប៉ុណ្ណេះ ៗ

×

× ×

# ពាក្យប្រដៅប្រុស

## បទពាក្យ ៨

នេះនឹងថ្លាថ្លៃថែនជាពាក្យកាព្យ ឲ្យអ្នកប្រុសបានជ្រាបសព្វសេចក្តី
គជាប់មកពីពាក្យប្រដៅស្រី ប្រុសផងគួរគប្បីទុកជាច្បាប់ ៗ
ជាតិមនុស្សកើតមកបានជាប្រុស កុំឲ្យមានខូចខុសតាស់ដល់ស្លាប់
មិនសេពគប់ឲ្យត្រូវរកចំណាប់ ឲ្យទៅជាអាប់មួយជីវិត ៗ
គួរសេពគប់ស្និទ្ធស្នាលនឹងអ្នកជា អ្នកមានប្រាជ្ញាគប់សុចរិត
ដែលមានគំនិតល្អជាបណ្ឌិត ប្រព្រឹត្តត្រឹមត្រូវផ្លូវតាំងប្រាំបី ៗ
កាលដែលខ្លួននៅតូចចំប្រឹងរៀន អក្សរជារបៀនដំបូងថ្មី
តាំងលេខនព្វន្តគណិតគួរអើ ឲ្យចេះចាំមានថ្វីដៃប្រាកដ ៗ
ឲ្យចេះគតិធម៌គតិលោក បានជាអ្នកប្រាជ្ញប្រាកដត្រូវបែបបទ
ប្រដៅខ្លួនឲ្យល្អត្រូវខាតគត់ ទើបគួរបង្ហាត់ពត់អ្នកដទៃ ៗ
កាលដែលខ្លួននៅតូចរក្សាខ្លួន ឲ្យសុខល្អមាំមួនដោយប្រពៃ
កុំឲ្យបាក់គ្រេចផ្លាស់អស់ជើងដៃ ឬខូចកែកសរសៃជាដើមការ ៗ
កុំឲ្យមានតាស់ខែងឈ្មោះប្រកែក ប្រកាន់ពាក្យដដែកឥតមារយាទ
ឲ្យចេះដឹងគួរសមនឹងពួកញាតិ នឹងអ្នកដទៃឃ្លាតមោះហ្មង ៗ
ឲ្យចេះកោតក្រែងខ្លាចចាស់ព្រឹទ្ធា មានវ័យហួសដកអ្នករៀមច្បង
នឹងអ្នកមានសីលសុទ្ធទៀងត្រង់ផង ប្រតិបត្តិឥតឆ្គងផ្លូវវិន័យ ៗ
នឹងអ្នកមានជាតិខ្ពស់ខ្ពង់ត្រកូល ជាក្សត្រមហាសាលច្រើនថ្កាថ្លៃ
កុំប្រមាថមើលងាយដូចសត្វព្រៃ ក្រែងកើតទោសចង្រៃបាបគ្រោះ ៗ

ចូររៀននិយាយពាក្យសុភាសិត ឲ្យជាទីពេញចិត្តផ្អែមពីរោះ
កុំរៀនហាត់និយាយពាក្យគ្រោតគ្រោះ ចេញសំដីបោកបោះឥតគួរសម ។
ផ្គត់ផ្គង់សារិយាបថទាំងបួន ដេកឲ្យល្អសមសួនតាមច្បាប់ក្រម
ដើរឈរទឹនអង្គុយគំរមទម អប់រំទាំងបុកពារឲ្យសមល្អ ។
រៀនធ្វើខ្លួនឲ្យមានសណ្ដាប់ធ្នាប់ កិរិយាគួរគាប់តាមមានក្រ
កុំធ្វើឲ្យហួសហេតុទៅជាស កុំយកជាតិសំណាធ្វើជាប្រាក់ ។
ខ្លួនក្រកុំធ្វើឫកដូចសេដ្ឋី ឬដូចមន្ត្រីអ្នកមានស័ក្តិ
កុំអួតសរសើរខ្លួននាំខាតលក្ខណ៍ សរសើរស្ដីធ្លាក់ខ្លួនថយថោក ។
បើគេមិនសួរទេកុំឆ្លើយឆ្លង និយាយហួសបំណងច្រើនគរគោក
បើគេមិនហៅទេកុំទៅឈ្លោក នាំខ្លួនឲ្យជ្រោកជ្រោកហិនលក្ខណា ។
បើមានសម្បត្តិទ្រព្យធនធានច្រើន កុំធ្ងើងថ្ងៃព្រហើនកាចឫស្យា
ឲ្យមានចិត្តទោរទន់ករុណា ដល់ជនផងនានាទីទ័លក្រ ។
កុំមើលងាយមើលថោកអ្នកក្រខ្សត់ ធ្វើឲ្យត្រូវបែបបទអ្នកចិត្តល្អ
គួរសង្គ្រោះដាក់ទានបាយសម្ល តាមចាស់ទុំតៗពីបូរាណ ។
បើបានជាអ្នកធ្វើស្រែចំការ ជាផ្លូវរកអាហារទទួលទាន
ចូរអ្នកខំប្រឹងប្រែងរកឲ្យមាន កើតសម្បត្តិធនធានបរិបូណ៌ ។
ក្របីគោទីពឹងនៃអ្នកស្រែ គួរចេះថ្នាក់ថ្នមថែដោយអាសូរ
ឲ្យបានធាត់ធំខ្លាំងរស់នៅយូរ នាំឲ្យទូលាយដូរសម្បត្តិទ្រព្យ ។
កន្ទុះប្រឡេខ្សែស្រះបំពង់ រៀនឲ្យស្អាតហ្មត់ចត់ជាការជាប់
ទុកជាមនុស្សមានសណ្ដាប់ធ្នាប់ មានព្យាយាមគួរគាប់ប្រសើរជា ។

មេនណាគេមានកូនក្រមុំ    គួរផ្សំផ្គុំឲ្យជាភរិយា
ដោយហេតុធ្វើការមិនខ្ជិលខ្ជា    ចេះថែទាំរក្សាទ្រព្យសម្បត្តិ ។
ពេលយប់ចំពាក់ភ្លើងជាធម្មតា    ដោយចិត្តមានមេត្តាប្រណីសត្វ
កុំឲ្យមូសសុចខាំកើតវិបត្តិ    កើតស្នាំស្នាមពេកក្តាត់ប្រើពុំបាន ។
ថែទាំស្មៅចំណីលាងទឹកផង    ពេលប្រើកុំសំពងហួសប្រមាណ
ផ្ទុកឲ្យល្មមកម្លាំងបន្ទុកយាន    ឲ្យមានមេត្តាត្រាប្រណីសត្វ ។
សេចក្តីកង្វល់បាលីគម្ពីរថា    អ្នកមានករុណាច្រើនពេកក្តាត់
ឲ្យផលមិនសូវមានគេជម្ពាត់    បៀសវាងគ្រីវិបត្តិដោយគេជូន ។
ធ្វើស្រែត្រូវផ្គត់ផ្គង់ដើមសំណាប    ត្រូវគិតបាត់បែងសាបតាមជំនន់
សាបហើយថែរក្សាមើលគយគន់    ក្រែងខូចដោយទឹកជន់ឬសត្វស៊ី ។
សំទូងល្អផលល្អព្រោះសំណាប    ដែលគេបាត់បែងសាបគង់នាទី
ដុះឡើងល្អល្អួតលាស់ស្រស់ខៀវខ្ចី    សំណាបតែងយោងដីស្រីយោងប្រុស(1) ។
ធ្វើស្រែលើកភ្លឺស្រែឲ្យត្រឹមត្រូវ    កុំឲ្យវៀចកង្គិកគង់ច្រើនខូចខុស
អ្នកផងគេនិន្ទាថាកំហុស    បាតជាមនុស្សលោភបបរី ។
អ្នកលោភពសុធាច្រើនបានទុក    ច្រើនទាស់ទែងអ្នកស្រុកច្រើនកើតក្តី
បង់ខាតទាំងប្រាក់កាសគ្មានសល់អ្វី    ជាមនុស្សផ្អប្រើយសក្តាន ។
ធ្វើស្រែត្រូវបំប្រាបឲ្យរាបស្មើ    បើទឹកតិចរាបលើសត្រូវបាន

•ពាក្យបុរាណថា "សំណាបយោងដី ស្រីយោងប្រុស", បើដីធន់តែសំណាបល្អ គង់ក្រាប់បើ, បើប្តីអន់ប្រពន្ធក្រាន់បើ គង់ក្រាន់បើដែរ ។

ស្រូវល្អស្មើគ្រប់គុម្ពចំរើនក្លាន    ចំរើនគ្រាប់ស្រូវបានដូចប្រាថ្នា ។
សំណាបចាស់ល្មមការត្រូវដកស្ទូង    ចាប់តាំងពីដំបូងស្របកាលណា
ត្រូវយកបត្តុកដាក់ចាំរក្សា    ក្រែងក្បៀចផុនរំលាលចខូចខាត ។
ត្រូវយើងបង្ហូរចេញទុកឲ្យល្មម    ឲ្យស្ទូងលាស់ព្រមល្អល្អូកស្អាត
ឬមួយបាក់ភ្លឺស្រែហូរហួសខាត    គួរទំប្រឹងសង្វាតទប់ឲ្យជាប់ ។
ថែទាំចាំរក្សាទាំងថ្ងៃយប់    ព្យាយាមកុំឈរឈប់ជាចំណាប់
ចំនៀមអ្នកមានស៊ីអ្នកមានទ្រព្យ    ប្រឹងប្រែងធ្វើការខ្ជាប់មិនកៀចក្រាញ ។
ស្រូវចេញប្រុងប្រៀបដេញបាបលលក    នឹងសេកកុំឲ្យមកស៊ីបំផ្លាញ
ទោះនឿយហត់យ៉ាងណាកុំធុញក្រាញ    តាមផ្លូវអ្នកជំនាញខាងរកស៊ី ។
ស្រូវទុំចំប្រូតកាត់ឲ្យរួសរាន់    ទំពោកបែនបញ្ជាន់ឲ្យពេញទី
កុំពោយពោលសំដីទីងធូលី    តាមច្បាប់ប្រពៃណីពីបូរាណ ។
ចំដឹកដៀវដេញ្ជូនដាក់ជង្រុក    ឲ្យល្មមតាមបន្ទុកសម្រេចបាន
ហើយដឹកស្របកាលណាកើតសុខសាន្ត    បានស្បើយទុក្ខរំខានព្រោះធ្វើ-

ស្រូវៗ

បានស្រូវហើយកុំចាយឥតសណ្តាប់    សំចៃទុកតាមច្បាប់ដែលត្រឹមត្រូវ
ក្រែងអត់ឃ្លានខ្វះខាតដោយរដូវ    ប្រព្រឹត្តដើរតាមផ្លូវអ្នកមានទ្រព្យ ។
អ្នកធ្វើស្រែត្រូវធ្វើចំការផង    ដំណាំមានរបងឲ្យជិតជាប់
ឲ្យមានដំណាំច្រើនជាចំណាប់    ជំនួយស្រូវគួរគាប់ក្រែងអត់ឃ្លាន ។
ចំដាំចេកអំពៅត្រាវដំឡូង    ឫស្សីស្រុកស្វាយដូងគ្នាតឲ្យមាន
កុំឲ្យខ្វះត្រង់ណាដោយគិតច្បាន    ឲ្យបានបរិបូណ៌គ្រប់ប្រើប្រាស ។

លក់ដូរយកតម្លៃកម្រៃចាយ បរិភោគសប្បាយស្រួលពេកណាស់
ហៅអ្នកមានគ្រឿងស៊ីមិនបេះខ្ទះ ចុំចើងតាមពាក្យចាស់ថាមានស៊ី ។
អ្នកខ្ជិលដាំដំណាំច្រើនតែអត់ កូនចៅឯងមើលមាត់គេមមី
សម្លឹងមើលគ្នាគេៗ ដោយសម្ដី មិនបេះធ្វើចំណីឲ្យកូនចៅ ។
អ្នកធ្វើចំការសុខមិនធ្វើស្រែ គេដាំសព្វបន្លែបេកអំពៅ
ដើមល្ហុងទីងដើមក្ដុម្ពស្លាដើមត្នោត សណ្ដែកសសណ្ដែកខ្មៅកប្បាសត្រុម ។
ដាំថ្នាំតក្រូចពោតក្រហមស ធ្វើទីដីឲ្យល្អល្អិតសុខុម
ការរៀបចាររៀបដាំដោយជុំ ដាំតាមពួកតាមក្រុមទើបចំរើន ។
ការដាំក្ដីស្រួចហើយពាំថែកាំ ព្យាយាមឲ្យមួនមាំទើបបានកើន
កុំខ្ជិលច្រអូសពេកខំក្រើក តែងបានកើតផលច្រើនចិញ្ចឹមខ្លួន ។
លក់ដូរឲ្យហែហូររៀងរាល់ថ្ងៃ ជាភាគផលកម្រៃដោយគាប់ជួន
នេះហើយហៅថាផលព្យាយាមមួន ហុចឲ្យតាមចំនួននៃកម្លាំង ។
វិធីអ្នកស្ទះស្វែងរកអាហារ ដោយធ្វើស្រែចំការដោយសម្រាំង
សម្រិតដោយសុចរិតពិតសព្វ វិធីញាំងអាជីពឲ្យផូរផង់ ។
បើអ្នកចង់បានកូនប្រពន្ធ សម្លឹងមើលទ្រព្យធនទីងពូជពង្ស
សម្លឹងមើលពូជបេះបុះខ្ញុំល្ងង់ សម្លឹងមើលពូជត្រង់ឬពូជវៀច ។
គន់មើលព្យាយាមច្រើនឬតាបទន់ ច្រើនដំអក់ទំនេខ្ជិលក្រាញកៀច
ជាមនុស្សស្អាតបាតឬពាពៀច ដូចសត្វក្របីខ្វៀចប្រឡាក់ភក់ ។
ពួកខ្លះច្រើនយកប្ដីដោយចិត្តឯង គ្មានមេបាចាត់ចែងអប់ចំពក់
គ្មានស្ដាប់មេស្ដាប់បាជានាយក ជាមនុស្សត្រគ្រក់ប្រុសគួរខ្ពើម ។

ពួជខ្លះច្រើនប្តីលែងនៅមេម៉ាយ　　ឥតមានសប្បាយផុតចុងដើម
ជួនកាលយកប្តីទៀតធូរដង្ហើម　　ជួនកាលទុក្ខសម្ងៀមជាងមុនផង ។
ពួជខ្លះសាំងនឹងប្រុសមិនចេះស្រែក　　ដោយចិត្តជាប់តម្រេករួមស្នេហ៍ស្នង
ស្និទ្ធស្នាលទៅនឹងប្រុសដូចប្អូនបង　　ឥតគិតការមោះហ្មងដោយក្នកគេ ។
ពួជខ្លះច្រើនលួចលាក់តែបន្ទុំ　　ឃើញទ្រព្យធនសន្សំយកទទេ
ខ្សៀមខ្សឹមមើលនាយអាយបែរវិះវេ　　វិះរករឿងគេចកែងឆក់បេកក្លាម ។
លួចចាំងពីពងមាន់ទឹងពងទា　　ចាំងទ្រព្យផងនានាសព្វគ្រប់នាម
ច្រើនតែមានទោសទុក្ខច្រើនភ្លាក់តាម　　ច្រើនត្រូវការគម្រាមគុកច្រវ៉ាក់ ។
ពួជខ្លះច្រើនផិតប្តីមានសហាយ　　ដោយសេចក្តីសប្បាយការរួមរ័ក
លួចលក់ខ្លួនសន្សំយកលុយកាក់　　ឬយកទ្រព្យមាសប្រាក់ឲ្យសហាយ ។
ពួជខ្លះមិនស្រឡាញ់ការសិក្សា　　គេនិយាយកាលណាមិនរីករាយ
ទុកកូនចៅឲ្យល្ងង់មិនខ្វល់ខ្វាយ　　មិនឲ្យកូនសប្បាយដោយវិជ្ជា ។
ពួជខ្លះច្រើនលោកដីរបងដើរ　　ច្រើនតែកើតជំណើរទាស់ទែងគ្នា
ព្រោះដីមួយចំអាមមួយហត្ថ　　បង់ប្រាក់កាសអាត្មាអស់គ្មានសល់ ។
សូម្បីបងប្អូនឯងរួមផ្ទៃគ្នា　　កើតទាស់ទែងគ្រៀវក្រាឥតយោគយល់
ព្រោះតែដីតិចតួចនាំអំពល់　　នាំឲ្យកើតរវល់ជល់មេស្រុក ។
ពួជខ្លះច្រើនអំនួតអួតក្អុតករ　　និយាយលើសគំនរហួសបន្ទុក
បន្ទន់បន្ទាបគេដូចឈើពុក　　គេច្រើនតែស្អប់មុខខ្ពើមសំដី ។
ពួជខ្លះប្តីដើមគេស្ទាត់កំប៉ាំង　　ល្បះបុញ្ញាច្រើនពេកខ្លាំងជួអប្រិយ
បណ្តាលឲ្យកើតឈ្មោះឬកើតក្តី　　ច្រើនបានគេស្រដីដើមតបវិញ ។

ពូជខ្លះច្រើនជាអ្នកស្វិតកំណាញ់ ទុកជាឃ្លាំងឬស្រឡាញ់មិនហ៊ានទិញ
ស៊ូស៊ុំដោយសារគេសង្កត់ធ្មេញ មិនអាចហ៊ានបញ្ចេញចាយស៊ីចុក ៗ
ពូជខ្លះកាចឃោរឃៅឥតសណ្ដាប់ ច្រើនឈ្លោះវាយចាក់កាប់បានក្ដីទុក្ខ
បង់ប្រាក់បង់កាសហើយថែមត្រូវគុក មនុស្សផងក្នុងស្រុកច្រើនរអា ៗ
អ្នកប្រុសផងទាំងឡាយចូរជញ្ជឹង ចូរគិតគួររំពឹងរកភរិយា
ឲ្យបានក្ដីសុខសាន្តដល់អាត្មា ក្រែងទុក្ខវេទនាទៅថ្ងៃក្រោយ ៗ
យកប្រពន្ធទ្រព្យធនស្មើគាត់គ្នា ស្មើត្រកូលវង្សាឥតមានក្លាយ
មិនមានមើលងាយគ្នាគ្រប់ជ្រុងជ្រោយ បានសុខតាមអំណោយផលរៀងខ្លួន ៗ
បើបានប្រពន្ធហើយចូរសង្កេត ខំប្រឹងប្រែងខំឃ្លាតឲ្យមាំមួន
ស្វែងរកទ្រព្យសម្បត្តិឲ្យសមសួន កុំឲ្យបានជួបជួនទីងទ័លក្រ ៗ
ប្រយ័ត្នកុំឲ្យមានឈ្លោះប្រកែក ប្រកា ពាក្យជជែកស្ដីតបត
ការប្រឆាំងទាស់ទែងគ្នាមិនល្អ ជាដើមហេតុបង្កឲ្យខាតទ្រព្យ ៗ
ព្រះពុទ្ធទេសនាប្រដៅជន ប្ដីសង្គ្រោះប្រពន្ធដោយគួរគាប់
ថាមានប្រាំប្រការដោយរៀបរាប់ ជនណាមានបុណ្យភ័ព្វប្រព្រឹត្តតាម ៗ
សម្មាននាយ ធម្មិកា សរសើរភរិយាជាប់ជិតជាម
មិននិយាយអាក្រក់អាសគ្រាម ពោលតាមធម៌គឺពោលពាក្យទន់ភ្លន់ ៗ
តថា ច អវិមាននា មិនមើលងាយជេរថាឲ្យប្រពន្ធ
មិនពោលពាក្យបាក់ដោតជាពាក្យធ្ងន់ មិនបៀតបៀនរិះគន់ឲ្យបង្អៀត ៗ
អបិ អនតិចរិយា មិនកន្លងចិត្តគ្នាមានស្រីទៀត
មិនក្បត់ប្រពន្ធឯងរកស្នៀត នាំឲ្យកើតសង្កៀតសង្កៀរចិត្ត ៗ

ផស្សប្រិយស្សរោស្សគ្គោ ចិត្តស្វាមីទន់ទោរទឹកអាណិត
លះបង់អំណាចខ្លួនទៅ ផ្តុកផ្តិត ប្រគល់ទ្រព្យធនពិតឲ្យប្រពន្ធ ៗ
អលង្ការានុប្បទានំ មេត្តាមានកម្លាំងឥតរះគន់
ស្វែងរកគ្រឿងប្រដាប់ស្រាលប្តូន់ តាមកម្លាំងទ្រព្យធននៃអាត្មា ៗ
ឲ្យបានមានៈប្រើប្រាស់ដូចអ្នកផង កុំឲ្យមានសៅហ្មងចិត្តត្រង់ណា
ឲ្យកើតសប្បាយចិត្តគ្រប់វេលា ហៅសង្គ្រោះភរិយាតាមបាលី ៗ
ការសង្គ្រោះបែបនេះជាមង្គល ជាបុណ្យកុសលកបសិរី
ត្រូវតាមពុទ្ធដីកាព្រះជិនស្រី ជនផងគួរគប្បីយកតម្រាប់ ៗ
មនុស្សទេវតាតែងសរសើរ ជាផ្លូវដំណើរល្អគួរគាប់
គួរគិតប្រព្រឹត្តតាមកាន់ឲ្យខ្ជាប់ យកទុកធ្វើជាច្បាប់ប្រពន្ធប្តី ៗ
ថ្ងៃមួយព្រះឥន្ទ្រស្តេចទេវតា ទ្រង់ព្រះនាមហៅថាព្រះកោសិយ
ទ្រង់ចុះចាកប្រាសាទមានសិរី ទ្រង់សំពះទិសទីទាំងដប់គត់ ៗ
គ្រានោះទេវបុត្រមាតលី បានឃើញព្រះកោសិយជាក់ប្រាកដ
ក្រាបបង្គំទូលសួរតាមបែបបទ ទ្រង់មានការកំណត់សំពះអ្វី ៗ
ព្រះឥន្ទ្រទ្រង់ឆ្លើយបតតាមពាក្យសួរ តាមការល្មមសមគួរដោយសំដី
ទន់ភ្លន់ពិតប្រាកដអាចសេចក្តី ដល់ព្រះមាតលីបានជ្រាបច្បាស់ ៗ
ឧបាសកឯណាមានសីលសុទ្ធ មានភរិយាបុត្រគ្រប់គ្រងផ្ទះ
ខំសាងបុណ្យកុសលមិនដែលលះ មានបញ្ញាតេជះស្មុតទៀងត្រង់ ៗ
ចិញ្ចឹមកូនប្រពន្ធដោយធម៌ពិត មិនដែលវិបរិតមិនលះបង់
យើងលើកដៃដប់សំពះដោយផ្ចិតផ្ចង់ ចិត្តបំពោះតម្រង់អ្នកនោះឯង ៗ

(មានត)

ពេជ្រព្រះរាជា

# លោក ស៊ុន-ហ៊ាន ប្រែរៀបរៀង

# លោក យូរ អ៊ុន ពិនិត្យកែសម្រួល

( តមក )

## ១០

ចំណេរកាលតាំងពីព្រះធម្មបតិកជាបានព្រះរាជសុណិសា សមតាមព្រះរាជបំណងហើយ ព្រះអង្គក៏ទ្រង់គ្រប់គ្រងព្រះនគរឲ្យចំរើនរុងរឿងដោយព្រះរាជហឫទ័យដែលស្មើរគេធម្មានុភាពឲ្យប្រាកដ ក្នុងរជ្ជកាលរបស់ព្រះអង្គ, ព្រះរាជការកិច្ចបានសម្រេចទៅដោយរៀបរយជាប់រៀងមក, ព្រះអង្គទ្រង់ពិចារណាឃើញនូវសេចក្ដីអង់អាចនៃព្រះរាជសុណិសាដោយសេចក្ដីទៀងត្រង់តាមធម៌ ព្រះអង្គទើបទ្រង់ជ្រើសប្រោសក្នុងករណីយកិច្ចតាំងពួនដែលសុវេលបានតាក់តែងទៅតាំងក្រនឹងឆ្ងាយ ឲ្យបានសម្រេចផលល្អគ្រប់ប្រការ, ឯសេចក្ដីអង់អាចរបស់សុវេលនោះ ពុំមានអ្នកណាដឹងសោះ មានតែខ្លួនសុវេលនឹងនន្ទិអមាត្យប៉ុណ្ណោះទេ ដែលអាចដឹងបាន ព្រោះការណាដែលត្រូវគេតែងប្រឹក្សានឹងបិតា លោកអមាត្យនន្ទិក៏ជួយណែនាំកែខៃឲ្យគិតៈឃើញយ៉ាងល្អិតសុខុម គេទើបប្រតិបត្តិរាជការបានល្អជានិច្ច, ដោយអំណាចនៃគុណគឺសេចក្ដីល្អនេះឯង ព្រះរាជាទើបទ្រង់តែងតាំងឲ្យជាឧបរាជរបស់ព្រះអង្គ, កាលសុវេលបាននៅឋានៈជាឧបរាជហើយ គេក៏គ្មានកើតកើនក្នុងយសស័ក្តិ តាមវិស័យរបស់អ្នកដែលធ្លាប់ជួបប្រទះគ្រោះកម្មយ៉ាងធ្ងន់មកហើយ ត្រឡប់ជាប្រាថ្នានឹងទំនុកបំរុងព្រះពុទ្ធសាសនាដែលត្រូវគេបោះបង់ចោលឲ្យទ្រុឌទ្រោមត្រឡប់រុងរឿងឡើងវិញ ដោយ

ការត្រិះរិះយ៉ាងសព្វគ្រប់ព្រមដោយផែនការណ៍ដ៏ល្អហើយ គេក៏ព្យាយាមទំនុកបំរុងសេវកាមាត្យទាំងឡាយ មិនយូរប៉ុន្មានក៏សម្រេចតាមបំណង នៅសល់តែព្រះពជាប៉ុណ្ណោះទេ ដែលព្រះអង្គទ្រង់ស្ទាក់ស្ទើរព្រះទ័យ តែមិនយូរប៉ុន្មាន សុរពលក៏ណែនាំព្រះទ័យរបស់ព្រះធម្មបតីពជាបានសម្រេច ព្រះអង្គទ្រង់បែរមកជ្រះថ្លាក្នុងព្រះពុទ្ធសាសនាបានប្រកាសខ្លួនជាពុទ្ធមាមកៈ; ពុទ្ធសាសនាក្នុងនគរពោកសីកំរុងរឿងមិនចាញ់ប្រៀបព្រះពុទ្ធសាសនាខាងក្រុងពជត្រិះឡើយ; ទៅជាប្រទេសមួយមានការសិក្សាធម្មវិន័យខាងព្រះពុទ្ធសាសនា ជាហេតុញ៉ាំងការចូលចិត្តធម៌វិន័យឲ្យកើតឡើង ដល់អាណាប្រជារាស្ត្រ ។

ឧបពជសុរពល កាលបានទទួលសេចក្ដីសុខដោយយសនឹងសម្បត្តិប៉ុណ្ណោះហើយ ក៏រឹតតែមានសេចក្ដីរាប់អានអមាត្យបាលិតដែលជាអ្នកទំនុកបំរុងខ្លួនគេមក ដូចជាមាតាបិតារបស់គេម្នាក់ក៏ថាបាន ចំណែកអមាត្យបាលិតមានសេចក្ដីកោតខ្លាចឧបពជសុរពលក្នុងផ្លូវរាជការ ហើយប្រតិបត្តិតាមពាក្យសុរពលដោយរៀបរយ តែកាលដល់វេលាក្រៅការរាជការ ឧបពជសុរពលក៏ត្រឡប់ជាសុរពលដូចដើមវិញ លោកអមាត្យបាលិតទើបចូលចិត្តមកសន្ទនាជាមួយនឹងឧបពជសុរពលរឿយៗ, រឿងសន្ទនាគ្នានោះ គឺរឿងជាប់ទាក់ទងឫទ្ធិស័ក្តិនិងនាគកាញ្ចនា; ថ្ងៃមួយកាលនៅជួបជុំមុខគ្នា អមាត្យបាលិតក៏និយាយអំពីឫទ្ធិស័ក្តិថា :

— ខ្ញុំប្រើមនុស្សនាំចុតហ្មាយបញ្ជាក់សេចក្ដីប្រព្រឹត្តរបស់ឧបពជនឹងគ្រួសារហើយ ហេតុអ្វីទើបយឺតយូរស្ងៀមស្ងាត់មិនមានដំណឹងអ្វី ? ។

សុពេលក៏មានគន្លល់ណាស់ជាងលោកបាលិតអមាត្យ ទើបតប តាមសេចក្ដីយល់ឃើញថា:

– ខ្ញុំគិតថាមិនប៉ុន្មានថ្ងៃទេ យើងគង់បានដំណឹងខ្លះពុំខាន ព្រោះការដើរផ្លូវហើយ យ៉ាងឆាប់ណាស់ក៏២ខែបាយដែរ ប្រហែលអ្នកនាំសំបុត្រទើបនឹងប្រញាប់ដើរផ្លូវត្រឡប់មកពីក្រុងកជគ្រិះវិញក៏ថាបាន ឬទ្ធិស័ត្យកាលដឹងរឿងហើយ គេក៏មិនព្រងើយកន្ដើយដែរ ។

– "មិនមែនដូច្នោះទេដឹង?" លោកបាលិតនិយាយឡើង "ខ្ញុំដឹងច្បាស់ថាសេដ្ឋីជាបិតារបស់ឬទ្ធិស័ត្យជាអ្នកប្រកាន់ខ្លួនខ្លះដែរ ជួនកាលចំពោះរឿងពាក់ព័ន្ធនឹងការចូលទៅរកអ្នកមានបុណ្យស័ក្ដិ គាត់មិនព្រមពឹងពាក់អាស្រ័យអ្នកណាទេ គាត់គាប់យល់ឃើញថាឥឡូវនេះសុពេលក៏ជាទុកជាហើយ គង់នឹងមានចិត្តថ្លើមឃ្លាតឆ្ងាយពីគាត់ក៏ថាបាន ខ្ញុំស្គាល់ច្បាស់នូវនិស្ស័យរបស់លោកម្នាក់នេះណាស់ សូម្បីព្រះរាជាហ្នឹងឯង សេដ្ឋីនឹងចូលគាល់ក៏ចំពោះកាលមានព្រះរាជកិច្ចជាចាំបាច់ កាលបើដូច្នេះខ្ញុំយល់ឃើញថាជាការលំបាកពេក ខ្ញុំអាណិតតែបុត្តនឹងធីតារបស់គាត់ប៉ុណ្ណោះ ដែលជិតនឹងពីរឃ្លាតឆ្ងាយពីគ្នាណាស់ ដូចម្ដេចនឹងដឹងហេតុការណ៍របស់គ្នាឲ្យពិតប្រាកដបាន" និយាយហើយលោកបាលិតក៏ដកដង្ហើមធំ ។

" ប្រហែលមិនជាអ្វីទេដឹងលោក! ចិត្តរបស់ឬទ្ធិស័ត្យខឹងខ្លួនណាស់ ហើយឬទ្ធិស័ត្យធ្លាប់និយាយប្រាប់ខ្ញុំថា សេដ្ឋីមានសេចក្ដីមោទនស្សជំនួសលោកជាច្រើន កាលណានឹងពឹងពាក់អាស្រ័យលោកពុំបាន បើនឹងប្រកាន់ខ្លួនខ្លះត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះមិនជាច្រើនប៉ុន្មានទេ, ខ្ញុំចង់ដឹងតែត្រឹមថា

តើសព្វថ្ងៃនេះ ពុទ្ធិស័ត្យឋិតនៅក្នុងក្រុងរាជគ្រឹះឬទេ?" សុពេលនិយាយដោះសារជំនួសសេដ្ឋីជាបិតារបស់ពុទ្ធិស័ត្យដោយសេចក្ដីសុភាព ។

ខណៈដែលកំពុងសន្ទនាគ្នានោះ មនុស្សបំរើបានចូលមកប្រាប់ថា មានអ្នកត្រូវការជួបនឹងលោកបាលិត ។ ទើបឲ្យអញ្ជើញចូលមក ។

មួយស្របក់ទៀត, ក៏មានបុរសពីរនាក់ស្ពាយថាវដើរចូលមកជាមួយនឹងមនុស្សបំរើ ហើយសួរថា "លោកបាលិតគឺអ្នកណា? ខ្ញុំជាមនុស្សបំរើរបស់ពុទ្ធិស័ត្យជានាយឲ្យនាំសំបុត្រមកជូនលោក" ។

-"យើងហ្នឹងហើយ" និយាយហើយអមាត្យបាលិតក៏ដើរចូលទៅរកមនុស្សទាំងពីរនាក់ដោយទឹកមុខស្រស់ស្រាយ ។

មនុស្សបំរើដែលកាន់សំបុត្ររបស់ពុទ្ធិស័ត្យជូនសំបុត្រនោះទៅលោកបាលិតដោយអាការគោរព ។

លោកបាលិតទទួលសំបុត្រហើយ អានសំបុត្រនោះរួចជូនឲ្យទៅឧបរាជសុពេលនឹង លោកនន្ទមើលទៀត ហើយនិយាយថា:

លោកឃើញទេ ខ្ញុំជំរាប់ហើយថាពុទ្ធិស័ត្យ មានសេចក្ដីនឹងខ្លួនណាស់ អញ្ជើញលោកអានសំបុត្រ១ច្បាប់នេះចុះ ហើយសូមប្រុងប្រៀបរៀបខ្លួនដើរផ្លូវទៅជាមួយនឹងខ្ញុំឥឡូវនេះ ។

នាងកាញ្ចនាដែលអង្គុយនៅក្នុងទីនោះដែរ លុះបានឮមនុស្សបំរើរបស់ពុទ្ធិស័ត្យ ពោលដូច្នោះ នាងត្រេកអរក្រៃលែង ។ អមាត្យបាលិតជូនសំបុត្រឲ្យសុពេលៗក៏អានខ្លាំងៗ ។ សេចក្ដីក្នុងសំបុត្រដែលពុទ្ធិស័ត្យបរិយាយរឿងរ៉ាវផ្សេងៗ ក្នុងរវាងដែលគេនៅក្នុងនគររាជគ្រឹះតាំងអំពីដើម

ដកបដល់បច់ ជាការផ្លាស់អារម្មណ៍ ដែលល្អក់កករហើយបើកផ្សាយទូវ ការស្មោះត្រង់ក្នុងចិត្ត ដោយពាក្យដែលបានស្តាប់នាំឲ្យកើតសេចក្តីអាណិតយ៉ាងខ្លោចចិត្ត ។

កូនស្រីលោកនន្ទិមិនអាចនឹងទប់ទឹកភ្នែកបាន ដោយនឹកតូចចិត្តចំពោះកាលវេលា ដែលបិទបាំងឃាំងឃុំមិនឲ្យជួបនឹងពុទ្ធស័ត្យមកជាវេលាយូរណាស់ហើយ ។

នន្ទិអមាត្យនឹងសុភេល កាលដឹងថា "ព្រះរាជានៃក្រុងរាជគ្រឹះទ្រង់ជ្រាបសេចក្តីបរិសុទ្ធរបស់ខ្លួនហើយ ព្រមទាំងអនុញ្ញាតឲ្យត្រឡប់ចូលមកកាន់នគរវិញដូច្នេះហើយ, នាំឲ្យមានការកន្ទុះរកក្នុងចិត្តពន់ពេក ។ សេចក្តីនឹករលឹកដល់ព្រះករុណាធិគុណ អំពីជាន់មុនមិនទាន់រលុបរលាយបាត់ទៅពីក្នុងចិត្តនៅឡើយ តែមិនអាចនឹងប្រតិបត្តិតាមព្រះរាជបំណងបានទេ ចាំថ្ងៃណាមួយនឹងទៅគាល់ព្រះអង្គ ថ្វាយសេចក្តីស្រឡាញ់ភក្តីឲ្យព្រះអង្គទ្រង់ជ្រាបថា នន្ទិអមាត្យនឹងបុត្តមានសេចក្តីអាឡោះអាល័យព្រះអង្គនៅឡើយ ដែលគិតដូច្នេះជាធម្មតារបស់បុគ្គលដែលធ្លាប់មានសេចក្តីស្រឡាញ់ភក្តីប៉ុណ្ណោះ បើជាបុគ្គលដែលប្រាសចាកគុណធម៌មុខតែស្អប់ខ្ពើមព្រះរាជា ហើយរកឱកាសនឹងតបស្នងវិញពុំខាន, អមាត្យនន្ទិនិយាយនឹងសុភេលដោយសំឡេងញ័រៗថា:

— កូនសម្លាញ់! ថ្ងៃដែលយើងរង់ចាំ ថាយើងនឹងត្រូវបរិសុទ្ធបានមកដល់ហើយ ឪពុកនឹកថា កូនគង់គិតដូចឪពុកដែរ កូនកុំបងចិត្តទោមនស្សស្អប់ខ្ពើមចំពោះព្រះរាជាឡើយ ។

– កុំបារម្ភឪពុក! ខ្ញុំមានសេចក្ដីស្រឡាញ់កក្ដីចំពោះព្រះអង្គនៅឡើយ តែថាការត្រឡប់ចូលទៅកាន់នគររាជគ្រឹះវិញនោះឃើញថា ជាការលំបាកពេក" សុរពលនិយាយដោយសេចក្ដីដឹងខ្លួនដូចបិតាហើយក៏អង្គុយស្ងៀម ។

ខាងក្រោយពីការអង្គុយស្ងៀមមួយស្របក់ អមាត្យបាលិតទើបអញ្ជើញបបួលសុរពលនឹងនន្ទិអមាត្យ:

–" សូមលោកឧបរាជ លោកនន្ទិនឹងបុត្ររបស់លោក ត្រូវទៅជាមួយនឹងខ្ញុំផង ឬទ្ធិស័ក្យគង់នឹងត្រេកអរណាស់ កាលបើបានជួបលោកហើយ, ចំពោះកាញ្ចនាត្រូវតែទៅកុំខាន" និយាយហើយលោកបាលិតក៏បែរទៅខាងកូនស្រីនៃលោកនន្ទិ ។

នាងកាញ្ចនា សូម្បីមានសេចក្ដីត្រេកអរយ៉ាងណា នាងក៏មិនសំដែងអាការឲ្យឃើញប្រាកដឡើយ តាមវិស័យរបស់ស្ត្រី ដែលស្រឡាញ់កេរ្តិ៍-ឈ្មោះ កិរិយារបស់នាងជាទីរីករាយរបស់មនុស្សក្នុងទីនោះក្រៃពេក ។

ក្នុងទីបំផុត ជនទាំងនេះ ក៏ព្រមព្រៀងគ្នានឹងចេញដំណើរទៅកាន់នគរវេសាលីក្នុងរវាងឆាប់ ៗ ខាងក្រោយដែលបានក្រាបបង្គំទូលលាព្រះរាជាហើយ ។

(មានត)

\+

\+ \+

.

## រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកវាងវៃឆ្លាសបើបានអាន<br>នឹងចេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ ។ |

## កណ្ឌទី ២៧

តាំងពីចូឆូប្រើទៀវលៀវឲ្យចេញតយុទ្ធនឹងអ៊ួនសៀវៗ ប្រើទៀវខាប់ចេញតទល់ រហូតដល់ចូឆូចាប់បានសំបុត្រនាយទាហានរបស់ខ្លួនដែលប្រែចិត្តទៅចូលនឹងអ៊ួនសៀវ ។

---

ចូឆូបានឮច្បាស់ក៏ខឹងខ្លាំងណាស់ ទើបចាត់ទៀវលៀវឲ្យលើកទាហានចេញទៅច្បាំងនឹងអ៊ួនសៀវ ។ ឃើញដូច្នោះក៏ចាត់ប្រើឲ្យទៀវខាប់លើកទាហានចេញមកតនឹងទៀវលៀវបាន ៥០ ក្បួន នៅមិនទាន់ចាញ់ឈ្នះគ្នា ។ ចូឆូឃើញទៀវខាប់ក្លាហានណាស់ក៏សរសើរថា: "ទៀវខាប់មានថ្វីដៃចំណានគួរគាប់សង្គ្រាមណាស់" ទើបប្រើខាំជូឡេចេញទៅជួយទៀវលៀវ ។ អ៊ួនសៀវឃើញដូច្នោះក៏ប្រើកោលាំចេញទៅជួយទៀវខាប់ ។ នាយទាហានទាំង៤នាក់នោះក៏ប្រយុទ្ធគ្នាទៅវិញទៅមកដោយគុនអាវុធដំរេហ៍សបីដូចគោមវិល ។ ចូឆូចាត់ឲ្យហៃហូទុននឹងហោហង់លើកទាហានម្នាក់ ៣.០០០ ចេញទៅជួយកាប់ខ្ទប់កងទ័ពអ៊ួនសៀវកុំឲ្យ

ដឹងខ្លួនទាន់ ។ សឹមផោយឃើញទាហានចូលមកវាយខ្លួនពីម្ខាង ផ្លូវនោះក៏ឲ្យផ្ទុះផាវជាសញ្ញាឡើង, ពួកទាហានដែលពួនបង្កប់ទាំង ២ បែក ក៏ស្រែករត់ចូលមក ។ ហៃហ៊ុយខ្ទុនទឹងហោហាងទប់មិនបាន ក៏ប្រាសនាំទាហានថយរត់ទៅក្រោយ ។ អ៊ួនសៀវបានចំណាប់ក៏លើកទ័ពដេញបណ្តោយទៅកាប់ចាក់ត្រូវពលទាហានចូចូរបួសពិការស្លាប់ជាច្រើន ទ័ពចូចូក៏បែកព្រាត់ព្រាយ ចូចូឃើញហួសលើសកំឡាំងនឹងទប់ពុំឈ្នះ ក៏ថយទ័ពត្រឡប់ទៅតាំងបន្ទាយនៅទីក្តុគួករ ។

អ៊ួនសៀវក៏លើកទ័ពតាមទៅ តាំងបន្ទាយជាប់ជិតគ្នានឹងបន្ទាយចូចូ ។ សឹមផោយនិយាយនឹងអ៊ួនសៀវថា នៅដំបន់គួករនេះជាទីចង្អៀតស្រួលណាស់ បើរិះគិតប្រើគំនិតប្រាំងវ៉ាយយកបន្ទាយគួករបានហើយ ស្រុកហ៊ូតោក៏នឹងវ៉ាយយកបានដោយងាយ សូមឲ្យលោកចាត់ទាហានទុករក្សាបន្ទាយតែ ១០ ម៉ឺនចុះ លើសពីនោះចាត់ឲ្យជញ្ជូនយកគាប់ដីមកគរជាកំពែងទប់ឲ្យខ្ពស់ឡើងជាងសេនបន្ទាយចូចូដោយជុំវិញ រួចឲ្យទាហានបាញ់ធ្នូបម្រុះចូលទៅក្នុងបន្ទាយចូចូ មុខជាចូចូនឹងការពារពុំឈ្នះប្រាសបែកទៅឯង បើយើងបានដំបន់គួករហើយក៏ដូចជាបានក្រុងហ៊ូតោដែរ ។ អ៊ួនសៀវយល់ឃើញពេញចិត្ត ក៏ឲ្យធ្វើតាមគំនិតដែលសឹមផោយគិតនោះ, ទាហានអ៊ួនសៀវតាំងតែជីកយកគាប់ដី ហាសិបកងជញ្ជូនមកចាក់គរជាប្រលប្រចល់ ។

ចូចូក្រឡេកទៅឃើញក៏ដឹងថា អ៊ួនសៀវឲ្យជញ្ជូនគាប់ដីមកចាក់ឲ្យខ្ពស់ឡើង ប្រយោជន៍នឹងឲ្យបាញ់ធ្នូបម្រុះទៅក្នុងបន្ទាយនៃខ្លួន, ចូចូ

កំបង្គាប់ទាហានឲ្យលើកទៅវាយបំបែកទ័ពអ្នួនសៀវ ដែលកំពុងដឹកជញ្ជូនអាហារដីនោះកុំឲ្យធ្វើការបាន, ទាហានបួនក៏លើកចេញទៅធ្វើតាមបង្គាប់ ។ សិមផៅយកតកបារម្មណ៍ខ្លាចក្រែងបួនប្រើទាហានមកកំបាត់កំចាយមិនឲ្យធ្វើការបាន ក៏បែងចែកទាហានឲ្យនៅរក្សាបន្ទាយ ៥ ម៉ឺន សុទ្ធតែកាន់ធ្នូបំរុងចាំបាញ់មិនឲ្យទាហានបួនលើកចេញពីកំផែងបន្ទាយ ។ ពួកទាហានអ្នួនសៀវដែលដឹកជញ្ជូនអាហារដីនោះ ប្រហែល ១០ ថ្ងៃមកហើយ ទំនប់ដីកំបើនខ្ពស់ឡើងជុំវិញបន្ទាយបួនបាន ៥០ អន្ទើ ជិតបន្ទាយបួនប្រហែល ៥ ព្យាម (គឺ១០ ម៉ែត្រ) អ្នួនសៀវក៏ឲ្យទាហានធ្នូឡើងទៅនៅលើទំនប់ដីគ្រប់កន្លែង ហើយបង្គាប់ទុកថា "បើឮសំឡេងផាវក៏ឲ្យព្រមគ្នាបាញ់ធ្នូចម្រុះទៅកំផែងបន្ទាយបួន" ទាហានទាំងពួងនោះក៏តាមបង្គាប់អ្នួនសៀវ ។

ឯទាហានបួនដែលនៅកំផែងបន្ទាយនោះ លុះឃើញទាហានអ្នួនសៀវបាញ់ធ្នូចម្រុះមកជុំវិញបន្ទាយ ក៏នាំគ្នាយកស្បែកសេះទីងពាងបាំងកំផែងខ្លះៗ: គេចវេះពួនជ្រកនៅកំផែងរណ្ដៅលុងកំផែងបន្ទាយខ្លះ ។ ទាហានអ្នួនសៀវឃើញដូច្នោះ ក៏បបួលគ្នាទះដៃសើចចំអកឡកឡឺយបញ្ឈឺចិត្ត ។ បួនឃើញទាហានទាំងពួងបែកខ្វែកគ្នា ក៏ប្រឹក្សានឹងនាយទាហានទាំងអស់ថា អ្នួនសៀវធ្វើបាយយ៉ាងនេះ នរណានឹងគិតគំនិតកែខ្វែងដូចម្ដេចបាន ? ។ ឡៅហ៊្វូឆ្លើយថា ឥឡូវនេះទាហានអ្នួនសៀវនៅលើទីខ្ពស់ បើនឹងលើកកងទ័ពយើងឡើងទៅវាយចំលាយចេញពុំបាន ខាងយើងមិញក៏គិតជាងគេណាស់ បើដូច្នេះសូមឲ្យធ្វើបក្រយន្ត

នាំរទេះផ្ទុកថ្មសិលារុញទៅឲ្យល្មមផុតបន្ទាយជិតទំនប់ដីនោះឲ្យបាន៤ទិស រួចឲ្យទាញខ្សែយន្តឲ្យចក្របក់ទាត់ដុំថ្មនោះឲ្យខ្ទាតឡើង មុខជាត្រូវទាហានអ៊ួនសៀវខ្ទាត់ខ្ចាយពីលើទំនប់ដីនោះមិនខាន ។ ចូឆ្គយល់ឃើញស្រួលក៏ឲ្យឡោហ៊ូធ្វើចក្រយន្តហើយយករទេះស្បៀង ២០០ មកផ្ទុកថ្មសិលាឲ្យពេញរទេះមួយៗ ។ រួចយកចក្រនោះដាក់ក្នុងរទេះត្រៀមទុកឲ្យព្រមក្នុងពេលកណ្ដាលយប់ស្ងាត់ លុះព្រឹកឡើងឃើញទាហានអ៊ួនសៀវឡើងបាញ់ធ្នូពីលើទំនប់ដី ចូឆ្គក៏ឲ្យទាហានរុញរទេះដែលផ្ទុកដុំថ្មនោះ ១ ទិស ៥០ រទេះ ចេញទៅផុតបន្ទាយជិតគំនរដីប្រហែល ៣ ព្យាមបាយ ហើយឲ្យកន្ត្រាក់ខ្សែយន្តឡើងព្រមគ្នា ចក្រយន្តនោះក៏បក់ទាត់ដុំថ្មនោះខ្ទាតឡើងទៅលើគំនរដី ត្រូវទាហានអ៊ួនសៀវរបួសពិការស្លាប់អស់ជាច្រើន ណាដែលរស់នៅក៏មិនអាចនឹងនៅក្នុងទីនោះបាន សឹងតែថយរត់ចុះទៅលើគំនរដីនោះអស់ឥតមានសល់ម្នាក់ឡើយ ។

អ៊ួនសៀវឃើញដូច្នោះ ក៏ពិគ្រោះនឹងសឹមផោយថា ទាហានយើងដែលឡើងទៅនៅលើទំនប់ដីនោះ ក៏ធ្វើអន្តរាយចូឆ្គមិនបាន ត្រឡប់រត់ចុះមកអស់ដូច្នេះ តើអ្នកនឹងគិតប្រការម្ដេចទៀត ? ។ សឹមផោយឆ្លើយថា កលឧបាយខ្ញុំបាទនៅមានមួយយ៉ាងទៀត សូមឲ្យលោកប្រមូលទាហានរកជីកឧមង្គទំលុះចូលទៅក្នុងបន្ទាយចូឆ្គ កាលណាបានសម្រេចហើយដល់ពេលកណ្ដាលយប់ស្ងាត់ ត្រូវបញ្ចូលទាហានឲ្យចូលទៅតាមប្រហោងឧមង្គ ហើយទំលុះឡើងទៅឲ្យចំកណ្ដាលបន្ទាយចូឆ្គ ដេញកាប់សម្លាប់ទាហានចូឆ្គក្នុងបន្ទាយឲ្យវិនាសខ្ចាត់ខ្ចាយទៅ មុខជាទាហាន

កូនបន្ទាយមិនដឹងខ្លួនទេ ។ អ៊ួនសៀវយល់ឃើញត្រូវ ក៏ឲ្យប្រមូលទាហានមកជីកទម្លុងក្រោមបន្ទាយជិតគំនរដី ។ ទាហានចូឆូឃើញដូច្នោះក៏ទៅជំរាបចូឆូថា ឥឡូវអ៊ួនសៀវឲ្យទាហានជីកដីទំលុះនៅក្រោយគំនរដីជាច្រើនណាស់ នឹងធ្វើប្រការម្ដេចបើមិនច្បាស់? ។ ចូឆូឮដូច្នោះក៏នឹកពិតាល់សង្ស័យ ទើបសួរទៅឡៅហ៊ួថា ដែលអ៊ួនសៀវធ្វើការដូច្នោះអ្នកយល់បានឬទេ? ។ ឡៅហ៊ួថា អ៊ួនសៀវនឹងគិតធ្វើការយកជ័យជំនះយើងពីជម្រេះដែលចេញមុខនោះ ឃើញជាមិនបានហើយ បានជាធ្វើកលឧបាយឲ្យទាហានជីកដី ប្រាថ្នាដើរផ្លូវទម្លុងចូលមកធ្វើអន្តរាយបន្ទាយយើង បើដូច្នោះសូមឲ្យលោកប្រមូលទាហានមកជីករំលុងស្នាក់ឲ្យជ្រៅពីក្រោមបន្ទាយ មុខជាទាហានអ៊ួនសៀវធ្វើការមកមិនរហូតបាន ។ ចូឆូយល់ត្រូវផង លុះវេលាយប់ស្ងាត់ក៏ប្រមូលទាហានមកជីករំលុងតាមពាក្យឡៅហ៊ួថា ។

ឯទាហានអ៊ួនសៀវនោះ លុះជីកទម្លុងមកដល់ជិតជើងបន្ទាយចូឆូ ក៏ពារទៅលើរំលុងដែលចូឆូឲ្យជីកស្នាក់ទុកនោះ នឹងជីកទំលុះចេញទៅទៀតក៏ពុំបាន ព្រោះរំលុងធំជ្រៅពន្ធឹកណាស់ ទើបនាំគ្នាទៅជំរាបអ៊ួនសៀវវិញ ។ អ៊ួនសៀវបានឮទាហានប្ដឹងដូច្នោះ ក៏មិនដឹងបើនឹងគិតធ្វើដូចម្ដេចទៅទៀត ក៏ឲ្យថយទ័ពត្រឡប់ទៅតាំងបន្ទាយឆ្ងាយអំពីដំបន់គួត ចម្ងាយប្រហែល ៣០០សិន (គឺ ១៦ គីឡូម៉ែត្រ) ។

ឯចំណែកចូឆូតាំងតែការពារបន្ទាយកងទ័ពមិនចេញតតាំងច្បាំងនឹងអ៊ួនសៀវតាំងពីខែភទ្របទរហូតដល់ខែអស្សុជ ក៏មិនឃើញអ៊ួនសៀវចេញច្បាំង

គិតនឹងថយទ័ពទៅស្រុកហ៊ូតោវិញ ទទួលស៊ីហ៊ុងគងក្រវែលចាប់ទាហានអ៊ួនសៀវបានម្នាក់ ក៏នាំខ្លួនទៅជូនចូឆូ ។ សួរទាហានយកការថាអ៊ួនសៀវប្រើអ្នកឯងឲ្យទៅណាមកណាចូលប្រាប់យើងតាមត្រង់ បើឯងភូតភរកុហកយើងឲ្យកាត់ក្បាលចេញឥឡូវនេះ ។ ទាហាននោះខ្លាចក៏ឆ្លើយប្រាប់តាមត្រង់ថា ខ្ញុំបាទជាបាវហ៊ានបេង អ៊ួនសៀវប្រើហ៊ានបេងឲ្យជញ្ជូនស្បៀងមកឲ្យកងទ័ពត្រឡប់មកជិតនឹងដល់ទីបន្ទាយហើយ ហ៊ានបេងប្រើឲ្យខ្ញុំបាទស្រូតមកស៊ើបការជាមុន ។

ស៊ុនហ៊ីវឮដូច្នោះ ក៏ជំរាបចូឆូថា ហ៊ានបេងនេះជាមនុស្សមានថ្វីដៃខ្លាំងពូកែក៏ពិតមែន តែគ្មានដំរិះប្រាជ្ញាទេ, ប្រសិនបើលោកចាត់ការឲ្យទាហានឯកលើកពលយោធាតែ ៣០០០ ទៅចាំស្ទាក់ដណ្តើមយកស្បៀងអ៊ួនសៀវ មុខជានឹងបានដោយងាយ អ៊ួនសៀវគង់តែនឹងបែកខ្វែកខូចស្បៀងអាហារអស់ ។ ចូឆូថា ចុះយើងនឹងឲ្យទាហានណាទៅស្ទាក់ធ្វើការនេះបាន? ស៊ុនហ៊ីវថា ត្រឹមតែថ្វីដៃស៊ីហ៊ុងក៏ល្មមតស៊ូនឹងហ៊ានបេងបានហើយ ។ ចូឆូក៏យល់ឃើញព្រមផង ទើបចាត់ទាហាន ៣០០០ ឲ្យស៊ីហ៊ុង នឹងស៊ូហ្វួនកាន់គាប់ទៅផង ឲ្យលើកកងទ័ពទៅតាំងចាំស្ទាក់នៅត្រង់ចន្លោះផ្លូវច្រកភ្នំ ដែលហ៊ានបេងនឹងនាំស្បៀងមកនោះ ហើយប្រើទៀវលៀវនឹងខៅជូឲ្យលើកទាហាន ៥០០០ ទៅតាមក្រោយ ទាហានទាំងនោះក៏លើកទៅតាមបង្គាប់ ។ លុះវេលាកណ្តាលអធ្រាត្រយប់ស្ងាត់ ហ៊ានបេងក៏នាំរទេះស្បៀង ២០០០ មកដល់ច្រកភ្នំនោះ ស្រាប់តែក្រឡេកទៅឃើញស៊ីហ៊ុងបញ្ឈរសេះនៅទទឹងផ្លូវពីមុខ ហ៊ានបេងក៏បរសេះបង្រុះ

ចូលទៅប្រយុទ្ធនឹងស៊ីហ៊ុងទាំងអំណាច នៅមិនទាន់បាញ់ឈ្នះ ស៊ូហ៊ួន ឃើញដូច្នោះក៏លើកទាហានចូលទៅព្រួតពីក្រោយថែមទៀត សម្លាប់ទាហានហ័នបេងស្លាប់អស់ជាច្រើន ហើយឲ្យទាហានយកភ្លើងដុតរទេះស្បៀងនោះឆេះអស់ ៗ ហ័នបេងឃើញស៊ូហ៊ួនដេញចាប់ទាហានចូលមក ឃើញថាលប់លើសកំឡាំង ទប់ទល់ពុំឈ្នះ ក៏បរសេះរត់ត្រឡប់ទៅក្រោយវិញ ទាហានក៏បាក់ទ័ពបណ្ដោយទៅបែកខ្ញែកខ្ចាត់ខ្ចាយអស់ ៗ

ឯអ៊ួនសៀវនៅក្នុងបន្ទាយ ឃើញពន្លឺភ្លើងឆេះឡើងខាងទិសឯលិច ក៏នឹកសង្ស័យណាស់ ទទួលទាហានដែលបែកទ័ពនោះរត់ទៅដល់ ប្ដឹងសេចក្ដីឲ្យអ៊ួនសៀវដឹង អ៊ួនសៀវក៏ភ័យស្លុតចិត្ត ទើបប្រើទៀវទាប់នឹងគោលាំ នាំទាហានលើកទៅជួយ ស្កាត់ពារយទ័ពចួចដែលដុតរទេះស្បៀងនោះ ទៀវទាប់នឹងគោលាំក៏លាអ៊ួនសៀវនាំទាហានកងទ័ពទៅចាំស្កាត់កណ្ដាលផ្លូវ ៗ

ឯស៊ីហ៊ុងនឹងស៊ូហ៊ួន លុះដុតរទេះស្បៀងឆេះអស់ហើយ ក៏លើកទ័ពត្រឡប់មកតាមផ្លូវ ទទួលប្រទះនឹងទៀវទាប់, គោលាំ ៈនៅចាំស្កាត់កណ្ដាលផ្លូវនោះ ក៏ចូលប្រយុទ្ធគ្នាជាពន្លឹក ទទួលទៀវលៀវទៅធូលើកទ័ពទៅជួបប្រទះគ្នាទៀត ក៏បរពលចូលប្រយុទ្ធគ្នាជាប្រឡូបល់ គោលាំនឹងទៀវទាប់តទល់ពុំឈ្នះក៏ប្រាសបែកទ័ពទៅ ស៊ីហ៊ុង, ទៅធូ, ស៊ូហ៊ួន ក៏ដេញកាប់កងទ័ពអ៊ួនសៀវស្លាប់វិនាសច្រើនណាស់ ហើយក៏លើកត្រឡប់ទៅបន្ទាយគួតវិញ ចូលទៅជំពបចួចៗ ក៏មានអំណរណាស់ ឲ្យបំណាច់រង្វាន់ដល់ស៊ីហ៊ុងនឹងសេនាទាហានទាំងពួងជាច្រើន ៗ

ឯហ៊ានបេនីរត់ទៅដល់បន្ទាយ ក៏នាំយកសេចក្ដីនោះទៅជំពប់អ៊ួនសៀវ ៗ ខឹងណាស់ ទើបបង្គាប់ឲ្យចាប់ខ្លួនហ៊ានបេនយកទៅប្រហារជីវិត ។ ចំប្រើក្បាននឹងសេនាទាហានទាំងពួងក៏នាំគ្នាអង្វរសូមទោស ។ សឹមផោយជំពប់អ៊ួនសៀវថា: ឯការធ្វើសឹកសង្គ្រាមនេះអាស្រ័យនឹងមាននូវស្បៀងអាហារជាកំឡាំង ឥឡូវបើស្បៀងអាហារយើងដែលលាក់ទុកនៅដំបន់អ៊ួទៅនោះ ខ្ញាបក្រេងបុច្ចូងនឹងនឹងលើកទ័ពទៅដណ្ដើមយកបានយើងក៏នឹងខ្វះខាតស្បៀងអាហារ ឃើញថានឹងធ្វើការសង្គ្រាមតទៅឲ្យរហូតពុំបាន ហេតុនេះ សូមលោកចាត់ទាហានដែលមានថ្វីដៃទៅរក្សាដំបន់អ៊ួទៅទុកឲ្យមាំមួន ទើបយើងនឹងបានអាស្រ័យអាហារជាកំឡាំងតទៅ ។ អ៊ួនសៀវថា ការត្រង់ណេះអ្នកកុំវិតក្កព្រួយឡើយ ឯដំបន់អ៊ួទៅនោះយើងបានចាត់ចែងជាមាំមួនទុកស្រេចហើយ ឲ្យអ្នកស្រុកទៅស្រុកងៀបកុនដែលជាស្រុកចុះឡើងស្ដាប់បង្គាប់យើង ឲ្យស្រូតរូតបញ្ជូនស្បៀងអាហារមកឲ្យកងទ័ពជាប្រញាប់កុំឲ្យខ្វះខាតគាន់ ។ សឹមផោយក៏លាអ៊ួនសៀវទៅកាន់ស្រុកងៀបកុន លុះសឹមផោយទៅផុតហើយអ៊ួនសៀវក៏ចាត់អីខេងជានាយទាហានទ័ពធំ នឹងកុយជួន,ជិនហ៊ាន,គីជួ,លីអ៊ុយហាង,ទៀវយ៉ូយ ឲ្យលើកទាហាន ២ ម៉ឺនទៅនៅរក្សាដំបន់អ៊ួទៅ ។ ខណៈកាលអីខេងទៅនៅដំបន់អ៊ួទៅហើយ ក៏មិនបានយកចិត្តទុកដាក់ក្នុងកិច្ចការពារការផែនដីអ៊ួសោះ គិតតែពីនាំពួកកៀនផឹកស្រាស្រវឹងជានិច្ច ពោះបើបើអ្នកឯណានិយាយទទឹងតាស់ក៏ត្រឡប់នៅជាក្រោធខឹងវិញ ហើយពោលពាក្យទ្រគោះមើលងាយជាច្រើន ទាហានទាំងពួងក៏សឹងតែ

គោតខ្លាចអីខេងមិនអាចហាមឃាត់ឬរំលឹកបានឡើយ ។

ឯចូឆូដែលតាំងទ័ពនៅដំបន់គួតនោះ ស្បៀងអាហារក៏កាន់តែស្តួចស្តើងណាស់ ចូឆូក៏ប្រើទាហានកាន់សំបុត្រទៅឲ្យស៊ុនហុកឯស្រុកហ៊ូតោ, សេចក្តីសំបុត្រនោះថា "កងកងទ័ពយើងមានការខ្វះខាតស្បៀងអាហារច្រើនណាស់ហើយ ឲ្យស៊ុនហុកខំរិះគិតបាត់ឲ្យនាំស្បៀងទៅជាប្រញាប់កុំឲ្យខ្វះខាតទាន់" ។ ទាហានទទួលសំបុត្រហើយក៏លាចូឆូទៅចេញពីបន្ទាយចម្ងាយប្រហែល ៣០០ សិន (១០គីឡូម៉ែត្រ) ពួកទាហានកងត្រវែលអ៊ួនសៅ ក៏ចាប់ខ្លួនបានហើយនាំយកទៅឲ្យខៅហ៊ីវដែលជាទីប្រឹក្សាធំរបស់អ៊ួនសៅ ។

ខៅហ៊ីវនេះ កាលនៅពីកំឡោះនៅឡើយនោះ ជាភឿនសំឡាញ់នឹងចូឆូ លុះចូឆូបែកបាក់ទៅធ្វើរាជការក្នុងស្រុកហ៊ូតោ ខៅហ៊ីវក៏ចូលមកនៅធ្វើរាជការនឹងអ៊ួនសៅ, កាលនាយកងត្រវែលចាប់ទាហានចូឆូមកឲ្យ ខៅហ៊ីវឲ្យមនុស្សត្រួតមើលឃើញសំបុត្រដែលចូឆូឲ្យទៅដល់ស៊ុនហុក ខៅហ៊ីវក៏នាំយកសំបុត្រនោះទៅជំរាបអ៊ួនសៅហើយថា ចូឆូតាំងកងទ័ពនឹងយើងក៏យូរអង្វែងណាស់មកហើយ ទាល់តែអស់ស្បៀងអាហារ, ស្រុកហ៊ូតោក៏នៅចំនេរគ្មាននរណាការពារជាមាំមួន សូមឲ្យលោកបែងទាហានលើកទៅក្រលុកវាយយកស្រុកហ៊ូតោ បើជាបានស្រុកហ៊ូតោហើយ ចូឆូក៏នៅក្នុងកណ្តាប់ដៃយើងតែម្តង ។

(មានត)

## កាំណត់ពីដ ប្រវត្តិការណ៍

# ពិធីបុណ្យកតញ្ញូកតវេទី

## ចំពោះសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ល្វី-ឯម

## របស់សមណៈនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

### សោក ឯង-ប៉ង់ ប្រមូលរៀបរៀង

---

ថ្ងៃសៅរ៍ទី ១៥ ធ្នូ ១៩៥៦ វេលាម៉ោង៧យប់ ក្នុងបរិវេណវត្តលង្កា សង្កាត់លេខ ៦ ក្រុងភ្នំពេញ មានធ្វើពិធីបុណ្យកតញ្ញូកតវេទីចំពោះសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សាគណៈមហានិកាយ ក្រោមការចាត់ចែងនៃសមណៈនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

ក្នុងឱកាសនោះ យើងសង្កេតឃើញនូវពួកពុទ្ធបរិស័ទ្យដែលបានអញ្ជើញទៅជួបជុំគឺ លោក ម៉ម-វ៉ែម ប្រធានគណៈកម្មការវត្ត, លោក ប៉េ-យាន, លោក លី-គីមសា៊, លោក ឈឹម-ស៊ុម ព្រមទាំងពុទ្ធបរិស័ទទាំងស្រីទាំងប្រុសជាច្រើននាក់ ដែលយើងសូមអភ័យទោសដោយមិនបានកត់នាមក្នុងទីនេះ ។ ចំណែកព្រះសង្ឃមានព្រះតេជព្រះគុណព្រះមហាព្រហ្មមុនី ទេព-អ៊ូ, ព្រះតេជព្រះគុណព្រះញាណវីរៈ វណ្ណ-សាត ជាដើម បាននិមន្តទៅជួបជុំក្នុងទីនោះ ។

នៅម៉ោង ៨, ១០ នាទី សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ បាននិមន្តមកដល់ទីនោះ ដោយមាន

សមណៈនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ឈរគោរពហូរហែតាំងពីខ្លោងទ្វាររហូតដល់ចាំកនៅមុខរោងក្រៃ ។ សម្តេចបានឈប់បង្អង់សំណេះសំណាលនឹងក្រុមសមណៈនិស្សិតទាំងឡាយមួយស្របក់ រួចទើបនិមន្តឡើងទៅថ្វាយបង្គំសម្តេចព្រះធម្មលិខិត លុះសួរអំពីអាការរោគសម្តេចហើយក៏និមន្តទៅឯព្រះវិហារ ។

ក្រោយដែលបានជួបជុំក្រុមនិស្សិតជាសមណៈ និងពុទ្ធបរិស័ទទាំងឡាយហើយ ព្រះអាចារ្យ ស៊ុន-សារៀម និស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតថ្នាក់ទី ៤ ថ្លែងសុន្ទរកថារៀបរាប់អំពីឧបការគុណ នៃសម្តេចព្រះធម្មលិខិតជាសង្ឃបិតា ។ បន្ទាប់មក ព្រះតេជព្រះគុណព្រះពុទ្ធវង្ស កៅ-ស៊ឹម ថ្លែងសុន្ទរកថាតបវិញ ។

លុះចប់សុន្ទរកថាហើយ សម្តេចព្រះមហាសុមេធាធិបតីបានសំដែងធម៌យ៉ាងពីរោះអស្ចារ្យ នាំឲ្យក្រុមសមណៈនិស្សិតនិងពុទ្ធបរិស័ទទាំងឡាយជ្រះថ្លារីករាយជាខ្លាំង ។

ថ្ងៃអាទិត្យទី ១៦ ធ្នូ ១៩៥៦ វេលាព្រឹកម៉ោង ៨,១៥ នាទី បាននិមន្តព្រះសង្ឃ ១៥០ អង្គទទួលបង្ហាន់បិណ្ឌបាត ។

ដល់ម៉ោង៧ចប់ និមន្តព្រះសង្ឃបំរើនព្រះបរិត្តមួយលើកទៀត រួចនិមន្តព្រះអាចារ្យ ទៀវ-ជុំ សំដែងធម៌; មុននឹងសំដែង ព្រះអាចារ្យ ស៊ុន-សារៀម ថ្លែងសក្ខីថាមួយក្នុងនាមនៃក្រុមនិស្សិតទាំងអស់យ៉ាងក្បោះក្បាយ ។

ពិធីបុណ្យនេះចប់នៅម៉ោង១២,៣០នាទី ។

× × ×

រីសុន្ទរកថា និងសង្កថាព្រះអាចារ្យ ស៊ិន-សារឿម ព្រមទាំងសុន្ទរកថា ព្រះតេជព្រះគុណព្រះពុទ្ធវង្ស កៅ-ស៊ុម យើងនឹងស្រង់យកមកចុះជូនអ្នកអាន ដូចតទៅនេះ ៖

## សុន្ទរកថាព្រះអាចារ្យ ស៊ិន សារឿម

ថ្លែងក្នុងនាមនៃនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

សូមគោរព

- សម្ដេចព្រះធម្មលិខិតឧត្ដមប្រឹក្សាគណៈមហានិកាយ ,
- សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ,
- ព្រះថេរានុត្ថេរៈទាំងឡាយ ,

សូមជំរាបអស់លោក-អ្នកជាពុទ្ធបរិស័ទទាំងឡាយ !

ខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងក្នុងនាមនៃនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នូវសេចក្ដីសោមនស្សរីករាយដ៏ក្រៃលែង ចំពោះសម្ដេច, ព្រះតេជព្រះគុណក្រុមជំនុំព្រះត្រៃបិដក ដែលមានព្រះតេជព្រះគុណ វ័ណ្ណ-សាឌុំ ជាដើម, ព្រះតេជព្រះគុណសាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត មានព្រះតេជព្រះគុណ ព្រះមហាព្រហ្មទី ទេព-អ៊ូ ជាដើម, អស់លោកនៅក្រសួងធម្មការ និងអស់លោក-អ្នកសប្បុរសជើងវត្តលង្កា ជាដើម ដែលបាននិមន្តបានអញ្ជើញមកក្នុងពិធីបុណ្យនេះ ។

ខ្ញុំព្រះករុណាទាំងឡាយជាក្រុមសិស្សពុទ្ធិកវិទ្យាល័យ និងជាសិស្សនៃពុទ្ធិកបឋមសិក្សាខ្លះ ជាចៅសិស្សរបស់សម្ដេច មានសេចក្ដីរំភើបញាប់-

ញ៉ាំងគក់ស្លុតរន្ធត់ក្នុងចិត្តក្រៃពេក ចំពោះសម្ដេចជាអយ្យកាចារ្យក្នុងវេលាដែលសម្ដេចមានជរាពាធប្រចាំព្រះកាយ ព្រោះខ្ញុំព្រះករុណាទាំងឡាយ ទោះបីពុំមែនជាសិស្សផ្ទាល់ទាំងអស់គ្នាក៏ដោយ, ប៉ុន្តែជាអ្នកបានទទួលមរតកដ៏បរិសុទ្ធ ពោលគឺចំណេះវិជ្ជាខាងផ្លូវព្រះពុទ្ធសាសនាតពីសម្ដេចមកដែរ ។ ខ្ញុំព្រះករុណាទាំងឡាយបានកើតឡើងក្នុងសម័យដែលសាលាបាលីរង, សាលាបាលីជាន់ខ្ពស់ និងពុទ្ធសាសនបណ្ឌិត្យមានសេចក្ដីចំរើនហើយក៏ពិតមែន, ប៉ុន្តែខ្ញុំព្រះករុណាទាំងឡាយបានដឹងប្រវត្តិខ្លះតាមវាចានៃគ្រូអាចារ្យតមកថា ៖

— ក្នុងអតីតកាលប្រទេសកម្ពុជា ពុំមានសាលាសម្រាប់សិក្សាទូវសាស្ត្រាបាលីនិងធម្មវិន័យទេ ព្រមទាំងពុំមានអ្នកប្រាជ្ញណាមួយអាចចាត់ការបង្រៀនឲ្យមានរបៀបរៀបរយបានឡើយ ។ ដល់មកឆ្នាំ១៩១៤ទើបអ្នកប្រាជ្ញទាំងឡាយមានសម្ដេចព្រះធម្មលិខិតឧត្តមប្រឹក្សាព្រះនាម ល្វី-ឯម នេះ និងសម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត ដែលគង់នៅចំពោះមុខខ្ញុំព្រះករុណាទាំងអស់នេះជាដើម បានសុំឲ្យព្រះរាជរដ្ឋាភិបាលបង្កើតសាលាបាលីជាន់ខ្ពស់ឡើង បានចាត់ការបង្រៀនដល់សមណៈនិស្សិតទាំងឡាយ ឲ្យរៀនចេះដឹងដោយងាយរហូតមកដល់សម័យនេះ ។

— តាំងពីសាលាបាលីជាន់ខ្ពស់កើតឡើង អធិករណ៍ធំ ៗ ខាងផ្លូវពុទ្ធសាសនា ដូចជាសង្គ្រាមសាសនាមួយកើតឡើងក្នុងប្រទេសកម្ពុជា សម្ដេចទាំងពីរព្រះអង្គនេះជាធម្មសេនាបតីព្រមទាំងព្រះសង្ឃជាសហការីឯទៀតផង បានកំចាត់អធិករណ៍នោះឲ្យរលត់រលាយទៅ ។

វត្តលង្កានេះសោតក៏ហាក់ដូចសមរភូមិមួយយ៉ាងធំក្នុងប្រទេសកម្ពុជាដែរ, តែសម្តេចបានសាងអាវុធគឺសៀវភៅធម្មវិន័យជាច្រើនច្បាប់ សរសេរបោះពុម្ពចែកជាធម្មទានច្រើនទៀត ៗ ទីវត្តនេះក្លាយទៅជាវិជ្ជាស្ថានមួយដ៏ឧត្តមយ៉ាងក្រៃលែង ។

– ក្នុងឆ្នាំ ១៩២៥ សម្តេចបានឋានៈជាក្រុមប្រឹក្សាក្នុងការបង្កើតព្រះរាជបណ្ណាល័យ ក្នុងឆ្នាំ ១៩២៩ សម្តេចបានទទួលឋានៈជាអធិបតីក្រុមជំនុំព្រះត្រៃបិដកដែលជាថ្មើមប្រមាត់នៃព្រះពុទ្ធសាសនា, ក្នុងឆ្នាំ ១៩៣០ សម្តេចបានជាក្រុមប្រឹក្សាក្នុងការបង្កើតពុទ្ធសាសនបណ្ឌិត្យ ក្នុងប្រទេសកម្ពុជា ។

– សម្តេចបានបង្កើតសាលាបាលីរង ក្នុងវត្តលង្កាមុនវត្តឯទៀតទាំងអស់ក្នុងប្រទេសកម្ពុជា, ទោះបីសាលានេះនៅក្រៅផ្លូវការក៏ដោយ សម្តេចក៏ទំនុកបំរុងឲ្យបានសេចក្តីចំរើនដូចជាសាលាក្នុងផ្លូវការដែរ, មានសិស្សរាប់រយរូប រៀនក្នុងមួយឆ្នាំ ៗ ក្នុងសម័យនោះ ។ សាលាបាលីរងវត្តលង្កានេះឯង ជាគំរូមួយឲ្យវត្តឯទៀតក្នុងព្រះរាជាណាចក្រ មានវត្តពោធិ៍អណ្តែតក្នុងខេត្តកំពង់ឆ្នាំងជាដើមយកតម្រាប់តាម ។

– វត្តឯទៀតបានបង្កើតសាលាបាលីរងបាន ២-៣ វត្តហើយ សម្តេចក៏បានប្រជុំពិគ្រោះជាមួយនឹងសហការីទាំងឡាយ មានសម្តេចព្រះមហាសុមេធាធិបតីជួន-ណាតដែលគង់នៅនេះជាដើម បានសម្រេចមូលមតិថាគួរតែបង្កើតសាលាបាលីរងគ្រប់ទីរួមខេត្តទាំង ១៤ ឲ្យមានក្របខណ្ឌដូចសាលាបឋមសិក្សា បារាំង-ខ្មែរ, ប៉ុន្តែការនេះពុំបានសម្រេចគ្រប់ខេត្ត

ដូចបំណងឡើយ បានត្រឹមតែសាលាបាលីរង៍ឲ្យមានក្នុងវត្តមួយ ៗ ដែលលោកគ្រូចៅអធិការវត្តសព្វព្រះទ័យឲ្យតាំង ។

— តាំងពីឆ្នាំ ១៩៣៣ ដែលសាលាបាលីរង៍វត្តនេះកើតឡើងបានចូលក្នុងផ្លូវការហើយ កុលបុត្រអ្នកសិក្សាក៏រឹតតែកើនចំនួនឡើងរាប់ពាន់រាប់ម៉ឺនរូបគឺទាំងខ្ញុំព្រះករុណាគ្រប់គ្នានេះផង ទាំងសិក្ខាកាមកុលបុត្រឯទៀតដែលពុំបានមកក្នុងទីនេះផង ក៏សុទ្ធតែបានបំណេះវិជ្ជាដុះដាលអំពីសាលាបាលីរង៍នោះៗទាំងអស់ ។

ឥឡូវនេះ ខ្ញុំព្រះករុណាទាំងអស់គ្នាជានិស្សិតពុទ្ធិកវិទ្យាល័យព្រះសុ-រាម្រឹតនិងនិស្សិតពុទ្ធិកបឋមសិក្សាខ្លះ ទោះបីពុំបានរៀនផ្ទាល់ក្នុងសំណាក់សម្តេចក៏មែន ប៉ុន្តែឈ្មោះថាបានទទួលមតិកដ៏បរិសុទ្ធមកអំពីសម្តេច ។

ចំណែកសម្តេច ទោះបីឥឡូវនេះពុំបានទទួលកាន់កាប់សាលាទាំងនោះក៏មែនពិតហើយ, ប៉ុន្តែសម្តេចនៅតែមានមេត្តាចិត្តផ្សាយគ្រាលទៅលើសាលាទាំងនោះ ដូចជាទឹកអម្រឹតរសស្រោចស្រប់លើខ្ញុំព្រះ-ករុណាគ្រប់គ្នាឲ្យដុះដាលពុំមានអាក់ខានឡើយ ។

បពិត្រសម្តេច ?

សម្តេចជាសង្ឃបិតាមួយព្រះអង្គយ៉ាងឆ្នើម, សម្តេចមានព្រះទ័យដ៏បរិសុទ្ធិចំរើនជ្រោមជ្រែងព្រះពុទ្ធសាសនា ក្នុងពេលដែលអន់ទន់ខ្សោយរយៈកាលយាក គឺខ្សោយទាំងការប្រតិបត្តិទាំងការសិក្សា ដរាបដល់មានកុលបុត្រ ប្រតិបត្តិសិក្សាពេញបន្ទុកឡើងក្នុងប្រទេសកម្ពុជា ។

ព្រះគុណដ៏ធំអស្ចារ្យ ដូចបានពណ៌នារៀបរាប់ខាងលើទាំងអស់នេះ

ហើយ ដែលបណ្ដាលឲ្យខ្ញុំព្រះករុណាជាសមណៈសិស្សទាំងអស់គោរព
ព្រមទាំងទឹកតុំក្ខេប ។

ក្នុងបច្ចុប្បន្ននេះ សម្ដេចត្រូវដកពលមកញាំញីព្រះកាយឲ្យទ្រុឌ-ទ្រោមស្គាំងស្គមហួសប្រមាណ ហើយជរាពាធនោះបានសំដែងអាការដ៏គ្រៀវក្រាសំបើម ។ ប៉ុន្តែក្នុងខណៈនោះ ព្រះករុណាជាអម្ចាស់ជីវិតទាំងពីរព្រះអង្គនិងសម្ដេចព្រះឧបយុវរាជ ទ្រង់មានព្រះរាជបញ្ជាឲ្យគ្រូពេទ្យយ៉ាំងជំនាញ យកឧសថវិសេសមកព្យាបាលព្រះកាយសម្ដេច, ជរាពាធនោះក៏បានធូរថយសះស្បើយបន្តិច ។ ដំណើរនេះនាំឲ្យខ្ញុំព្រះករុណាទាំងឡាយជាសមណៈសិស្ស មានសេចក្ដីរំភើបតក់ស្លុតខ្លួនជាខ្លាំង ទើបរួមកំឡាំងគ្នាធ្វើបុណ្យនេះ ដោយផ្គង់ចិត្តឧទ្ទិសកុសលប្រគេនសម្ដេច ដើម្បីឲ្យអានុភាពបុណ្យនេះ ជួយសម្ដេចឲ្យសះស្បើយជរាពាធហើយ មានព្រះជន្មយឺនយូរតរៀងទៅ ។ ដូច្នេះ សូមសម្ដេចមេត្តាទទួលកុសល ដែលយើងខ្ញុំឧទ្ទិសប្រគេនតទៅនេះ ៖

បពិត្រសម្ដេច !

កុសលទាំងឡាយទោះជាសច្ចវាចាក្តី ទោះជាធម្មទានក្តី ទោះការនិមន្តព្រះសង្ឃមកស្វាធ្យាយព្រះបរិត្តក្តី ព្រមទាំងអាមិសទានរបស់ក្រុមពុទ្ធបរិស័ទក្តី ខ្ញុំព្រះករុណាទាំងឡាយជាក្រុមនិស្សិតនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត សូមតាំងប្រណិធានដោយមនោសញ្ចេតនាដ៏បរិសុទ្ធ លើកស្ទួយនូវបុណ្យកុសលនេះប្រគេនចំពោះសម្ដេច, សូមសម្ដេចតាំងព្រះទ័យអនុមោទនា ទទួលដោយសោមនស្ស !

សូមអំណាចអានុភាពនៃបុណ្យកុសលនេះ ព្យាបាលសម្ដេចឲ្យបានជាស្រឡះសះស្បើយចាកព្រះរោគ, សូមជ្រោមជ្រែងសម្ដេចឲ្យមានព្រះកាយរឹងប៉ឹងមាំមួនជាស្ថាពរឡើងវិញ, សូមជួយឧបត្ថម្ភសម្ដេចឲ្យមានព្រះជន្មាយុយឺនយូរទៅ ដើម្បីនឹងបានជាម្លប់ត្រជាក់សម្រាប់ជាទីជ្រកកោននៃខ្ញុំព្រះករុណាទាំងឡាយជាក្រុមនិស្សិត ។

ទីបំផុតនេះ ខ្ញុំព្រះករុណាអាត្មាភាពទាំងឡាយ សូមឧទ្ទិសផ្សាយផលនៃកុសលនេះដល់ព្រះថេរានុត្ថេរៈ នវកភិក្ខុ សាមណេរ ព្រមទាំងឧបាសកឧបាសិកា ជាពុទ្ធបរិស័ទដែលបាននិមន្តនឹងអញ្ជើញមកក្នុងពិធីបុណ្យនេះ សូមឲ្យបានសម្រេចនូវឥដ្ឋមនុញ្ញផលគ្រប់ៗគ្នាកុំបីខានឡើយ ។

+ × +

## សុន្ទរកថា ព្រះពុទ្ធវង្ស កៅ.ស៊ុម

ថ្លែងក្នុងនាមនៃសម្ដេចព្រះធម្មលិខិត ល្វី-ឯម ឧត្ដមប្រឹក្សាគណៈមហានិកាយ

តបសមណៈនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

អស់លោកសមណៈនិស្សិតទាំងឡាយ! សម្ដេចខ្ញុំ សូមឱកាសបន្តិច ដើម្បីថ្លែងសេចក្ដីទទួលអំណរយ៉ាងក្រៃលែង អំពីអស់លោកជាសមណៈនិស្សិត ដែលមានឧស្សាហ៍កុសលចេតនាផុះផុលឡើងក្នុងខន្ធ-សន្តាន ហើយបានមូលមតិរួមគំនិតគ្នាធ្វើបុណ្យគតញ្ញុតានេះឧទ្ទិសចំពោះរូបខ្ញុំ, ទាំងបានអញ្ជើញអស់លោក អ្នកសប្បុរសប្រុស ស្រីទាំងឡាយ ឲ្យចូលមកជួយពង្រីកបុណ្យនេះ ឲ្យមានវិសាលភាពធំទូលាយឡើងទៀត ។

អស់លោកសមណៈទិសៀតទាំងឡាយ ! សម្តេចខ្ញុំ មានសេចក្តីត្រេកអរជ្រះថ្លាជាកិយេ្យភាព ចំពោះបុណ្យកតញ្ញុតានេះដោយសុទ្ធចិត្ត ហើយបានធ្វើមនសិការៈប្រកបដោយមនោសញ្ចេតនា សំដែងអាការជាបដិគ្គាហកាពទទួលអំណារបុណ្យ ដែលអស់លោកទាំងឡាយ បានធ្វើបដិការគបដោយអាទរភាពចំពោះខ្ញុំ ដែលកំពុងតែរងសេចក្តីទុក្ខវេទនា ដោយរោគាពាធដ៏ដាច់គ្រប់សន្លាក់ជាប់តែរាល់ថ្ងៃ មិនដឹងជាទីពឹងបានថ្នាំអ្វីមកបន្ធូបរម្ងាប់រោគនេះ ឲ្យបានជាសះស្បើយទៅឡើយ, ឯថ្នាំសម្រាប់បន្សាបរម្ងាប់រោគនេះទីងលោកគ្រូពេទ្យ ដែលពូកែកស្ទាវមកព្យាបាលតែរាល់ថ្ងៃ ជាបច្ច័យឲ្យខ្ញុំបានធូរស្រាលគ្រាន់ទប់ទល់អត្តភាពនេះ ឲ្យប្រព្រឹត្តបានបន្តិច ៗ ចាត់ថាប្រសើរវិសេសណាស់ហើយ ។

ពេលនេះ ក្នុងសរីរពាងកាយរបស់ខ្ញុំ បានធូរស្រាលអំពីការឈឺចាប់បន្តិច ដោះបានទទួលបុណ្យកុសលរបស់អស់លោកជាសមណៈទិសៀត ដែលឧទ្ទិសប្រគេនចំពោះខ្ញុំ ។ មហាកុសលនេះដែលកើតឡើង ប្រហែលជាកើតដោយគំនិតអស់លោកដែលបានគិតឃើញថាៈ "ខ្ញុំជាមនុស្សមួយគួរជាទីស្នេហា គួរជាទីជ្រះថ្លា ស្រឡាញ់ពេញចិត្ត គួរជាទីគោរពរបស់អស់លោកទាំងឡាយ ក្នុងជរលោកសម័យសព្វថ្ងៃនេះ" ។ សម្តេចខ្ញុំ មានសេចក្តីពេញចិត្តណាស់ ដែលបានឃើញអស់លោកជាសមណៈទិសៀតទាំងឡាយមានសាមគ្គី បាននាំគ្នាសស្រោកសស្រាញមកធ្វើបុណ្យ ឧទ្ទិសប្រគេនខ្ញុំ ដើម្បីឲ្យខ្ញុំមានអាយុវឌ្ឍនភាពចំរើនឡើងជាអង្វែងទៅ ។ ក្នុងកិច្ចនេះ សម្តេចខ្ញុំ ពុំបានធ្វើបដិសណ្ឋារៈផ្ទាល់ចំពោះ

លោកជាសមណៈនិស្សិត ឲ្យបានសមរម្យពេញគ្រប់គ្រាន់ជូនល្មមនឹង
បដិការៈនោះៗ ដូចអស់លោកដឹងស្រាប់ហើយ ។

អស់លោកសមណៈនិស្សិតទាំងឡាយ! សម្តេចខ្ញុំ មានយោបល់
ប្រកបដោយ "ធម្មវិចារណ៍" បានពិចារណា ត្រិះរិះរំពឹងមើលចំពោះករជ-
កាយរបស់ខ្ញុំជាពល់ថ្ងៃហើយ ឃើញថាគ្មានផ្លូវណាមួយល្មមឲ្យសង្ឃឹមនឹង
តកាយុសង្ខារ ឲ្យជឿនលឿនវែងទៅ គ្រាន់នឹងបានជាទីពឹងពាក់សំណាក់
អាស្រ័យរបស់អស់លោកជាសមណៈនិស្សិតយូរប៉ុន្មានឡើយ ខ្ញុំសូមផ្តាំ
ទុកជាមុនថា "ខ្ញុំសូមលាលោកទាំងអស់ហើយ សូមលោករស់នៅជាខាង
ក្រោយ គួរខំប្រឹងរៀនសូត្រឲ្យបានចេះដឹងពិតប្រាកដក្នុងធម្មវិន័យ ហើយ
ចូរប្រតិបត្តិឲ្យបានម៉ឺតចត់បរិសុទ្ធក្នុងព្រះពុទ្ធសាសនាកុំបីឲ្យឃ្លៀងឃ្លាត"
ព្រោះវិបរិណាមធម៌ ធម៌សម្រាប់ធ្វើរូបកាយរបស់មនុស្សសត្វឲ្យប្រែប្រួល
ទៅជានិច្ច គឺជរានិងមរណៈ ដែលយើងបានឃើញជាក់ផ្ទាល់ភ្នែក ចេះតែ
សន្ធើញចូលមកជិតកិតណាស់ហើយ បានធ្វើឲ្យវិបត្តិដល់ការទៀងទាត់
គឺឲ្យបាត់មុខខានឃើញមុខគ្នាទៅវិញទៅមក មិនដឹងជាវេលាថ្ងៃណាមួយ
ចុះបើពល់រូបសត្វសុទ្ធតែយ៉ាងនេះហើយ តើធ្វើដូចម្តេចហ្ន៎! នឹងបាន
សេចក្តីសុខចំរើន ?

(មានត)

## ដំណើរទៅកាន់ប្រទេសឥណ្ឌា

# ក្នុងឱកាសបុណ្យពុទ្ធជយន្តី ព.ស.២៥០០ គ.ស.១៩៥៦

## នៃលោក ប៉ាយ-ប៊ុក ក្រុមការដើមខ្សែ

នាយផ្នែកការផ្សាយសៀវភៅនៃក្រុមពុទ្ធសាសនបណ្ឌិត្យ

ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យភ្នំពេញ

## លោក ប៉ាយ-ប៊ុក រៀបរៀង

---

ដោយបានទទួលសេចក្ដីអញ្ជើញរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិការនៃពិធីបុណ្យ ព.ស. ២៥០០ នៅទីក្រុងញូវដែល្ហីប្រទេសឥណ្ឌា ពីខែកក្កដា ១៩៥៦, ខ្ញុំ (ប៉ាយ-ប៊ុក) ក្នុងនាមសមាគមមិត្តពុទ្ធិកវិទ្យាល័យ បានចេញដំណើរតាមអាកាសយានពីក្រុងភ្នំពេញ នៅថ្ងៃអង្គារទី២០វិច្ឆិកា ១៩៥៦ ម៉ោង ៨,៣០នាទី ទៅដល់ទីក្រុងញូវដែល្ហី នៅថ្ងៃសៅរ៍ទី ២៤ វិច្ឆិកា ១៩៥៦ ពេលម៉ោង ១៧,៤០ នាទី ។ រដ្ឋាភិបាលឥណ្ឌាបានចាត់តំណាងម្នាក់ និងអ្នកប្រែភាសាបារាំងអង់គ្លេសម្នាក់ យករថយន្តមកទទួលខ្ញុំនៅចំណតអាកាសយាន "បាលំ" ។ រថយន្តក៏បាននាំខ្ញុំទៅសំណាក់នៅភោជនាគារ "អសោក" ដែលជាគ្រឹះស្ថានខ្ពស់ជាងគេបំផុតនៅទីក្រុងញូវដែល្ហី (៧ជាន់) ។ ភោជនាគារនេះជាទីសំណាក់នៃពួកគណៈប្រតិភូតាំងសែសិបប្រទេស ដែលទទួលនិងអញ្ជើញមកប្រជុំក្នុងពិធីបុណ្យនេះ ។

សូមជ្រាបថា: ពិធីបុណ្យពុទ្ធជយន្តីប្រទេសឥណ្ឌាគេចាប់ធ្វើតាំងពីថ្ងៃសៅរ៍ទី ២៤ វិច្ឆិកា ១៩៥៦ រហូតដល់ថ្ងៃពុធទី ១២ ធ្នូ ១៩៥៦ ។

ពិធីបុណ្យនេះបែងចែកជាពីរកាលៈ

កាលទី ១ ពិធីបុណ្យនៅទីក្រុងញូវដែល្ហីចាប់ពីថ្ងៃទី ២៤ វិច្ឆិកា ទៅដល់ថ្ងៃទី ២ ធ្នូ ១៩៥៦ ;

កាលទី ២ ការទស្សនាពុទ្ធបូជនិយដ្ឋានពីទីក្រុងញូវដែល្ហី ទៅដល់ទីក្រុងកាល់កុត្តា តាមអយស្ម័យយានពិសេស ចាប់ពីថ្ងៃទី ២ ធ្នូ ទៅដល់ថ្ងៃទី១២ ធ្នូ ១៩៥៦ ។

## ពិធីបុណ្យនៅទីក្រុងញូវដែល្ហី

ថ្ងៃសៅរ៍ទី ២៤ វិច្ឆិកា ១៩៥៦ ពិធីសម្ពោធបុណ្យពុទ្ធជយន្តិឥណ្ឌាបានធ្វើនៅថ្ងៃទី២៤វិច្ឆិកា ពេលម៉ោង១៧ នៅតំបន់ពមលិឡាគ្រូនក្រោមអធិបតីភាពលោករដ្ឋាគ្រឹស្នន៍ អនុប្រធានាធិបតីប្រទេសឥណ្ឌា, ប្រធាននៃគណៈកម្មាធិការប្រតិបត្តិការបុណ្យនេះ ។

ឥស្សរជនដែលបាននៅរួមក្នុងពិធីបុណ្យនេះគឺ

១- លោកបណ្ឌិតនេហ៍រូ នាយករដ្ឋមន្ត្រីប្រទេសឥណ្ឌា ប្រធានកិត្តិយសនៃគណៈកម្មាធិការប្រតិបត្តិការ ;

២- លោកអ៊ូ-នូ នាយករដ្ឋមន្ត្រីប្រទេសភូមា ,

៣- លោកសាស្ត្រាចារ្យ គ.ករ៉ាគីរ៍ ,

៤- ព្រះភិក្ខុស៊ីរហា ជ័គស្វ ,

៥- លោកគ្រីស្តស៊ិស ហំហ្វ្រីស៍ ,

៦- លោកជ័យវែរ៉ា គុរុព្វ ,

ព្រមទាំងឥស្សរជនឯទៀតជាច្រើននាក់ ។

ដំបូងលោកវង្គត្រីស្នង់បានថ្លែងសុន្ទរកថាទទួលអំណរចំពោះគណៈប្រតិភូនានាប្រទេស ដែលអញ្ជើញមកកាន់សន្និបាតនោះ ហើយលោកបានបញ្ចប់សុន្ទរកថាដោយពាក្យថាៈ "បុណ្យពុទ្ធជយន្តីនេះជាស្គរទូងឲ្យឧបាសកឧបាសិកាបានឮគ្រប់ៗគ្នាថា ករណីយកិច្ចនៃពួកពុទ្ធសាសនិកជនទាំងអស់ ត្រូវតែព្រួតគ្នាតស៊ូនឹងអយុត្តិធម៌ ព្រមទាំងអំពើកាចសាហាវ ដែលនាំមនុស្សលោកឲ្យធ្លាក់ទៅក្នុងមហាសង្គ្រាមសាកលលោកទី៣ទៀត" ។

លំដាប់ពីនោះមក បណ្ឌិតនេហ៍រូ បានថ្លែងសារលិខិតមួយយ៉ាងក្បោះក្បាយ ។ សេចក្ដីសង្ខេបនៃសារលិខិតនោះថា "ត្រូវតែពុទ្ធសាសនិកជនទាំងឡាយ ទោះជាមហាយានក្ដី ហីនយានក្ដី ត្រូវតែរួបរួមកាន់ដៃគ្នាដោយមេត្រីភាព នឹងភាតរភាព ដើរឆ្ពោះទៅរកសន្តិសុខព្រោះថាជាអ្នកជឿកាន់តាមឱវាទនៃព្រះសម្មាសម្ពុទ្ធតែមួយព្រះអង្គ, ការដែលយើងមានយោបល់ផ្សេងគ្នា មានគំនិតខ្វែងគ្នា ជាហេតុធ្វើឲ្យព្រះពុទ្ធសាសនាទុព្វលភាពជាលំដាប់" ។

ពិធីបុណ្យនេះ, បានបញ្ចប់ដោយមានមនុស្សផ្ទុខ្ទុយឲ្យសព្ទសាធុការពរ ចំពោះគណៈប្រតិភូទាំងអស់ ។

**ថ្ងៃអាទិត្យទី ២៥ វិច្ឆិកា** ម៉ោង ៦ ល្ងាច លោកអ៊ូ-នូ រដ្ឋមន្ត្រីប្រទេសភូមា បានថ្លែងសន្និសីទក្នុងនាមនៃគណៈប្រតិភូភូមានៅមន្ទីរសន្និសីទក្រុងឈ្មោះវិញ្ញាណកវ័ទ អំពីរឿងថាៈ យ៉ាងដូចម្ដេចដែរ

ហៅថា.ព្រះពុទ្ធសាសនា? លោក អ៊ូ-នូ បានពណ៌នាអំពីឱវាទរបស់ព្រះសម្មាសម្ពុទ្ធ ៣ យ៉ាងគឺ ការមិនធ្វើបាបអកុសល១, ការធ្វើកុសលឲ្យកើតមាន១, ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់១, បន្ទាប់មកលោកពណ៌នាអំពីអដ្ឋង្គិកមគ្គ ។

សន្និសីទនេះ បានបញ្ចប់នៅម៉ោង៨ ល្ងាច ។ លោកអ៊ូ-នូ បានធ្វើអំណោយជាសារវត្ថុផ្សេងៗ ក្នុងនាមនៃគណៈប្រតិភូភូមា ចំពោះរដ្ឋាភិបាលប្រទេសឥណ្ឌា ។

ថ្ងៃច័ន្ទ ទី២៦ វិច្ឆិកា ម៉ោង៩.១០នាទី មានការថតរូបនៅមុខមន្ទីរសន្និសីទ វិញ្ញាណភវ័ន ដែលមានលោកបណ្ឌិតនេហ៍រូ នាយករដ្ឋមន្ត្រីប្រទេសឥណ្ឌា បានអញ្ជើញទៅថតជាមួយ ។

លុះដល់ម៉ោង៩,៣០នាទី មានពិធីបើកសន្និសីទនៅមន្ទីរសន្និសីទក្រុង វិញ្ញាណភវ័ន នៅក្រោមអធិបតីភាពលោក បណ្ឌិតនេហ៍រូ ដោយលោករដ្ឋាគ្រិស្នន៍ ប្រធានគណៈកម្មាធិការប្រតិបត្តិការ មានទុក្ខជាទម្ងន់ដោយភរិយារបស់លោកទើបនឹងទទួលអនិច្ចកម្ម ។

សន្និសីទនេះពាក្យអង់គ្លេសថា symposium ប្រែថា "ការសួរដេញដោលឲ្យអស់សង្ស័យ ។ ទីសម្រាប់សន្និសីទខាងលើនេះមានវេទិកា១ សម្រាប់គណៈកម្មការបុច្ឆាវិសជ្ជនា, មានប្រធាន១ អនុប្រធាន២ លេខាធិការ១ អ្នកពាក់ព័ន្ធដែលត្រូវថ្លែងអត្ថបទមួយអំពីរឿងសិល្បៈព្រះពុទ្ធសាសនា១ ។

អត្ថបទទាំងនេះគេធ្វើជាភាសាអង់គ្លេស, មានបោះពុម្ពជាស្រេច ។

ខ្ញុំបានសួរថាអត្ថបទនេះគេធ្វើពីកាលណាមក ? លោកដុកទ័រម្នាក់ប្រាប់ខ្ញុំថា អត្ថបទនេះរដ្ឋាភិបាលឥណ្ឌៀបានបង្គាប់ទៅគណៈប្រតិភូគ្រប់ប្រទេសឲ្យពិនិត្យតាំងពីមុនធ្វើពិធីបុណ្យ ហើយគេបញ្ជូនអត្ថបទនេះទៅគណៈកម្មការពិនិត្យ ។ យល់ថាសមគួរហើយ ក៏ឲ្យបោះពុម្ពផ្សាយ ។ ដល់មកក្នុងពេលនេះ បុគ្គលណាដែលជាអ្នកតែងនៃអត្ថបទនេះ ត្រូវយកអត្ថបទនោះទៅសូត្រ ដាក់មៃក្រូសនសព្ទ ដែលស្ថិតនៅខាងស្ដាំគណៈកម្មការបុច្ឆាវិសជ្ជនា, បើកាលណាអានរួចហើយ ប្រធានគណៈកម្មការបានក្រោកឈរឡើង ប្រកាសសួរទៅគណៈប្រតិភូនានាប្រទេសដែលអង្គុយតាំងស្ដាប់នៅខាងក្រោម មានតុកៅអីស្ដាបនាជារង្វង់មូលធំថា តើលោកអ្នកយល់ទាស់យ៉ាងណាខ្លះទេ ? បើមានគណៈប្រតិភូម្នាក់យល់ទាស់ពីកថាខណ្ឌណា គណៈប្រតិភូនេះត្រូវឡើងទៅកាន់វេទិកា ដើម្បីថ្លែងពន្យល់តាមមៃក្រូ-សនសព្ទនឹងឲ្យយោបល់ ។ បើអ្នកពិគ្គិននោះមិនសុខចិត្ត ក៏ចូលទៅថ្លែងដោះស្រាយ លុះត្រាតែយោបល់ស្របគ្នា ។ បើចុងក្រោយមានអ្នកពិគ្គិនពីរនាក់ទាស់យោបល់គ្នា, ត្រូវលោកប្រធានគណៈកម្មការសំដែងហេតុផលហើយសម្រេច ។

លុះដល់ម៉ោង ១២ ទើបចប់នូវការបុច្ឆាវិសជ្ជនាមួយលើក ។ ម៉ោង ១៣ មានការលៀងភោជនាហារជាឧឡារិក នៅមហាសណ្ឋាគារនៃលោកបណ្ឌិតនេហ៍រូ ។

លុះដល់ម៉ោង ៣,៣០ នាទីរសៀល មានការបុច្ឆាវិសជ្ជនានៅមន្ទីរ

វិញ្ញាណកវ័ន ១ លើកទៀត ដែលមានឯកឧត្តម សម-សារី ជាប្រធានគណៈកម្មការ ។

ឯកឧត្តម សម-សារី ប្រធានគណៈប្រតិភូប្រទេសកម្ពុជា ជាប្រធានគណៈកម្មការបុប្ផាវិសជ្ជនា បានថ្លែងសន្និសិទមួយអំពីរឿងព្រះពុទ្ធសាសនា, លំដាប់តមក, មានពួកវាគ្មិននៃគណៈប្រតិភូនានាប្រទេស ថ្លែងជាលំដាប់រហូតដល់ម៉ោង៥ ល្ងាច ។

ម៉ោង៥,៣០នាទី ខ្ញុំនិងលោកសាជាស៊ីវ័នជាអ្នកប្រែភាសារបស់ខ្ញុំ បានទៅទស្សនាពិពណ៌អន្តរជាតិនៃសិល្បៈព្រះពុទ្ធសាសនា ។

ពិពណ៌អន្តរជាតិនេះ គឺធ្វើដោយការប្រមូលនិងអង្គការសហប្រជាជាតិនៃការសិក្សា, នូវវិទ្យាសាស្ត្រនិងវប្បធម៌ ដើម្បីនឹងផ្សាយនូវសិល្បៈ, អក្សរសាស្ត្រ,ទស្សនវិជ្ជានៃព្រះពុទ្ធសាសនា ។ មានប្រទេសជាច្រើនបានមកតាំងសិល្បៈព្រះពុទ្ធសាសនានៅទីនោះគឺ ប្រទេសឥណ្ឌៀ, ប៉ាគិស្ថង់, ថៃឡង់, ភូមា, ជាពិន, សហរដ្ឋអាមេរិក, ប្រទេសកម្ពុជា, រដ្ឋស៊ីគិម, ប្រទេសចិនប្រជាមានិត, នេប៉ាល; ហុងគ្រី, ឡាក្រង់ប្រឺតាញ់ជាដើម ។

ថ្ងៃអង្គារទី ២៧ វិច្ឆិកា ពេលម៉ោង១០, ខ្ញុំនិងលោក សាជាស៊ីវ័ណ្ណ(អ្នកប្រែភាសារបស់ខ្ញុំ)បានទៅកាន់វិហារឥណ្ឌូមួយឈ្មោះ វិហារលក្ស្មីនារ៉េន ។ ទៅដល់ទីនោះ នាយទ្វារបាលបានបង្គាប់ឲ្យយើងទាំងពីរទាក់ដោះស្បែកជើង ហើយឲ្យពាក់ស្បែកជើងផ្ទាត់ដែលមាននៅទីនោះ ទើបចូលទៅក្នុងវត្តនោះបាន ។ ខ្ញុំមានសេចក្តីឆ្ងល់ថា ស្បែកជើងយួបនិងស្បែកជើងផ្ទាត់តើខុសគ្នាយ៉ាងណា ? ខ្ញុំគិតមិនយល់សោះ ។ ក្នុង

ពេលនោះ ខ្ញុំបានលស្បែកជើងផ្លាត់ណាក៏មិនត្រូវជើង, ខ្ញុំក៏ដើរជើងទទេឡើងទៅលើវិហារនោះទៅ ។

វិហារនេះបណ្ដោយប្រហែល ៣០០ ម៉ែត្រ ទទឹងប្រហែល ២០០ ម៉ែត្រ, លោកបរលោជាអ្នកកសាង ។ នៅតាមសាលា, ព្រះវិហារ ស៊េន . . . . ល . . មានរូបព្រះនាងលក្សរ៉ី, ព្រះអគ្គមហេសីព្រះគ្រិស្នៈ ។

លំដាប់តមក, យើងបានទៅទស្សនាព្រះវិហារមួយដែលហៅថា "ព្រះវិហារព្រះពុទ្ធ" ដែលលោកបរលោកសាងដែរ ។ ព្រះវិហារនេះគឺសាងនៅជិតព្រះវិហារហិណ្ឌូ ។ ខ្ញុំបានសួរលោកសាដាស៊ីវ៉ណ្ណថា លោកបរលោនេះជាអ្វី ? លោកជាអ្នកកាន់ព្រះពុទ្ធសាសនា ឬព្រាហ្មណ៍សាសនា ? លោកសាដាស៊ីវ៉ណាឆ្លើយតបមកខ្ញុំវិញថា លោកបរលោនេះជាមហាសប្បុរស លោកមិនប្រកាន់លទ្ធិណាសាសនាណាទេ, ឲ្យតែកិច្ចការនោះជាប្រយោជន៍សាធារណៈ លោកចេះតែសាង ព្រោះលោកមានធនធានគ្រប់គ្រាន់ល្មមធ្វើបាន ។ ព្រះវិហារព្រះពុទ្ធនេះមានបណ្ដោយប្រហែល ១៥០ម. ទទឹងប្រហែល ១០០ម. ។

លុះដល់ម៉ោង ១៧-៣០ នាទី យើងបានទៅកាន់ទីមហាពោធិសមាគមនៅញូវដែល្ហី, ជិតទំព័រវីងរ៉ូត ដោយមានពិធីទទួលនៅទីនោះ ។ ពិធីនេះគេធ្វើនៅក្រោមអធិបតីភាពនៃលោកដុកទ័រ ក.ន. កាត់ជូ រដ្ឋមន្ត្រីក្រសួងការពារប្រទេស ។

ម៉ោង២០ យើងបានទទួលការជប់លៀងភោជនាហារនៅភោជនាគារអសោក ដោយលោកបណ្ឌិតនេហ៍រូ នាយករដ្ឋមន្ត្រីប្រទេសឥណ្ឌាជាអ្នក

អញ្ជើញ ។ ម៉ោង២១,៣០នាទីយើងបានទៅទស្សនាល្ខោនឥណ្ឌូ លេង
រឿងជីវភាពព្រះសិទ្ធត្ថកុមារ ដោយសេចក្តីអញ្ជើញពីសមាជិកម្នាក់ នៃ
គណៈកម្មាធិការប្រតិបត្តិការបុណ្យពុទ្ធជយន្តិ, នៅតំបន់ទល-មិល្ហ.ក្ហួត ។

ល្ខោនឥណ្ឌូជាសិល្បៈមួយដ៏ចំឡែក ហើយចេះផ្សំទិដ្ឋភាពធម្មជាតិ
មេឃ, ផ្កាយ, ពពកដោយពន្លឺអគ្គិសនីគ្រប់ពណ៌, ទាំងតាបូគំនូរផ្សេងៗ
ឲ្យទៅជាស្ថានទីមួយដ៏ល្អស្អាត គួរឲ្យមើលណាស់របៀបតំ ប្រៀង,
កាយវិការផ្សេងៗ នៃល្ខោននោះវិសេសវិសាលពន់ពេក ។

ថ្ងៃពុធទី ២៨ វិច្ឆិកា ម៉ោង៩,៥០នាទី, មានការធ្វើសន្និសីទ
បុច្ឆាវិសជ្ជនានៅមន្ទីរវិញ្ញាណកវ័ន ។ ម៉ោង១៤,៣០នាទី មានធ្វើសន្និសីទ
អំពីសិល្បៈព្រះពុទ្ធសាសនា នៅកន្លែងសន្និសីទដដែល, ដល់ម៉ោង ១៩,
៣០នាទី, មានការលេងល្ខោនឥណ្ឌូអំពីរឿងពុទ្ធប្រវត្តិ ។ ក្នុងពេលនោះ
លោក ជូ-អេន-ឡាយ នាយករដ្ឋមន្ត្រីប្រទេសចិនប្រជាមានិត ក៏បាន
អញ្ជើញទៅទស្សនាដែរ ។

ថ្ងៃព្រហស្បតិ៍ទី ២៩ វិច្ឆិកា ម៉ោង៩,៣០ នាទី, មានធ្វើ
សន្និសីទបុច្ឆាវិសជ្ជនានៅកន្លែងសន្និសីទក្រុង ។ ម៉ោង១៤,៣០នាទី,
សន្និសីទក៏ផ្តើមតទៅទៀត រហូតដល់ម៉ោង១៧ ៕

ម៉ោង ១៨,៣០ នាទី លោករាជេន្ទ្រប្រសាទ ប្រធានាធិបតី
សាធារណរដ្ឋឥណ្ឌា បានអញ្ជើញគណៈប្រតិភូនានាប្រទេសទៅជប់
លៀងនំទឹកតែ នាវិមានរបស់លោក ។

(មានត)

(តមក)

អកុហក គុ. ដែលមានការបំភាន់ជំនឿមិនមាន; ដែលមិនបំភាន់,ដែលមិនកុហក។

អកូជ គុ. ដែលមិនលាន់ឮ,ត;–ន គុ. (កង់) ដែលមិនលាន់សំឡេង ។ នបុំ. កិរិយាស្ងៀម ។

អកូបារ បុំ. សមុទ្រ; មេអណ្តើក ។

អក្ឫច្ឆ្រ គុ. ដែលមិនលំបាក ។

អក្ឫត គុ. ដែលមិនធ្វើហើយ; នបុំ. កម្មពីបុគ្គលមិនធ្វើហើយ; *អក្ឫតា* ស្ត្រី. កុមារិកាដែលមិនទាន់ពេញច្បាប់; *អក្ឫតាត៌* គុ. ដែលមានប្រយោជន៍មិនទាន់ធ្វើហើយ ។ – *ចូឌ* គុ. ដែលមានពិធីចូឌៈ (កោរសក់) មិនទាន់ធ្វើហើយ ។ – *ជ្ញ* គុ. ដែលមិនដឹងឧបការគុណដែលគេបានធ្វើហើយ; – *ជ្ញតា* ស្ត្រី. ភាវៈនៃបុគ្គលមិនដឹងឧបការគុណដែលគេបានធ្វើហើយ ។ – *បុណ្យ* គុ. ដែលមានបុណ្យកិច្ចមិនទាន់ធ្វើហើយ ។ – *ប្រជ្ញ* គុ. ដែលមានប្រាជ្ញាមិនទាន់ធ្វើហើយ, ល្ងង់ខ្លៅ ។ – *ពុទ្ធិ* គុ. ដែលមានពុទ្ធិមិនទាន់ធ្វើហើយ (ដែលមានកិរិយាត្រាស់ដឹងមិនទាន់ធ្វើហើយ); – *ពុទ្ធិត្វ* នបុំ. ភាវៈនៃបុគ្គលមានពុទ្ធិមិនទាន់ធ្វើហើយ ។ – *វៃរ* គុ. ដែលមានពៀរមិនទាន់ធ្វើហើយ ។ – *វ្រណ* បុំ. នាមនៃព្រាហ្មណ៍ម្នាក់ ។ – *សំជ្ញ* គុ. ដែលមានការសិក្សាមិនទាន់ធ្វើហើយ ។ *អក្ឫតាគស៑* ( < *អក្ឫត* + *អាគស៑* ) គុ. ដែលមានទោសមិនទាន់ធ្វើហើយ ។ *អក្ឫតាត្មន៑*. ( < *អក្ឫត* + *អាត្មន៑* ) គុ. ដែលមានអាត្មាមិនទាន់ធ្វើហើយ ។ *អក្ឫតាថ៌* ( < *អក្ឫត* + *អថ៌*) គុ. ដែលមានអាថ៌មិនទាន់ធ្វើហើយ ។ *អក្ឫតាស្ត្រ* ( < *អក្ឫត* + *អស្ត្រ* )គុ. ដែលមាន

អស្ត្រ (អាវុធ) មិនទាន់ធ្វើហើយ ។ *អក្ឫតាហ្និក* ( < *អក្ឫត + អហ្និក* ) គុ. ដែលមានពិធីវិតមិនទាន់ធ្វើហើយ ។

**អក្ឫត្យ** គុ. ដែលបុគ្គលមិនគប្បីធ្វើ; នបុំ. កម្មគឺបុគ្គលមិនគប្បីធ្វើ, បទឧក្រិដ្ឋ ។ *–ការិន* គុ. ដែលធ្វើនូវកម្មដែលបុគ្គលមិនគប្បីធ្វើ, មនុស្សត្រូវទោសបទឧក្រិដ្ឋ ។

**អក្ឫត្ត** គុ. ដែលបុគ្គលមិនកាត់ហើយ ។

**អក្ឫត្រិម** គុ. ដែលមិនក្លែង, ដែលជាធម្មជាតិ ។

**អក្ឫត្ស្ន** គុ. ដែលមិនពេញលេញ។ *–វិទ* គុ. ដែលមានវិជ្ជាពេញលេញមិនមាន។

**អក្ឫប** គុ. ដែលមិនអាណិត; *–ណ* គុ. ដែលមិនក្រីក្រ, ដែលស្ដុកស្ដម្ភ ។

**អក្ឫឝ** គុ. ដែលមិនស្គម, ធាត់; *– លក្ស្មី* គុ. ដែលមានលក្ស្មី (ទ្រព្យ, សេចក្ដីចំរើន) មិនក្បត់ឡើយ, ដែលមានលក្ស្មីពេញបរិបូណ៌ ។ *អក្ឫឝានេកកណ្ដក* ( < *អក្ឫឝ + អនេក + កណ្ដក* ) គុ. ដែលមានបន្លាអនេកមិនមាន, ដែលរួចពីបន្លា ។

**អក្ឫឞ្ដ** គុ. ដែលមិនភ្ជួរហើយ, ដែលមិនដឹកហើយ; ដែលមិនដាំហើយ, ដែលដុះដោយខ្លួនឯង ។ *– រោហិន* គុ. ដែលដុះដោយមិនបាច់ដាំ, ដែលដុះដោយខ្លួនឯង ។

**អកេតន** គុ. ដែលមានលំនៅមិនមាន ។

**អកេឝ** គុ. ដែលមានសក់មិនមាន, ដែលទំពែក ។

**អកេឝរ** គុ. ដែលមិនមែនជាកេសរៈ; ដែលមិនមែនរុក្ខ, ដែលមិនមានសក់ ។

**អកោប** បុ. សេចក្ដីមិនក្រោធ, នាមៈមួយមន្ត្រីនៃព្រះបាទទសរថ ។

**អកោបន** គុ. ដែលមិនក្រោធ ។

អកោវិទ គុ. ដែលមិនឈ្លាស, ខ្លៅ ។

អកោឝ គុ. ដែលមិនមានស្រោម ។

អក្កា ស្ត្រី. ម្តាយ; មេអណ្តើក ។

អក្ត គុ. (អឝិ) ដែលនាំទៅហើយ ។

អក្ត គុ. (អញ្ជ) ដែលលាបលនហើយ។

អក្តា ស្ត្រី. យប់ ។

អក្តុ បុ. ពណ៌, ពន្លឺ; ពណ៌ខ្មៅ; ងងឹត, យប់ ។

អក្ខោបន គុ. ដែលមិនសើម ។

អក្រ (<អ+ក្រ) ដែលមិនកម្រើក, ដែលនឹងថ្កល់ ។

អក្រ បុ. ទង់; ប្រាកា; រកំពែង ។

អក្រតុ គុ. ដែលមានបំណង់មិនមាន ។

អក្រម គុ. ដែលឥតក្រម, ដែលមានលំដាប់មិនមាន, ដែលរាត់រាយ ។

អក្រវិហស្ត គុ. ដែលមានដៃប្រហ្យាក់ឈាមមិនមាន ។

អក្រវ្យាទ គុ. ដែលមិនស៊ីសាច់ ។

អក្រាន្ត គុ. ដែលមិនទៅ, ដែលមិនកន្លង ដែលបោះមិនបាន ។

អក្រិយា ស្ត្រី. អក្រិយា, កា.មិនមានអំពើ ។

អក្រូរ គុ. ដែលមិនកាច, ស្លូត; ដែលមិនរឹង. ទន់ ។ បុ. នាមព្រះឈ្មោះយាទវៈ ។

អក្រោធ គុ. ដែលមានក្រោធមិនមាន; បុំ. សេចក្ដីមិនក្រោធ ។

អក្លម គុ. ដែលមិនអស់កម្លាំង, មុឺងម៉ាត់; មាំទាំ ។

អក្លិឞ្ឋ គុ. ដែលមិនសៅហ្មង, វិសេស ។ -*ការិន៑*, ដែលធ្វើការមិនសៅហ្មង ។ -*ភាវ* បុំ. អក្លិឞ្ឋភាព, ភាវៈនៃបុគ្គលមិនសៅហ្មង ។ -*វ្រត* គុ. ដែលមានព្រតមិនសៅហ្មង ។

អក្លេឝ្យ គុ. ដែលមិនគប្បីធ្វើឲ្យសៅហ្មង ។

អក្លេឝ បុំ. កិរិយាមិនលំបាក, ការមិនមានទុក្ខ ។ *អក្លេឝាត៑*, អស់ព្យាយាម ។

អក្ស បុំ. ល្បែងបាសក, គ្រឿងលេង; ឈ្មោះដើមឈើ ។ -*កិតវ* បុំ. អ្នកលេងបាសក ។ -*កូដ* នបុំ. កលល្បិចនៃល្បែងបាសក; ការកាងនៃល្បែងបាសក ។ -*ក្សបណ* បុំ. ឈ្មោះនៃអ្នកលេងបាសកម្នាក់ ។ -*គ្លហ* បុំ. ការដើរនៃល្បែងបាសក, ការអុកនៃល្បែងបាសក ។ -*ទេវិត្ឫ* ក.ន., -*ទេវិន៑* បុំ.; -*ធូត៌* បុំ. អ្នកលេងបាសក ។ -*ទ្យូត* នបុំ. ល្បែងនៃបាសក ។ -*ភូមិ* ស្ត្រី. ភូមិនៃល្បែងបាសក, ទីឋានលេងនៃល្បែងបាសក ។ -*មទ*. បុំ. កិរិយាញៀននៃល្បែងបាសក ។ -*មាលា* ស្ត្រី. កម្រងនៃអក្ស, ផ្គាំ (ដែលធ្វើពីគ្រាប់ឈើអក្ស); ផ្កាយអរុន្ធតី; -*មាលិកា* ស្ត្រី. ផ្គាំ; -*មាលិន៑* បុំ. (ដ៏ទ) អ្នកមានផ្គាំ, ព្រះសិវៈ ។ -*វលយ* នបុំ. កងនៃអក្ស, ផ្គាំ; -*វលយិន៑* គុ. ដែលមានកងអក្ស, ដែលមានផ្គាំ ។ -*សូត្រ* នបុំ. ខ្សែនៃអក្ស, ផ្គាំ ។ -*ហ្ឫទយ* នបុំ. ហឫទ័យនៃបាសក, ល្បិចនៃបាសក ។ *អក្សាតិវប* ( <*អក្ស*+*អតិវប*) បុំ. អ្នកយាមនៃល្បែងបាសក ។ *អក្សាវលី* ( <*អក្ស*+*អាវលី*) ស្ត្រី. កម្រងនៃផ្គាំ, ផ្គាំ ។

អក្ស បុំ. ភ្នែក (ទេះ); ព្រហ្ម; ឈ្មោះមនុស្ស ។

អក្ស (មើលអក្សិ) បុំ. នបុំ. អង្គារយេវៈ ។

អក្សណិក គុ. ដែលប្រយ័ត្ន ។

អក្សត គុ. ដែលមិនអស់ទៅ, ដែលមិនអន្តរាយ; បុំ. ពហុ. ឬ នបុំ. ឯក. គ្រាប់ស្រូវ (ដែលបកសម្បកហើយ) សម្រាប់ពិធីបូជា ។

អក្សត្រ, អក្សត្រិយ គុ. ដែលមិនមែនក្សត្រ, ដែលមិនមានក្សត្រ ។

អក្សិ មើល អក្សិ ។

អក្សម គុ. ដែលមិនមានសមត្ថភាព, ដែលមិនធ្ងន់ស; ដែលមិនខ្ចង់, ដែលមិនរកកល ។ *អក្សមា* ស្ត្រី. សេចក្តីប្រាថ្នា, បំណង; សេចក្តីខ្ញាញ់ ។ *អក្សមាវន្ត* គុ. ដែលមានបំណង; ដែលខ្ញាញ់ ។

អក្សមិន គុ. ដែលមិនអាណិត ។

អក្សយ គុ. ដែលមិនអស់ទៅ, ដែលឋិតថេរ ។ –*ត្វ* នបុំ. ភាពអក្ស័យ, ភាពមិនអស់ទៅ ។

អក្សរ គុ. ដែលមិនសឹក, ដែលមិនវិបរិល; នបុំ. ពាក្យ, សំដី; ព្យាង្គ, ព្យាង្គថា "ឧម" ; អក្សរ, សំឡេងភាសា; បើជាពហុ. ឯកសារដែលសរសេរហើយ; ទេវតាជាន់ខ្ពស់; នាមនៃទេវតាផ្សេង ៗ ។ – ការ បុំ. សមាធិចិត្តមួយបែប ។ –*ចញ្ចុ* ឬ –*ចុញ្ចុ* ពុំនោះ –*ចណ* ឬ–*ចន* បុំ. "អ្នកឈ្លាសសរសេរ" អ្នកនិពន្ធ ។ –*ច្យុតក* នបុំ. កិរិយាច្បុតនៃព្យាង្គ (ល្បែង) ។ – *ឆន្ទស* បុំ. ឆន្ទនៃអក្សរ ។

(មានត)